បណ្ឌិត ជា ឈោង

# ជំនឿខ្មែរ

ឆ្នាំ ១៩៩៨

បណ្ឌិត ជា ឈាង

នាយកដ្ឋាន ផលិតកម្ម និង បសុព្យាបាល
ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

# ជំងឺជ្រូក

ម.ព.ឯ.ក AIDOC
Code: 241-003
Date:
Donated by:

ឆ្នាំ ១៩៩៨

# ជំងឺបង្កឡើងដោយវីរុស

## *Maladies à virus*
## *Virus Diseases*

## ជំងឺផ្ដាសាយ

**La grippe du porc**
**Flu, Hog Flug, Swine flu**
**Swine influenza**

ជំងឺផ្ដាសាយ ច្រើនកើតនៅកន្លែងចិញ្ចឹមខ្វះអនាម័យ និង ខ្វះពន្លឺថ្ងៃ ។ ជាជំងឺផ្លូវដង្ហើម ហើយក្នុងករិកធ្ងន់ អាចឆ្លងរាលដាលយ៉ាងរហ័ស ។ ជំងឺនេះច្រើន កើតនៅរដូវភ្លៀង និង ពេលផ្លាស់ប្ដូររដូវ ។

ជំងឺផ្ដាសាយ កើតឡើងដោយការផ្សំគ្នានៃមេរោគ Hémophilus influenzae និង វីរុសនៃជំងឺផ្ដាសាយរបស់ជ្រូក ។

គឺវីរុសនៃជំងឺផ្ដាសាយជាអ្នកបង្កឱ្យមានជំងឺ ប៉ុន្តែបើមានតែម្នាក់វានោះ មិនបណ្ដាលឱ្យមានជំងឺធ្ងន់ធ្ងរទេ ។ ចំណែក Hémophilus influenzae តែម្នាក់វាក៏មិនបង្កឱ្យមានជំងឺដែរ ប៉ុន្តែនៅពេលដែលវាទាំងពីរបូកបញ្ចូលគ្នា នោះនឹងបណ្ដាលឱ្យមានជំងឺផ្ដាសាយធ្ងន់ធ្ងរ ឆ្លងរាលដាលរហ័ស

ហើយក្នុងលក្ខណៈខ្លះ គេឃើញវានៅលាយឡំជាមួយនឹងមេរោគ Pasteurella multocida ទៀតផង ។

ប្រវត្តិសង្ខេប :

គេបានរកឃើញជំងឺផ្តាសាយជ្រូកតាំងពីឆ្នាំ១៩១៨ ។ បណ្ឌិត J.S.Koen( ១៩២២ ) និយាយថា ជំងឺផ្តាសាយជ្រូកមានលក្ខណៈប្រហាក់ប្រហែលគ្នានឹងជំងឺផ្តាសាយរបស់មនុស្ស ។ គេមានការលំបាកក្នុងការបែងចែកជំងឺផ្តាសាយជ្រូក និង ជំងឺផ្តាសាយមនុស្ស ព្រោះជំងឺទាំងពីរនេះមានរោគសញ្ញាដូចគ្នា : ក្តៅ ក្អក មិនស្វាវ ស៊ីចំណី ពិបាកដកដង្ហើម ។

ជ្រូកដែលកើតជំងឺផ្តាសាយ ដេកគរលើគ្នាមួយកន្លែង ។ ជំងឺនេះឆ្លងរាលដាលរហ័សណាស់ ក្នុងមួយឆ្នាំ ១៩១៨ វាបានសម្លាប់ហ្វូងជ្រូកនៅលើពិភពលោកអស់ចំនួន ២១លានក្បាល ។ បច្ចុប្បន្នជំងឺផ្តាសាយជ្រូកកើតមានគ្រប់ទីសទីក្នុងពិភពលោក ។

ការឆ្លងរាលដាល :

ជ្រូកដែលមានជំងឺផ្តាសាយ អាចចំលងទៅជ្រូកជាបានយ៉ាងឆាប់រហ័ស ។ កូនជ្រូកអាយុតិចជាងមួយខែ មានជំងឺនេះច្រើនជាងជ្រូកធំ ។ នៅប្រទេសយើង ជំងឺនេះច្រើនកើតនៅដើមរដូវភ្លៀង ។ លក្ខណៈពិសេសនៃជំងឺនេះ គឺកើតមានយ៉ាងរហ័ស ហើយឆ្លងរាលដាលយ៉ាងលឿន ក្នុងរយៈពេលតែពីរ-បីថ្ងៃ ជ្រូកទាំងអស់ក្នុងទ្រុងសុទ្ធតែមានជំងឺនេះ ។

រោគសញ្ញា :

រយៈពេលសម្ងំរបស់មេរោគគឺ ៣-៦ថ្ងៃ ។ ជំងឺកើតឡើងរហ័ស បណ្តាលឱ្យជ្រូកក្តៅ មិនស៊ីចំណី ក្អក ។ នៅថ្ងៃទីបី កំដៅខ្លួនឡើងដល់ ៤១,៤°-C រួចចុះមកវិញ ជ្រូកក្អកយ៉ាងខ្លាំង ពិបាកដកដង្ហើម ហៀរសំបោរ ខាប់ ពពឹកភ្នែក ហើមស្លូត ។ ជ្រូកឈឺ ច្រើនងាប់នៅថ្ងៃទី ៣, ៤, ៥ ឬទី ៦ អាស្រ័យទៅតាមសភាពរបស់ជំងឺធ្ងន់ ឬ ស្រាល ។ ជ្រូកដែលមិនងាប់ពីជំងឺនេះចិញ្ចឹមក្រធំ ។

ប្រសិនបើយើងថែទាំវាបានល្អ តែក្នុងរយៈពេល ៣-៧ថ្ងៃ ជ្រូកអាចជា ប៉ុន្តែនៅតែក្អក រហូតដល់បីអាទិត្យទើបបាត់ ។

វិធីការពារ :

គ្មានថ្នាំការពារជំងឺផ្តាសាយជ្រូកទេ ។ មធ្យោបាយការពារជំងឺផ្តាសាយដ៏ប្រសើរបំផុត គឺត្រូវចិញ្ចឹមជ្រូកក្នុងទ្រុងស្ងួត មិនសើមប៉ផ្លិចប៉ផ្លាច់ កក់ក្តៅ និង មានខ្យល់អាកាសចេញ-ចូល ។

ការព្យាបាល :

- លាយ Sulfathiazole ក្នុងទឹកឱ្យជ្រូកឈឺផឹកក្នុងរយៈពេលពីរថ្ងៃ រួចហើយឱ្យជ្រូកផឹកទឹកថ្លាស្អាតពីរថ្ងៃទៀត បើមិនឃើញមានលទ្ធផលទេ លាយ Sul-fathiazole ឱ្យផឹកមួយថ្ងៃទៀត ។

- ចាក់វីតាមីន C ជួយឱ្យជ្រូកឆាប់ជាពីជំងឺ

- ក្នុងករណីជ្រូករលាកស្លូត ត្រូវចាក់ Streptomycine ឬ Pénicilline ឬក៏ប្រើ Auréomycine ចាក់ក៏បាន ផឹកក៏បាន ។

### តើជំងឺផ្តាសាយជ្រូកឆ្លងមកមនុស្សដែរឬទេ ?

ពិតជាការគួរឱ្យចាប់អារម្មណ៍ ព្រោះថាជំងឺផ្តាសាយជ្រូកកើតមាននៅឆ្នាំ ១៩១៨ បណ្តាលមកពីជំងឺផ្តាសាយរបស់មនុស្ស ក៏ប៉ុន្តែជំងឺនេះស្ថិតនៅស្ថេរភាព តែលើសត្វជ្រូកមិនបង្កឱ្យមានជំងឺដល់ជីវិតសត្វលោកដទៃទៀតទេ ។

## ជំងឺប៉េស្តជ្រូក

**La peste porcine**

**Hog Cholera - Swine fever**

ដោយសារវិធានការពារមានលក្ខណៈល្អប្រសើរ ជំងឺប៉េស្តជ្រូកត្រូវកំចាត់ចេញជាស្ថាពរពីប្រទេសអាមេរិក និង ពីប្រទេសមួយចំនួនទៀតដូចជា អង់គ្លេស កាណាដា ដាណឺម៉ាក អូស្ត្រាលី ។ ល ។

ការចំលងជំងឺជាទូទៅគឺតាមរយៈផ្លូវរំលាយអាហារ និង តាមផ្លូវដង្ហើម។

ជំងឺប៉េស្តជ្រូក ជាជំងឺឆ្លងកាចសាហាវ បង្កឡើងដោយសារវីរុសមួយប្រភេទ ។ ជំងឺនេះកើតមានជាលើកដំបូងនៅឆ្នាំ ១៨៣៣ នៅរដ្ឋ Ohio សហរដ្ឋអាមេរិករួចហើយឆ្លងរាលដាលពាសពេញសហរដ្ឋទាំងមូល។

ជំងឺប៉េស្តជ្រូកកើតមានតែនៅលើសត្វជ្រូក ទន្សាយ ចៀម ពពែ សត្វ ដទៃទៀតមិនកើតជំងឺនេះទេ តែអាចពាំមេរោគចំលងឱ្យសត្វជ្រូក ។

រោគសញ្ញា :

មិនស៊ីចំណី ទុក្ខព្រួយ រសេះរសោះ ហេវហត់ ទន់ខ្សោយ ខ្ជិលដើរ [illegible]ហ្សាហ៍ឈរប្ដូរជើង ហាក់បីដូចជាដើម្បីសំរាលការឈឺចាប់ ឈរមិនជាប់ ជួនប្រឹងងើបឈរ តែត្រូវដួលទៅវិញ ច្រើនដេកមួយកន្លែង ជ្រូកមួយចំនួនញ័រញាក់ ងងឹតភ្នែក កំដៅឡើងដល់ ៤១-៤២°C ហៀរទឹកភ្នែកព្រមទាំងមានពពឹកស្អិតជាប់ គ្របកភ្នែកទាំងលើទាំងក្រោម ជួនកាលមានហៀរសំបោរ ដំបូងរាវ ក្រោយមកក្លាយជាក្រមរស្ងួតនៅចុងច្រមុះ រាំងស្ទះការដកដង្ហើម ។ ទោះបីជាពពឹកភ្នែកបិទជិតភ្នែក ជាសញ្ញាសំគាល់នៃជំងឺប៉េស្តជ្រូកក៏ដោយ ក៏មានករណីខ្លះគ្មានរោគសញ្ញានេះដែរ ។ ក្រោយមកទល់លាមក ក្អៀនមួយរយៈខ្លី រួចហើយរាគរូសយ៉ាងខ្លាំង លាមកពណ៌លឿង ក្តួតចង្អោរ ក្នុងលាមក និង ក្នុងកំអួត អាចនឹងឃើញមានព្រូនចង្កឹះ ( Ascaris ) ប្រសិនបើជ្រូកនោះមានព្រូនចង្កឹះ ។ បន្ទាប់មកទៀតជ្រូកអាចនឹងទល់លាមកឡើងវិញ បើគ្មានជំងឺស្មុគ្រស្មាញរួមផ្សំទេ ។ បន្ទាប់មកមានកកឈាមដុំតូចៗនៅក្រោមស្បែក កន្ទួលក្រហមនេះអាចមើលឃើញច្បាស់នៅលើជ្រូកដែលមានសម្បុរស នៅកន្លែងស្បែកស្តើង ដូចជានៅលើត្រចៀក រន្ធត្រចៀក ច្រមុះ ភ្លៅ និង ពោះ ។ល។ កន្ទួលក្រហមតែមួយមុខ មិនអាចឱ្យយើងកំណត់បានថាជាជំងឺប៉េស្តទេ ព្រោះជំងឺផ្សេងទៀតក៏មានរោគសញ្ញាបែបនេះដែរ ។ កន្ទួលក្រហមនៅលើជ្រូកកើតជំងឺប៉េស្ត មានពណ៌ក្រមៅ ហើយរាលធំជាងកន្ទួលក្រហមនៅលើជំងឺកញ្ជ្រិល ។ ក្នុងសភាពជំងឺរ៉ាំរ៉ៃ ជួនពេលខ្លះមិនមានកន្ទួលក្រហមនេះទេ ។

ក្នុងតំណាក់កាលចុងក្រោយ គេឃើញជ្រូកឈឺមានដំណើរលូតល្វៃទន់ល្វែងក្រោម សញ្ញានេះក៏ជាលក្ខណៈពិសេសនៃជំងឺប៉េស្តជ្រូកដែរ ។

ជំងឺប៉េស្តជ្រូក ច្រើនបូកផ្សំនឹងជំងឺដទៃទៀត ដូចជាជំងឺរលាកសួត រលាកពោះវៀន ឬក៏ជាមួយជំងឺដទៃទៀត គេពិបាកនឹងឃើញជំងឺប៉េស្តជ្រូកពិតប្រាកដណាស់ ។

**វិធីការពារ :**

ចាក់ថ្នាំការពារជាការសំខាន់ ប៉ុន្តែត្រូវយកចិត្តទុកដាក់លើបញ្ហាមួយចំនួនដូចតទៅ :-

- ត្រូវថែរក្សាជ្រូកឱ្យមានសុខភាពល្អ អនុវត្តអនាម័យឱ្យបានត្រឹមត្រូវ ។

- ចំពោះទ្រុងជ្រូកដែលមានជំងឺនេះ ត្រូវរោយកំបោរ ឬ ចាក់ទឹកដាំពុះសំលាប់មេរោគ ។ លាមក និង ទឹកនោមត្រូវផ្ទាប់ជាមួយកំបោរ ។

- មួយខែក្រោយមក សឹមចាប់ផ្តើមចិញ្ចឹមឡើងវិញ ដោយត្រូវចាក់ថ្នាំការពារគ្រប់ជ្រូកទាំងអស់ ។

**ការព្យាបាល :**

ចំពោះជ្រូកដែលឈឺយូរថ្ងៃ មានរោគសញ្ញាច្បាស់លាស់នោះ មិនអាចព្យាបាលជាទេ តែចំពោះជ្រូកដែលទើបឈឺ យើងអាចព្យាបាលដោយប្រើសេរ៉ូមការពារជំងឺប៉េស្ត បូកផ្សំជាមួយអង់ទីប៊ីយ៉ូទិកដូចជា Terramycine ឬ Auréomycine ប្រើពី ០,២៥០ក្រ-១ក្រ ក្នុងមួយថ្ងៃ ទៅតាមទំងន់ជ្រូកតូច ឬ ធំ ប្រើក្នុងរយៈពេលបីថ្ងៃ ឬ ក៏អាចប្រើ Chloram-

phénicol 15 mg ក្នុងទំងន់ជ្រូក ១គក្រ ចាក់សាច់មួយថ្ងៃម្តង ក្នុងរយៈពេល ៤-៥ថ្ងៃ បើឱ្យផឹកគឺប្រើលើសពីកំរិតចាក់មួយជាពីរ ។

## ជំងឺអុត

**La variole porcine**
**Swine pox**

ជំងឺអុតជ្រូក ( Variola Suilla ) ជាជំងឺបង្កឡើងដោយវីរុស ។ ជំងឺនេះច្រើនកើតនៅកន្លែងចិញ្ចឹមជ្រូកប្រមូលផ្តុំ ហើយកើតមានគ្រប់ទិសទីពាសពេញពិភពលោក ។ Peiper ( ១៩០១ ) បញ្ជាក់ថាជំងឺអុតមនុស្សអាចចំលងទៅជ្រូក ហើយជំងឺអុតជ្រូក ក៏អាចចំលងមកមនុស្សដែរ ។ ជ្រូកធំមិនសូវកើតជំងឺនេះដូចជ្រូកតូចទេ ។ កាលណាពីក្មេងធ្លាប់កើតជំងឺនេះហើយ ដល់ធំឡើងមានភាពស៊ាំនឹងជំងឺនេះអស់មួយជីវិត គឺវាមិនអាចកើតមានជំងឺអុតជាលើកទីពីរទេ ។ វីរុសចំលងពីជ្រូកមួយទៅជ្រូកមួយ ជាទូទៅគឺតាមរយៈរុយ និង ចៃ ។ រយៈពេលសម្ងំនៃមេរោគក្រោយការឆ្លងជំងឺតាមរយៈមុខរបួសនៅលើស្បែក គឺពី ៣-៦ថ្ងៃ ។ វីរុសអាចចំលងតាមរយៈទឹកមាត់ និង ទឹកភ្នែក ចូលទៅប្រមូលផ្តុំនៅបំពង់ក និង បំពង់ខ្យល់ ហើយជ្រាបចូលទៅក្នុងឈាម ។ រយៈពេលសម្ងំនៃវីរុសចាប់ពីពេលឆ្លងជំងឺទៅដល់ពេលលេចចេញរោគសញ្ញាជាលើកដំបូងគឺប្រហែល ១៦ថ្ងៃ ។

រោគសញ្ញា :

ជំងឺចាប់ផ្តើមដោយការឡើងកំដៅ និង មិនស៊ីចំណី រួចហើយមានកន្ទួលក្រហម រាងមូលមិនស្មើ ទំហំ ១-៣ស.ម លេចចេញជាដំបូងនៅលើស្បែកពោះ ចង្កេះ ខ្នង ត្រចៀក ចុងច្រមុះ និង នៅចន្លោះជើងខាងក្នុង ។ ២-៣ថ្ងៃ ក្រោយមក កន្ទួលក្រហមនេះក៏ក្លាយទៅជាពងដោររួចហើយក្រៀមក្លាយជាក្រមរ ដែលមានពណ៌ក្រមៅ និង ខ្មៅ ស្អិតជាប់នឹងស្បែក ក្នុងរយៈពេលពី ២-៤ អាទិត្យ ក្រមរក៏រង្គោះ ដោយមិនបន្សល់ទុកនូវស្នាកស្នាមអ្វីទេ ។ វីរុសអាចរស់ក្នុងក្រមរស្បែកជាច្រើនខែ ។ ជំងឺនេះមិនបណ្តាលឱ្យជ្រូកងាប់ទេ ប៉ុន្តែអាចបង្កឱ្យមានការខាតបង់ដ៏ធ្ងន់ធ្ងរ ប្រសិនបើវាកើតនៅលើកូនជ្រូក ព្រោះវាបណ្តាលឱ្យមានការថយចុះនៃការកើនទំងន់ តម្រូវឱ្យយើងបន្ថាយពេលចិញ្ចឹមអស់រាប់អាទិត្យទៀត ។

ជំងឺនេះច្រើនកើតមាននៅលើកូនជ្រូកអាយុ ៤-៦អាទិត្យ បណ្តាលឱ្យជ្រូកមិនស៊ីចំណី បាក់កំលាំង ជួនកាលបណ្តាលឱ្យជ្រូកងាប់ ។

ពេលអុតឡើងពង ស្បែកហើម ពិបាកទ្រាំ ជួនកាលនៅលើស្បែកមានចេញឈាម ។ កន្លែងដែលមានពងអុត រុយ និង ចៃគោងច្បាមនៅទីនោះ ហើយនាំនាំជំងឺទៅកាន់កន្លែងដទៃទៀត ។ ជំងឺនេះអាចចំលងពីកសិដ្ឋានមួយទៅកសិដ្ឋានមួយទៀតដែលមានគំលាត ១៥០០ម ។

ជ្រូកឈឺអាចឡើងកំដៅ ៤០-៤០,៥°C ។ ក្នុងសភាពធ្ងន់ នៅច្រមុះ ភ្នែក មាត់ និង បំពង់ក ក៏មានពងអុតដែរ ។ ជំងឺអុតអាចបណ្តាលឱ្យជ្រូកហើមសួត រាគ ហើយអាចងាប់ ។

ការឆ្លងរាលដាលច្រើនបណ្តាលមកពីជ្រូកជាទៅជិតជ្រូកឈឺ ឬក៏តាមរយៈទ្រុង ស្នូកទឹក ស្នូកចំណី ដែលមិនបានធ្វើអនាម័យសំលាប់មេរោគ ។

ជំងឺនេះច្រើនកើតមាននៅរដូវក្តៅ ( សំបូររុយ ) ហើយបន្តរហូតដល់រដូវភ្លៀងទើបបញ្ចប់ ។

រោគសញ្ញាប្រៀបធៀប :

មានរបៀបពិនិត្យស្រាវជ្រាវច្រើនបែប ប៉ុន្តែពងអុត និង ក្រមរពណ៌ក្រមៅ ខ្មៅ នៅលើស្បែក ជារោគសញ្ញាគ្រប់គ្រាន់ល្មមឱ្យយើងកំណត់បានថាជាជំងឺអុត ។ ប៉ុន្តែសូមចំណាំថា ពងអុតអត់មានកើតនៅលើជើងទេក្នុងករណីមានពងនៅលើច្រមុះ មាត់ អណ្តាត និង នៅលើជើងនោះអាចជារោគសញ្ញានៃជំងឺអុតក្តាមជ្រូក ប៉ុន្តែជំងឺអុតក្តាមមិនមានពងនៅលើខ្លួនទេ ។

វិធីការពារ :

មធ្យោបាយប្រសើរបំផុត ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺនេះ គឺត្រូវសំលាប់ជ្រូកដែលកើតជំងឺនេះចោល ។

គ្មានថ្នាំការពារជំងឺអុតជ្រូកទេ ។ ថ្នាំបណ្តុះអុតមនុស្សមិនមានប្រសិទ្ធិភាពទៅលើសត្វជ្រូកទេ ។

ការព្យាបាល :

គ្មានថ្នាំមានប្រសិទ្ធិភាពព្យាបាលជំងឺអុតទេ ជ្រូកដែលកើតអុតក្នុង

កំរិតស្រាលមិនបណ្ដាលឱ្យងាប់ទេ បញ្ហាសំខាន់គឺត្រូវរក្សាអនាម័យក្នុងការចិញ្ចឹម ។

យើងអាចចាក់វីតាមីន C និង លាយថ្នាំ Térramycine ឬក៏ Auréomycine ក្នុងចំណី ដើម្បីឱ្យជ្រូកឆាប់ជា ។

## ជំងឺឆ្កួតក្លែងក្លាយ

**La maladie d'Aujeszky**
**Aujeszky's disease ( Pseudorabies )**

ជំងឺឆ្កួតក្លែងក្លាយ ជាជំងឺដែលបង្កឡើងដោយវីរុស ( Herpes virus ) ។ សត្វគោ សត្វឆ្កែ និង សត្វឆ្មា សុទ្ធតែជាសត្វដែលអាចកើតមានជំងឺនេះ ។ ជំងឺនេះបង្កគ្រោះថ្នាក់ធ្ងន់នៅលើកូនជ្រូក ជាងជ្រូកធំ ។ គេចាត់ទុកថាសត្វជ្រូកជាប្រភពនៃការចំលងមេរោគទៅសត្វដទៃ ។

រោគសញ្ញា :

ជំងឺនេះកើតមានពាសពេញពិភពលោក បណ្ដាលឱ្យកូនជ្រូកដែលមានជំងឺនេះងាប់ស្ទើរតែ ១០០% ចំណែកនៅលើជ្រូកធំ មិនសូវមានជំងឺនេះទេ តែបើមាន នោះវាគ្រាន់តែបណ្ដាលឱ្យងាប់តែមួយ ឬ ពីរក្បាលតែប៉ុណ្ណោះ ។

កូនជ្រូកទើបកើត ដល់អាយុ ៨អាទិត្យ :

រោគសញ្ញាលេចចេញក្រោយពេលដែលវីរុសចូលទៅក្នុងខ្លួនពី ៣-៧ថ្ងៃ បណ្ដាលឱ្យកូនជ្រូក ក្អួត រាគ ញ័រញាក់ អង្គុយដូចឆ្កែ កន្ត្រាក់ខ្លួន រួចហើយងាប់ដោយបាក់កំលាំង ក្នុងរយៈពេល ១២ម៉ោងក្រោយមក ។ កំដៅខ្លួនមិនលើសពី ៤១,៥°C ទេ ។

កូនជ្រូកអាយុ ៨អាទិត្យ ដល់ អាយុ ៥ខែ :

រយៈពេលសម្ងំនៃវីរុសគឺ ៥-៧ថ្ងៃ ។ ជ្រូកឡើងកំដៅពី ៤០,៦-៤១,៧°C បន្តរហូតពី ៤-៨ថ្ងៃ ជ្រូកមិនស៊ីចំណី ជួនកាលក្អួត ញ័រញាក់ ប្រកាច់ ហេវហត់ បាក់កំលាំង រួចហើយងាប់ ។

ជ្រូកធំ :

នៅលើជ្រូកធំ គេមិនសូវឃើញមានរោគសញ្ញានៅខាងក្រៅទេ គេឃើញតែជ្រូកមិនសូវស៊ីចំណី ក្អក ហៀរទឹកមាត់ ដង្ហក់ ទល់លាមក ហើយ ៤-៥ថ្ងៃ ក្រោយមក ក៏ជាទៅវិញ ។

មានករណីតិចតួច វីរុសធ្វើទុក្ខសរសៃប្រសាទ បណ្ដាលឱ្យជ្រូកងាប់ ២% ។ ៥០% នៃមេជ្រូកជើម រលូតកូន ឬក៏កើតកូនមុនពេលកំណត់ ។ នៅលើគោ ឆ្កែ និង ឆ្មា ក្រៅពីរោគសញ្ញាសរសៃប្រសាទ គឺសត្វដែលមានជំងឺនេះ រមាស់ អេះ រហូតដល់រលាត់ស្បែក ។ ពេលដែលមេរោគឆ្លងចូលតាមកន្លែងរបួសនៅលើស្បែក វាធ្វើដំណើរយ៉ាងលឿនសំដៅខួរក្បាលតាមសរសៃប្រសាទ ហេតុនេះបានជាពេលចាប់ផ្ដើមពីដំបូងបណ្ដាលឱ្យសត្វរមាស់ រួចហើយរលាកខួរ ។

### ការឆ្លងចំលងជំងឺ :

ជំងឺនេះច្រើនកើតមាននៅកន្លែងចិញ្ចឹមតូច ចង្អៀត ។ ឆ្លងផ្ទាល់តាមរយៈទឹកសំបោរនៅច្រមុះជ្រូកឈឺទៅជ្រូកជា ហើយអាចចំលងជាប្រយោលតាមរយៈខោអាវ ដី ភក់ជ្រាំ តាមរយៈសត្វព្រាប សត្វចាប កណ្តុរ ឆ្មា សត្វចៀម សត្វគោ ។ ល ។

ការឆ្លងរាលដាលពីកសិដ្ឋានចិញ្ចឹមជ្រូកមួយ ទៅកសិដ្ឋានចិញ្ចឹមជ្រូកមួយទៀតតាមរបៀបយ៉ាងណានោះ គេមិនទាន់កំណត់បានច្បាស់លាស់ទេ អ្នកខ្លះមានយោបល់ថាសត្វកណ្តុរជាភ្នាក់ងារចំលងជំងឺពីកន្លែងមួយទៅកន្លែងមួយទៀត ប៉ុន្តែកំណត់សំគាល់នេះក៏មិនមានមូលដ្ឋានរឹងមាំដែរ ។

ជំងឺផ្លូតក្លែងក្លាយ អាចឆ្លងមកពីសត្វគោ ហើយសត្វគោក៏អាចឆ្លងជំងឺនេះពីសត្វជ្រូក ។ ដូច្នេះមិនត្រូវចងគោក្បែរទ្រុងជ្រូក ដែលមានជំងឺនេះទេ ។

### រោគវិនិច្ឆ័យ :

រលូតកូន ងាប់ដោយសារកើតមុនពេលកំណត់ ញ័រក្បាល វក់វីក្អក សោះ អង្គើយ មមីងមមាំង ជារោគសញ្ញាបញ្ជាក់ឱ្យយើងដឹងថាជាជំងឺផ្លូតក្លែងក្លាយនេះឯង។

### ការព្យាបាល :

ប្រើសេរ៉ូមដែលយកពីជ្រូកឈឺជំងឺនេះមកព្យាបាល ប៉ុន្តែវាមានប្រសិទ្ធិភាពល្អ តែនៅពេលណាដែលយើងព្យាបាលវាបានទាន់ពេលវេលា

ពេលដែលជំងឺនេះទើបនឹងចាប់ផ្ដើមតែប៉ុណ្ណោះ ។ នៅសហរដ្ឋអាមេរិក គេមិនប្រើវិធីព្យាបាលទេ ព្រោះថាគ្មានថ្នាំណាមានប្រសិទ្ធិភាពទៅលើជំងឺនេះ គេគ្រាន់តែយកជ្រូកឈឺចេញ ដាក់ឱ្យឆ្ងាយពីជ្រូកជាតែប៉ុណ្ណោះ ដើម្បីកុំឱ្យឆ្លងទៅជ្រូកដទៃទៀត ។

## ជំងឺអុតក្ដាម

**La fièvre aphteuse**
**Foot and Mouth Disease ( FMD )**

ជំងឺអុតក្ដាម ជាជំងឺឆ្លងនៃពពួកសត្វដែលមានក្រចកជើងពីរ ទាំងសត្វស្រុក ទាំងសត្វព្រៃ ។ សត្វគោ ក្របី ជ្រូក ចៀម ពពែ ច្រើនកើតជំងឺនេះ ។ ជំងឺឆ្លងរាលដាលរហ័សពីខេត្តមួយទៅខេត្តមួយ ហើយក្នុងរយៈពេលតែ ៣-៤ខែ កើតពាសពេញតំបន់តែម្ដង ។ សត្វសេះ និង សត្វឆ្កែ មិនឆ្លងជំងឺនេះទេ ។ ជំងឺនេះបញ្ជាក់ដោយមានដំបៅនៅក្នុងមាត់ ( អណ្ដាត ក្រអូមមាត់ បបូរមាត់ ) និង នៅលើស្បែក ពិសេសនៅចុងច្រមុះ ចុងជើង និង នៅលើដោះ ។

គេចែកជំងឺអុតក្ដាមជា ៧ប្រភេទ

- ប្រភេទ O, A, C មានពាសពេញពិភពលោក
- ប្រភេទ SAT1, SAT2, SAT3 មានតែនៅទ្វីបអាហ្វ្រិកទេ

- ប្រភេទ ASIA1 នៅទ្វីបអាស៊ី ( ឥណ្ឌា ប៉ាគីស្ថាន ហុងកុង ថៃឡង់ដ៍ កម្ពុជា )

ការឆ្លងរាលដាល :

ជំងឺអុតក្តាមឆ្លងរាលដាលរហ័សណាស់ ការឆ្លងរាលដាលនៃជំងឺនេះអាចបណ្តាលមកពី :- ឆ្លងផ្ទាល់ពីសត្វឈឺទៅសត្វជា ឆ្លងជាប្រយោលដោយការដឹកជញ្ជូនសត្វ ។ មនុស្ស និង សត្វដើរឆ្លងកាត់ចុះឡើងពាំវីរុសពីកន្លែងមានជំងឺ ទៅកន្លែងមិនទាន់មានជំងឺ ។ នៅក្នុងសាច់សត្វស្រស់ សាច់ប្រឡាក់ និង សាច់ក្លាសេ ក្នុងម៉ាស៊ីនត្រជាក់ ក៏នៅតែអាចផ្ទុកវីរុសនេះបានយូរថ្ងៃ ។

រោគសញ្ញា :

ជំងឺស្តែងចេញដោយមានពងដោរ ទំហំប៉ុនចុងចង្កឹះនៅក្នុងក្រអូមមាត់ លើអណ្តាត លើបបូរមាត់ និង នៅបំពង់ក បណ្តាលឱ្យជ្រូកហៀរទឹកមាត់កក្លាក់ ។ ពងដោរនេះអាចមាននៅលើចង្អៀកជើង និង នៅលើក្បាលដោះ ។ ជារឿយៗគេឃើញមាននៅចុងច្រមុះ ជួនកាលក៏មាននៅក្នុងរន្ធច្រមុះទៀតផង ហើយក៏អាចកើតមានផងដែរក្នុងករណីតិចតួចនៅកន្លែងដទៃទៀត ដូចជានៅលើប្រដាប់បន្តពូជរបស់មេជ្រូកជាដើម ។

ពងដោរនេះក្រោយមកប៉ុន្មានម៉ោងក៏រាបទៅវិញ ក្លាយជាដំបៅរាងមូល ដំបៅស៊ីជ្រៅទៅក្នុងក្រចកជើង បណ្តាលឱ្យរលុងក្រចក ជួនបណ្តាលឱ្យជ្រុះក្រចក ហើយជួនកាលមានខ្ទុះ ។ ក្នុងសភាពជំងឺស្រាល

គេមិនឃើញក្រចករលុងទេ រោគសញ្ញាដែលគេឃើញនោះ គឺមិនស្មូវស៊ីចំណី ក្តៅខ្លួន ហើយដើរបាំងខ្វើច ព្រោះឈឺជើង ។

ជំងឺនេះ មិនបណ្តាលឱ្យមានមហន្តរាយខ្លាំងដូចជំងឺដទៃទៀតទេ អត្រាងាប់អាចមានត្រឹម ៣-៥% តែប៉ុណ្ណោះ ប៉ុន្តែជំងឺអាចនឹងបន្ទាយពេលយូរ ប៉ះពាល់ដល់បញ្ហាសេដ្ឋកិច្ច ចំពោះជ្រូកសាច់គឺចុះទំងន់ ហើយចំពោះជ្រូកមេគឺអត់ទឹកដោះ ឬក៏មានដែរ តែមិនឱ្យកូនបៅព្រោះឈឺដោះ កូនជ្រូកចុះស្គម មេធើមរលូតកូន ។

កូនជ្រូកក៏អាចកើតជំងឺអុតក្តាមដែរ ហើយអត្រាងាប់មានរហូតដល់ ៥០% ។ គោ ក្របី ដែលកើតជំងឺនេះ មិនអាចភ្ជួររាស់កើត ។

ប្រយ័ត្នច្រឡំជំងឺនេះនឹងជំងឺរលាកបំពង់ក មានពងដោរ ។

**វិធីការពារ និង ព្យាបាល :**

មធ្យោបាយប្រសើបំផុត-

គឺកាលណាជំងឺនេះកើតមាននៅតំបន់ណា ត្រូវសំលាប់សត្វដែលមានជំងឺនេះទាំងអស់ ( Stamping Out ) នេះជាវិធានការការពារដ៏មានប្រសិទ្ធិភាពបំផុត ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺ ។ គេមិនប្រើវិធីព្យាបាល ព្រោះគ្មានថ្នាំព្យាបាលជំងឺនេះទេ ។

**របៀបសំលាប់មេរោគ ( Stamping Out method ) :**

- ត្រូវសំលាប់សត្វដែលកើតជំងឺនេះ រួចហើយដុតក្នុងឡកាន់តែរហ័ស កាន់តែប្រសើរ ។

- ត្រូវធ្វើអនាម័យកន្លែងដែលមានជំងឺ ( ដុតចោលចំពោះវត្ថុណាដែលមានតម្លៃថោក ) ។

**ចាក់ថ្នាំការពារ :**

ចាក់ថ្នាំការពារជំងឺអុតក្តាមនៅលើសត្វជ្រូកមិនសូវមានប្រសិទ្ធិភាព ដូចចាក់ការពារឱ្យសត្វគោ ក្របីទេ ។

## ជំងឺរលាកសួតបណ្តាលមកពីវីរុស

**La pneumonie à virus du porc**

**Virus pneumonia of pig ( V.P.P )**

ជំងឺរលាកសួតបណ្តាលមកពីវីរុស កើតមានគ្រប់ទីសទីក្នុងពិភពលោក ។ គេបានរកឃើញជំងឺនេះតាំងពីយូរយារមកហើយ ប៉ុន្តែគេដាក់ឈ្មោះជំងឺនេះផ្សេងៗគ្នា លុះមកដល់ឆ្នាំ ១៩៥២ ទើបគេឯកភាពដាក់ឈ្មោះជំងឺនេះថា ជំងឺរលាកសួតបណ្តាលមកពីវីរុស របស់ជ្រូក ឬហៅកាត់ថា V.P.P ( Betts ១៩៥២ ) ។

**រោគសញ្ញា :**

ជំងឺនេះច្រើនកើតនៅលើកូនជ្រូក បណ្តាលឱ្យមានជំងឺក្អកស្ងួត ក្រជំ និង ក្រងាប់ ជួនកាលគេក៏ឃើញមានជំងឺរាគនៅក្បែរជាមួយ ។ សម្លេង

ក្អកស្ងួតរបស់ជ្រូកមានជំងឺរលាកសួតបណ្ដាលមកពីវីរុស មានលក្ខណៈពិសេសត្រង់ថានៅពេលព្រឹក ពេលដែលជ្រូកដើរទៅស៊ីចំណី គឺដើរបណ្ដើរក្អកបណ្ដើរ រយៈពេលក្អកមានពី ១-៣អាទិត្យ ឬជូនកាលក្អកមួយជីវិតរបស់វា ។ ជ្រូកឈឺមិនសូវស៊ីចំណី ក្រធំ ដង្ហើមធម្មតា ... ។

ជំងឺនេះកើតមានគ្រប់រដូវកាល ឆ្លងពីជ្រូកមួយទៅជ្រូកមួយ តាមការរស់នៅ ស៊ីផឹករួមគ្នា ។

គេអាចច្រឡំជំងឺនេះទៅនឹងជំងឺផ្ដាសាយជ្រូក ប៉ុន្តែជំងឺផ្ដាសាយជ្រូកកើតមានតែនៅរដូវភ្លៀង ចំណែកជំងឺរលាកសួតបណ្ដាលមកពីវីរុសកើតមាននៅគ្រប់រដូវ ។ ជំងឺផ្ដាសាយជ្រូកអាចនឹងជាយ៉ាងឆាប់ ហើយធំធាត់ជាធម្មតា ចំណែកជ្រូកមានជំងឺរលាកសួតបណ្ដាលមកពីវីរុស ចិញ្ចឹមក្រធំ ។ នៅឯមន្ទីរពិសោធន៍ គេអាចបញ្ជាក់ពីជំងឺទាំងពីរនេះបាន ដោយការបណ្ដុះវីរុសទៅលើសត្វកណ្ដុរ និង ទៅលើស៊ុតមាន់ដែលមានកំណើត (œuf de poule embryonné ) ។

ការទិញជ្រូកថ្មីបញ្ចូលក្នុងហ្វូងចាស់ មិនសូវបង្កឱ្យមានជំងឺផ្ដាសាយទេ ចំណែកឯជំងឺរលាកសួតបណ្ដាលមកពីវីរុស ជារឿយៗគឺជាលទ្ធផលនៃការទិញជ្រូក ថ្មីបញ្ចូលក្នុងហ្វូងចាស់ ។

ជំងឺផ្លូវដង្ហើមរ៉ាំរ៉ៃ យូរខែ ឆ្នាំ គឺបង្កឡើងដោយវីរុសនៃជំងឺរលាកសួត មិនមែនជាលទ្ធផលបង្កឡើងដោយវីរុសផ្ដាសាយទេ ។

**ការព្យាបាល :**

ជំងឺរលាកសួតបណ្ដាលមកពីវីរុស មិនទទួលការព្យាបាលពីពពួក

ថ្នាំអង់ទីប៊ីយ៉ូទិក និង ពពួកស៊ុលហ្វាមីដទេ ។

បញ្ហាសំខាន់គឺត្រូវចិញ្ចឹមជ្រូកក្នុងលក្ខណៈអនាម័យល្អ ទ្រុងជានិច្ច-កាល ស្ងួត កក់ក្តៅ មានខ្យល់អាកាសចេញចូល ។

ត្រូវបញ្ចុះព្រូនជ្រូកតាមកម្មវិធី បង្ការកុំឱ្យមានព្រូនធ្វើដំណើរចូលទៅក្នុងសួត ដែលអាចបណ្តាលឱ្យមានរបួសបន្ថែមទៅលើសួត ។

## ជំងឺរលាកពោះវៀន

**La gastro entérite**
**Infectieuse du porcelet**
**Transmissible gastroenteritis**
**( TGE )**

---

ជំងឺរលាកពោះវៀន ជាជំងឺឆ្លងបង្កជាមហន្តរាយធំធេងទៅលើកូនជ្រូកអាយុក្រោម ១០ថ្ងៃ ។ ជំងឺនេះអាចកើតមាននៅលើជ្រូកគ្រប់អាយុ ប៉ុន្តែគ្រោះថ្នាក់ធ្ងន់បំផុត គឺនៅលើកូនជ្រូក ។

Doyle និង Hutchings ( ១៩៤៦ ) ជនជាតិអាមេរិក ជាអ្នករកឃើញជំងឺនេះមុនគេ ។ មកទល់បច្ចុប្បន្ននេះ គេគិតថាជំងឺរលាកពោះវៀនជាមូលហេតុដ៏សំខាន់មួយ ដែលបណ្តាលឱ្យកូនជ្រូកងាប់។

ជំងឺនេះកើតមានគ្រប់រដូវកាលក្នុងឆ្នាំ ប៉ុន្តែប្រមូលផ្តុំខ្លាំងនៅពេលដែលមេជ្រូកកើតកូននៅរដូវក្តៅ ។

មូលហេតុ :

ជំងឺរលាកពោះវៀន បង្កឡើងដោយវីរុសមួយប្រភេទ ។ មកទល់ពេលនេះគេដឹងថា វីរុសនេះបង្កឱ្យមានជំងឺតែនៅលើសត្វជ្រូកតែប៉ុណ្ណោះ។ ក្នុងកំដៅធម្មតា អាចសំលាប់វីរុសនេះបានយ៉ាងងាយ ។

រោគសញ្ញា :

រយៈពេលសម្ងំរបស់វីរុស គឺពី ១២-១៨ម៉ោង ។ ជ្រូកធំមានរោគសញ្ញាស្រាលជាងជ្រូកតូច ។ កូនជ្រូកដែលបៅដោះ ពេលមានជំងឺនេះខ្លះគ្មានបង្ហាញរោគសញ្ញាអ្វីទេ តែខ្លះទៀតមិនស៊ីចំណី ក្អួត និង រាគរូសយ៉ាងខ្លាំង ។ ចំណែកមេជ្រូកដែលមានជំងឺនេះ គ្មានទឹកដោះ ចុះទំងន់ ប៉ុន្តែមានករណីតិចណាស់ដែលបណ្តាលឱ្យមេជ្រូកងាប់ ។ ចំពោះជ្រូកសាច់ គឺបណ្តាលឱ្យចុះទំងន់ ហើយ ៥-៧ថ្ងៃ ក្រោយមកក៏ជាទៅវិញ ។ ចំណែកកូនជ្រូកដែលមានជំងឺ មានរោគសញ្ញារាគរូសជាប្រចាំ ក្អួត ហើយផឹកទឹកច្រើន លាមកពណ៌ស ជួនពណ៌បៃតងស្លឹកឈើ ។ ទឹកដោះដែលបៅចូលទៅក្នុងពោះវៀនមិនរំលាយ បានជាក្នុងលាមក និង ក្នុងកំអួតមានទឹកដោះ ។ កូនជ្រូកចុះទំងន់ ហើយស្រេកទឹកជាខ្លាំង យើងអាចពិនិត្យឃើញកូនជ្រូកឈឺនៅតែក្បែរស្នូកទឹក កូនជ្រូកអាចងាប់ក្នុងរយៈពេលមួយអាទិត្យបន្ទាប់ពីមានរោគសញ្ញាជាលើកដំបូង ។ ក៏មានករណីខ្លះកូនជ្រូកដែលឈឺជំងឺនេះអាចងាប់ ក្នុងរយៈពេលមិនដល់ ៤៨ម៉ោង ។ អត្រាងាប់

អាចមានដល់ ១០០% ចំពោះកូនជ្រូកអាយុក្រោមមួយអាទិត្យ កូនជ្រូកដែលមិនងាប់ ចិញ្ចឹមក្រធំ ដូច្នេះគួរយកកូនជ្រូកប្រភេទនេះចេញ ។

ស្លាកស្នាម :

កូនជ្រូកដែលឈឺជំងឺនេះយូរថ្ងៃ ក្នុងក្រពះទទេស្អាត ចំណែកកូនជ្រូកដែលឈឺភ្លាមងាប់ភ្លាមក្នុងក្រពះពេញដោយទឹកដោះ ។ ប្រដាប់រំលាយអាហារមានស្នាមដំបៅ ។

រោគវិនិច្ឆ័យ :

និមិត្តសញ្ញានៃជំងឺរលាកពោះវៀន អាចនឹងសំគាល់បានដោយសារ :-

- ឆ្លងរាលដាលរហ័ស

- អត្រាងាប់ខ្ពស់

ចំណែកនៅលើជ្រូកធំ ក៏មានរោគសញ្ញាដូចគ្នានេះដែរ តែ ២-៧ថ្ងៃ ក្រោយមកក៏ជាទៅវិញ ។ គួរកត់សំគាល់ថា ក្អួត និង រាគ ជារោគសញ្ញាងាយឱ្យយើងច្រឡំនឹងជំងឺដទៃទៀត ដូចជាជំងឺប៉េស្ត និង ការពុលចំណី ។ ប៉ុន្តែគប្បីចាំថា ជំងឺរលាកពោះវៀន បញ្ជាក់ដោយការឆ្លងរាលដាលរហ័ស ហើយការឆ្លងរាលដាលនេះបណ្តាលមកពីប៉ះពាល់ផ្ទាល់នឹងសត្វឈឺ និង ការស៊ីដោយចំណីដែលមានមេរោគនេះ ។

ការព្យាបាល :

មិនទាន់មានថ្នាំមានប្រសិទ្ធិភាពទៅលើជំងឺនេះទេ ។ រយៈកាលកន្លងមកគេបានសាកល្បងប្រើថ្នាំច្រើនប្រភេទ ដើម្បីព្យាបាលជំងឺនេះ ប៉ុន្តែ

មិនបានទទួលលទ្ធផលគាប់ប្រសើរទេ មានថ្នាំមួយចំនួនដូចជា Auréomycine និង Terramycine ដែលគេយកមកព្យាបាលកូនជ្រូកនោះ គ្រាន់តែអាចពន្យាថ្ងៃងាប់តែប៉ុណ្ណោះ ហើយប្រសិទ្ធិភាពរបស់វានៅលើជ្រូកធំក៏មិនប្រាកដដែរ ព្រោះថាទោះជាមិនព្យាបាល ក៏វាជាដោយឯកឯងដែរ ។

## ជំងឺរលាកបំពង់ក មានពងដោរ

**La stomatite vésiculeuse**
**Vesicular stomatitis**

គេបានរកឃើញជំងឺរលាកបំពង់កមានពងដោរ ជាលើកដំបូងនៅលើសត្វសេះ ក្រោយមកនៅលើសត្វគោ និង សត្វជ្រូក មនុស្ស និង សត្វព្រៃក៏មានជំងឺនេះដែរ ។ នៅសហរដ្ឋអាមេរិកគេហៅជំងឺនេះថា ឈឺច្រមុះ ( Sore nose ) ឬ ឈឺមាត់ ( Sore mouth ) ។

ជំងឺរលាកបំពង់កមានពងដោរ បង្កឡើងដោយសារវីរុសរាតត្បាតទៅលើភ្នាសស្លេងនៅក្នុងមាត់ នៅលើស្បែកជុំវិញក្រចកជើងសេះ គោ ជ្រូក ឈ្លូស ប្រើស ។

រោគសញ្ញា :

ជ្រូកឈឺគឺដោយសារស៊ីចំណីមានវីរុសនេះ ។ រោគសញ្ញាជាដំបូងគឺ កំដៅខ្លួនឡើងក្នុងរយៈពេលពី ២៤-៤៨ម៉ោង កំដៅឡើងពី ៤០-៤១°C

ជូនកាលឡើងដល់ ៤២°C ។ ក្នុងរយៈពេលពី ៤៨-៧២ម៉ោង នៅលើអណ្តាតមានពងដោរ ទំហំ ២-៣ ស.ម ។ ជ្រូកហៀរទឹកមាត់ រួចហើយកំដៅចុះមកធម្មតាវិញ ជ្រូកចាប់ស៊ីចំណីឡើងវិញ ប៉ុន្តែស៊ីមិនច្បាញ់ ព្រោះឈឺមាត់ ឈឺអណ្តាត ដំណើរក៏មិនធម្មតា ព្រោះឈឺជើង ជ្រូកឈឺអាចក្អកជំងឺបន្ទាយពេលប្រហែលពីរអាទិត្យ ហើយមិនក្លាយជាជំងឺអ្វីផ្សេងទៀតទេ សត្វឈឺអាចវិលមករកសភាពធម្មតាវិញ ហើយស្នាកស្នាមក៏ជាទៅវិញដែរ។

ប្រយ័ត្នច្រឡំជំងឺនេះនឹងជំងឺអុតក្តាម ព្រោះថាជំងឺទាំងពីរនេះសុទ្ធតែមានពងដោរនៅច្រមុះ និង អណ្តាត ដូចគ្នា ។

ការព្យាបាល :

គ្មានថ្នាំព្យាបាលមានប្រសិទ្ធិភាពចំពោះជំងឺនេះទេ យើងអាចលាងស្នាមរបួសនឹងទឹកថ្នាំសំលាប់មេរោគដូចជា Acide borique, borate de soude និង Streptomycine ដើម្បីឱ្យស្នាមរបួសនៅមាត់ និង នៅលើអណ្តាតឆាប់ជា ។

ក្នុងរយៈពេលពី ១០-១៥ថ្ងៃ ជ្រូកជាពីជំងឺ ហើយត្រឡប់មករកសភាពធម្មតាវិញក្នុងរយៈពេល ៤-៥អាទិត្យ ។ ហើយ ២-៣ខែក្រោយមកជ្រូកធំធាត់ឡើងវិញ មានភាពស៊ាំនឹងជំងឺដែលមិនអាចបណ្តាលឱ្យជ្រូកឈឺជំងឺនេះជាលើកទីពីរទេ ។ ចំពោះគោ ភាពស៊ាំនឹងជំងឺនេះអាចមានរហូតដល់ ៧ឆ្នាំ ។

# ជំងឺបង្កឡើងដោយបាក់តេរី

## Maladies bactériennes
## Bacterial diseases

## ជំងឺឈាមខ្មៅ

### Charbon bactéridien
### Anthrax

ជំងឺឈាមខ្មៅ ជាជំងឺធ្ងន់ដែលតែងតែកើតមាននៅតំបន់ណាដែលធ្លាប់មានការរាតត្បាតនៃជំងឺនេះ ។ ជំងឺនេះបង្កឡើងដោយមេរោគ Bactéridie charbonneuse de Davaine ( Bacillus Anthracis ) ។ ជំងឺឈាមខ្មៅ កើតមាននៅលើសត្វគោ ក្របី ជ្រូក ចៀម ពពែ សេះ និង មនុស្ស ទាំងសត្វចិញ្ចឹមក្នុងទ្រុង ទាំងសត្វដែលលែងឱ្យស៊ីនៅក្រៅវាល សុទ្ធតែអាចកើតមានជំងឺនេះដូចគ្នា ។

មូលហេតុ :

ជំងឺឈាមខ្មៅ កើតឡើងដោយសារការប៉ះពាល់ផ្ទាល់ជាមួយសត្វឈឺ ឬ ក៏ជាមួយផលិតផលនៃសត្វឈឺ ។ សត្វជ្រូកច្រើនជំនះបាននឹងជំងឺនេះ ចំណែកសត្វ ចៀម និង សត្វគោ ក្របី ងាយកើតជំងឺនេះណាស់ ។ មូលហេតុដែលបណ្តាលឱ្យជ្រូកឈឺជំងឺនេះ គឺមកពីយើងឱ្យស៊ីចំណីរោង

ចក្រដែលមានលាយម្សៅឆ្អឹង ឬ ម្សៅ សាច់ ហើយឆ្អឹង និង សាច់ទាំងនោះគឺជាផលិតផលនៃសត្វដែលមានជំងឺឈាមខ្មៅនេះ ។

មេរោគនៃជំងឺនេះ អាចរស់នៅជាយូរឆ្នាំនៅក្នុងដី ក្នុងតំបន់ដែលធ្លាប់មានជំងឺនេះ ។ ជ្រូកដែលយើងលែងឱ្យដើររកស៊ីក្នុងតំបន់នេះ អាចឆ្លងជំងឺតាមរយៈកន្លែងរបួសនៅលើស្បែក និង នៅចុងច្រមុះ ។ មូសខាំជ្រូកឈឺ រួចហើយខាំជ្រូកជា ក៏អាចចំលងជំងឺបានដែរ ។

កាលណាយើងកប់សាកសពសត្វដែលងាប់ដោយជំងឺនេះមិនបានត្រឹមត្រូវទេ មេរោគនេះអាចរស់នៅយូរឆ្នាំ ហើយបង្កជាមហន្តរាយដល់សត្វដែលរកស៊ីនៅតំបន់នេះ ។

ត្រូវកប់សាកសពសត្វងាប់ដោយជំងឺនេះក្នុងជំរៅយ៉ាងតិច១.៥០ម ហើយបាចកំបោរឱ្យបានច្រើនផង ។

ឈាម និង ផ្នែកដទៃទៀតនៃសត្វដែលមានជំងឺនេះសុទ្ធតែមានមេរោគ ។ បើយើងកំណត់ច្បាស់ថាជាជំងឺឈាមខ្មៅហើយ នោះមិនត្រូវវះពិនិត្យទេ ព្រោះ :-

- អាចបណ្តាលឱ្យឈាមហូរធ្លាក់ចុះទៅក្នុងដី ដែលជាការលំបាកក្នុងការធ្វើអនាម័យ ។
- ឆ្កែ ជ្រូក មាន់ មកស៊ីសាកសព ជ្រូក អាចបណ្តាលឱ្យឆ្លងជំងឺ ។
- រុយទំសត្វជ្រូកងាប់ អាចចំលងជំងឺទៅសត្វជា ។
- ភ្នាក់ងារបសុពេទ្យ បើគ្មានស្រោមដៃទេ មិនត្រូវវះពិនិត្យសត្វងាប់ទេ ។

ព្រោះអាចឆ្លងមេរោគតាមរយៈមុខរបួសនៅដៃ. ជើង ។

**រោគសញ្ញា :**

ជំងឺកើតឡើងយ៉ាងរហ័ស តែក្នុងប៉ុន្មានម៉ោងអាចឱ្យជ្រូកងាប់ដោយយើងមិនអាចធ្វើអន្តរាគមន៍ទាន់ ។

- ហើមកូនកណ្តុរនៅក ភ្លៅ ក្រលៀន ។

- កាលណាយើងយកម្រាមដៃសង្កត់កន្លែងហើម ស្បែកកន្លែងនោះទ្រុឌ ហើយទុកស្នាកស្នាម ។

- ពិបាកដកដង្ហើម កន្លែងស្បែកស្តើងកកឈាម ជាំ ។

- ហៀរសំបោរ មានលាយឈាម ។

- ក្នុងទឹកនោម និង លាមក មានឈាមស្រស់ ។

**រោគសញ្ញាប្រៀបធៀប :**

រោគសញ្ញាហើមក អាចឱ្យយើងច្រឡំនឹងជំងឺសារទឹក ។ រោគសញ្ញាពក ហើម និង មានចេញឈាម អាចឱ្យយើងច្រឡំនឹងជំងឺកព្រិល ។ ជាមួយនឹងរោគសញ្ញារាគ អាចឱ្យយើងច្រឡំនឹងជំងឺប៉េស្ត ។

ត្រូវយកផាល ( Rate ) និង ឈាមជ្រូកឈឺដោយប្រុងប្រយ័ត្នជាទីបំផុត ផ្ញើទៅមន្ទីរពិសោធន៍ ដើម្បីបញ្ជាក់ពីជំងឺ ។

**វិធីការពារ :**

កាលណាយើងដឹងថាជ្រូកងាប់ដោយជំងឺឈាមខ្មៅ យើងមិនត្រូវវះសាកសពជ្រូកនោះទេ តែត្រូវយកក្រណាត់ញុករន្ធលាមក រន្ធនោម ច្រមុះមាត់ កុំឱ្យឈាមហូរចេញ ។ ត្រូវធ្វើដោយប្រុងប្រយ័ត្ន រួចហើយនាំយក

ទៅកប់ឱ្យឆ្ងាយពីភូមិ ឆ្ងាយពីវាលស្មៅ ជំរៅ ១.៥០ម ហើយបាចកំបោរពីរស្រទាប់ពីលើ ។ ស្រាស់បន្ទាកន្លែងកប់ កុំឱ្យសត្វដទៃទៀតចូលមកជិតរួចហើយត្រូវសំអាតអនាម័យទ្រុង និង ប្រដាប់ប្រដារប្រើប្រាស់ ដុតចំបើងទ្រាប់បាតទ្រុងចោល ។

នៅកន្លែងដែលធ្លាប់កើតមានជំងឺនេះ រៀងរាល់ឆ្នាំ ត្រូវចាក់ថ្នាំការពារឱ្យជ្រូក ប្រើថ្នាំណាមួយក្នុងចំណោមថ្នាំពីរមុខខាងក្រោមនេះ :-

ក- វ៉ាក់សាំង Ramon Staub ចាក់សើស្បែក ១/៤ cc

ខ- វ៉ាក់សាំង Pasteurien ចាក់សើស្បែក ចាក់ពីរដង ក្នុងគំលាត ៨ថ្ងៃ ចាក់លើកទីមួយ : ១/១៦ cc លើកទីពីរ ១/៨ cc ។

ការព្យាបាល :

បើយើងរហ័សដឹងថាមានជំងឺនេះ ទើបអាចសង្គ្រោះទាន់ បើទុកដល់ពេលមានរោគសញ្ញាហើយ គឺមិនអាចព្យាបាលបានទេ ។

អាចប្រើថ្នាំខាងក្រោមនេះ ដើម្បីព្យាបាល :-

ក- សេរ៉ូមព្យាបាលជំងឺឈាមខ្មៅ បញ្ចូលក្នុងខ្លួនជ្រូកឈឺ ក្នុងមួយថ្ងៃ ១០-៤០ cc ទៅតាមជ្រូកតូច ឬ ធំ ។

ខ- Pénicilline ២០ ០០០ UI ក្នុងទំងន់ជ្រូក ១គក្រ

គ- Streptomycine ២០មក្រ ក្នុងទំងន់ជ្រូក ១គក្រ

ឃ- Terramycine injectable solution ២-៤ cc ក្នុងទំងន់ជ្រូក ៤៥គក្រ ទោះជ្រូកទំងន់ណាក៏ដោយចាក់ម្តងកុំឱ្យលើសពី ១០ cc ។

# ជំងឺបួសខ្យល់

**Charbon symptomatique**
**Blackleg**

---

បួសខ្យល់ ជាជំងឺដ៏កាចសាហាវមួយ បង្កឡើងដោយមេរោគ Clostri-dium Chauvœi ។ ជាជំងឺរបស់សត្វគោ សត្វទំពារអៀងដទៃទៀតិនសូវមានជំងឺនេះទេ ហើយជំងឺនេះកើតមានតិចណាស់នៅលើសត្វជ្រូក ។

**រោគសញ្ញា :**

មេរោគនៃជំងឺបួសខ្យល់ ចូលទៅក្នុងខ្លួនសត្វតាមរយៈផ្លូវរំលាយអាហារ និង តាមរយៈស្នាមរបួស ស្នាមរលាត់ រួចហើយរត់ចូលទៅកាន់កន្លែងសាច់ដុំនៅភ្លៅ និង ស្មា ធ្វើឱ្យកន្លែងនោះមានពកដុំប៉ោង មានពពុះខ្យល់នៅខាងក្នុង ។ ដុំពកកើតឡើងតំណាលគ្នានឹងការឡើងកំដៅខ្លួន ។ កាលណាយើងច្របាច់ដុំពកទាំងនោះ វាមិនបណ្តាលឱ្យឈឺទេ តែឮសូរ " ក្រិបក្រៀប១ " ស្បែកនៅកន្លែងដុំពកនោះស្ងួត ទន់ ហើយរង្គោះរោម ។

- ជ្រូកញ័រញាក់ កំដៅឡើងដល់ ៤១°C កន្ត្រាក់សាច់
- ជ្រូកឈររឹងខ្លួនស្អក ( ដោយសារស្ពឹកស្រពន់សាច់ដុំ ) រហូតដល់ពេលងាប់ ការងាប់នេះគឺបណ្តាលមកពីជាតិពុល ដែលមេរោគនេះបង្កឡើង ។

## វិធីការពារ និង ព្យាបាល :

វ៉ាក់សាំងការពារជំងឺបួសខ្យល់ មានប្រសិទ្ធិភាព ១៨ខែ ចំពោះជ្រូក ។ ជ្រូកឈឺអាចងាប់ក្នុងរយៈពេល ១-២ថ្ងៃ ។

អាចប្រើថ្នាំណាមួយក្នុងចំណោមថ្នាំខាងក្រោមនេះដើម្បីព្យាបាល :

- សេរ៉ូមព្យាបាលជំងឺបួសខ្យល់ ១០-២០ cc ក្នុងជ្រូកមួយក្បាល ចាក់សើរស្បែក ។ ប៉ុន្តែសេរ៉ូមថ្លៃណាស់ បើប្រៀបធៀបនឹងពពួកថ្នាំអង់ទីប៊ីយ៉ូទីកខាងក្រោមនេះ :-

* ចាក់ Pénicilline 20 000UI ក្នុងទំងន់ជ្រូក ១គក្រ
* ចាក់ Streptomycine 20 mg ក្នុងទំងន់ជ្រូក ១គក្រ
* ចាក់ Terramycine injectable solution 2-4cc ក្នុងទំងន់ ជ្រូក ៤៥គក្រ ចាក់ម្តងកុំឱ្យលើសពី ១០ cc ។

# ជំងឺកញ្ជ្រិល
## Rouget du porc
## Swine Erysipelas

---

ជំងឺកញ្ជ្រិលជាជំងឺឆ្លង បង្កឡើងដោយមេរោគ Erysipelothrix Rhusiopathiae ។ ជំងឺនេះកាលណាកើតមាននៅតំបន់ណាមួយហើយ

ក៏ចប់បាត់នៅទីនោះ មិនរាតត្បាតទៅទីដទៃទៀតទេ ។ ជំងឺកញ្រ្ជិល មិនសូវឃើញកើតមាននៅប្រទេសយើងទេ ហើយក៏មិនបង្កឱ្យមានជាគ្រោះថ្នាក់អ្វីធំដុំដែរ ។

មេរោគកញ្រ្ជិល ឆ្លងចូលទៅក្នុងខ្លួនជ្រូក តាមរយៈមុខរបួសលើស្បែក និង ក្នុងពោះវៀន ដោយសារព្រូន ។

រោគសញ្ញា :

ចែកចេញជាបីកំរិត

– កំរិតធ្ងន់ :

រាតត្បាតយ៉ាងរហ័សហើយបណ្តាលឱ្យជ្រូកងាប់ក្នុងរយៈពេល១-២ថ្ងៃ។ ជ្រូកឈឺ ក្តៅខ្លាំង កំដៅអាចឡើងដល់ ៤២°C ញ័រញាក់ ដេកក្រោកមិនរួចដោយសារបាត់កំលាំង ទោះជាខំក្រោកឈរក៏ដើបមិនរួចដែរ ពេលប្រឹងដើប ជើងមុខទាំងពីរលុតជង្គង់ចុះដូចសំពះព្រះ ទោះបីយើងប្រឹងជួយវាឱ្យដើបក៏ដើបមិនរួចដែរ ដង្ហើមដង្ហក់ រលាកសន្លាក់ឆ្អឹង រោគសញ្ញាទាំងនេះអាចនឹងបាត់ទៅវិញជាបណ្តោះអាសន្ន ជ្រូកមួយចំនួនស៊ី ផឹកកើត តែភាគច្រើនក្អួត រាគ ។ ក្នុងកំរិតនេះជ្រូកអាចងាប់មុនមានរោគសញ្ញានៅលើស្បែក ។

– កំរិតមធ្យម :

ជាកំរិតដែលមានរោគសញ្ញានៅលើស្បែក ជ្រូកឈឺ ស្រពាប់ស្រពោន ស៊ីតិច ឬ មិនស៊ី ច្រើនដេកថ្ងូរ ភ្នែកក្រហម ហៀរទឹកភ្នែក ពិបាកដកដង្ហើម ហៀរសំបោរ ២-៣ថ្ងៃក្រោយមកនៅលើខ្នង ពោះ ភ្លៅ

មានស្នាមក្រហមរាងមូលពេងក្រពើ ដំបូងពណ៌ផ្កាឈូក បន្ទាប់មកប្រែជាក្រហមបន្តិចម្តងៗ ហើយពេលជ្រូកងាប់ ស្នាមនេះក៏ក្លាយជាខៀវជាំ ។ ៣-៤ថ្ងៃក្រោយមកស្នាមនេះក្រៀម ហើយក្លាយជាក្រមររបកចុះ ៥-១០ ថ្ងៃទើបក្រមររបកអស់ ដោយបន្សល់ទុកសំលាក ។ ២-៣ខែក្រោយ ទើបកន្លែងនោះដុះរោមវិញ ។

ជំងឺបន្លាយពេល ៣-៥ថ្ងៃ ជ្រូកខ្សោយទៅៗ ហើយកំដៅខ្លួនចុះខ្លាំង ។ ក្នុងកំរិតនេះជ្រូកអាចងាប់ពី ៥០-៦០% ។

– កំរិតស្រាល :

ក្នុងកំរិតនេះ រោគសញ្ញាមិនច្បាស់ដូចកំរិតមធ្យមទេ ជ្រូកឈឺស្រពាប់ស្រពោន ស៊ីតិច ចុះស្គម ហើមគ្រប់សន្លាក់ឆ្អឹង ជ្រូកដើរ បាំងខ្ទើចបាក់កំលាំង ។ ជ្រូកអាចជាឡើងវិញក្នុងរយៈពេលច្រើនខែក្រោយមក ឬក៏ងាប់ដោយបាក់កំលាំង។

**វិធីការពារ :**

ការពារជំងឺនេះ ដោយការថែរក្សាអនាម័យរួម ឱ្យជ្រូកស៊ីចំណីឆ្អិនកុំឱ្យស៊ីត្រីស្រស់ បាយទឹកជូរជ្លួម ។

ត្រូវទុកដាក់ជ្រូកដែលទើបទិញចូលថ្មីឱ្យនៅឆ្ងាយពីគេ រយៈពេល ៣០ ថ្ងៃ ។

**ចាក់ថ្នាំការពារ :**

វ៉ាក់សាំងការពារជំងឺកញ្ជ្រិល មានប្រតិកម្មខ្លាំង ពេលប្រើវាត្រូវប្រុងប្រយ័ត្ន ។ ការចាក់វ៉ាក់សាំងត្រូវធ្វើជាពីរលើក ក្នុងគំលាត ១០ថ្ងៃ ។

- លើកទី ១:

ចាក់សេរ៉ូមព្យាបាលជំងឺកព្រៀល លាយជាមួយវ៉ាក់សាំង :

* វ៉ាក់សាំង ០.៥ cc សំរាប់ជ្រូកទំងន់ក្រោម ៥០គក្រ

* សេរ៉ូម ៥ cc សំរាប់ជ្រូកទំងន់ក្រោម ៥០គក្រ

ចំពោះជ្រូកទំងន់លើសពី ៥០គក្រ គឺក្នុងកំណើនទំងន់ ១០គក្រ ថែមថ្នាំ លាយខាងលើ ១ cc ។

- លើកទី ២ :

ក្រោយលើកទីមួយ ១០ថ្ងៃ ។

ប្រើវ៉ាក់សាំងតែឯកឯង ០.៥ cc ក្នុងជ្រូកមួយក្បាល ។

ប្រសិទ្ធិភាពរបស់ថ្នាំមានរយៈពេល ៦ខែ ការចាក់ថ្នាំការពារ គឺធ្វើតែចំពោះជ្រូកជាទេ ។ ចំពោះជ្រូកដែលសង្ស័យថាឈឺ ត្រូវព្យាបាលវាដោយសេរ៉ូមសិន រួចសឹមចាក់ថ្នាំការពារ ។

- មេជ្រូកកើតកូនហើយ ១០-២៥ថ្ងៃ ទើបអាចចាក់វ៉ាក់សាំងការពារ ។

- ចាក់វ៉ាក់សាំងការពារតែចំពោះជ្រូកដែលមានអាយុលើសពីបីខែ ។

ការព្យាបាល :

- ចាក់សេរ៉ូមព្យាបាលជំងឺកព្រៀលជ្រូក ទំងន់ ៣០-៥០គក្រ :

១០ cc

- ចាក់សេរ៉ូមព្យាបាលជំងឺកញ្រ្ជិលជ្រូក ទំងន់ ៥០-១០០គក្រ : ២០ cc

- ចាក់សេរ៉ូមព្យាបាលជំងឺកញ្រ្ជិលជ្រូក ទំងន់ > ២០០គក្រ : ៥០cc ចាក់ក្នុងរយៈពេលបីថ្ងៃ ។

ប្រើថ្នាំណាមួយក្នុងចំណោមថ្នាំខាងក្រោមនេះ សុទ្ធតែមានប្រសិទ្ធិភាព :

- Pénicilline 20 000 UI ក្នុងទំងន់ជ្រូក ១គក្រ
- Auréomycine ឬ Tifomycine 10-20mg ក្នុងទំងន់ជ្រូក ១គក្រ
- Streptomycine 20 mg ក្នុងទំងន់ជ្រូក ១គក្រ
- Terramycine injectable solution 2-4 cc ចំពោះជ្រូកទំងន់ ៤៥គក្រ ( ប្រើច្រើនបំផុតត្រឹម ១០ cc )

ការប្រើថ្នាំទាំងប៉ុន្មានខាងលើនេះមានប្រសិទ្ធិភាពល្អណាស់ ប្រសិទ្ធិភាពរបស់វាបង្ហាញឱ្យឃើញតាំងពីថ្ងៃទី ១ ត្រូវប្រើក្នុងរយៈពេល ៣-៤ថ្ងៃ ។

# ជំងឺសារទឹក

**Pasteurellose porcine**
**Pasteurellosis Suum**

---

ជំងឺសារទឹកជាជំងឺឆ្លង បង្កឡើងដោយមេរោគ Pasteurella mul-tocida ។ ជំងឺនេះកើតនៅលើជ្រូកគ្រប់ប្រភេទ ប៉ុន្តែកើតច្រើនបំផុតគឺនៅលើជ្រូកអាយុពី ២-៦ខែ ជំងឺនេះច្រើនកើតមាននៅដើម និង ចុងរដូវភ្លៀង ។ មេរោគឆ្លងតាមរយៈការប៉ះពាល់ផ្ទាល់រវាងជ្រូកឈឺ និង ជ្រូកជា ឬក៏ឆ្លងជាប្រយោលតាមរយៈមនុស្ស និង សត្វដទៃទៀតដែលមានជំងឺនេះ ។ ក្រៅពីនេះ ជំងឺក៏អាចឆ្លងពីធម្មជាតិបានដែរ ព្រោះមេរោគនៃជំងឺនេះរស់នៅក្នុងដី និង នៅលើខ្លួនសត្វ ពេលណាសុខភាពសត្វចុះខ្សោយ ឬក៏ពេលណាមេរោគនៃជំងឺនេះជួបលក្ខណៈអំណោយផល វាក៏រីកដុះដាលយ៉ាងរហ័ស បង្កឱ្យមានជំងឺយ៉ាងធ្ងន់ធ្ងរ ។

**រោគសញ្ញា** : ចែកជាបីកំរិត :-

**- កំរិតធ្ងន់ :**

ក្តៅខ្លាំង មិនស៊ីចំណី ងាប់រហ័ស ជួនកាលម្ចាស់អ្នកចិញ្ចឹមមិនទាំងដឹងថាជ្រូកឈឺផង ពេលខ្លះគេឃើញជ្រូកដែលងាប់ដោយជំងឺនេះ មានហូរឈាមតាមច្រមុះ ។

**- កំរិតមធ្យម :**

រោគសញ្ញាច្បាស់បំផុតនោះគឺ រលាកសួត ហើមបំពង់ក ពិបាកដកដង្ហើម ហេវហត់ ផតពោះ ហៀរទឹកសំបោរខាប់ ក្តៅពី ៤១-៤២°C

រួចហើយឃើញមានចំណុចក្រហម ជួនចំណុចក្រហមនេះផ្តុំគ្នាជាផ្ទាំងនៅកន្លែងស្បែកស្តើង ៥-៦ថ្ងៃ ក្រោយជ្រូកងាប់ ។

- **គំរិតស្រាល** :

ក្តៅ ៣៩-៤០°C មិនសូវស៊ីចំណី រលាកសួត ហៀរទឹកសំបោរ ទល់ លាមក ស្បែករបកទាំងផ្ទាំងៗ ។ បើមិនថែទាំព្យាបាលឱ្យវាទេ ៤-៥អាទិត្យក្រោយ ជ្រូកអាចងាប់ដោយហេវហត់ អស់កំលាំង ។

**រោគវិនិច្ឆ័យ** :

- **ករណីគំរិតធ្ងន់** :

គ្រប់ភ្នាសស្តើងមានចេញឈាម រលាកសួត និង មានស្លេសនៅបំពង់ក ។

- **គំរិតមធ្យម** :

សួតរលាក ហើមពណ៌ស្វាយ រឹង ជួនកាលមានដក់ទឹក បេះដូងចេញឈាម ក្រពេញទងសួតហើម ចេញឈាម ។

- **គំរិតស្រាល** :

សួតរលាកយ៉ាងខ្លាំង ជួនកាលមានខ្ទុះ ។ នៅគ្រប់កំរិតសុទ្ធតែមានចេញឈាមតាមស្បែក ។

* **ប្រយ័ត្នច្រឡំជំងឺនេះជាមួយនឹងជំងឺដទៃទៀត ដូចជា** :

**ជំងឺប៉េស្ត** :

ព្រោះថាជំងឺប៉េស្តក៏ក្តៅខ្លាំង ពិបាកដកដង្ហើម មានចំណុចឈាម

ក្រហមលើស្បែក ។ ប៉ុន្តែចំពោះជំងឺប៉េស្ត កាលណាយើងប្រើ Streptomycine ព្យាបាល ជំងឺនេះវាមិនថយចុះទេ ។

ជំងឺគ្រុនក្រៀល :

ក្តៅខ្លាំង មិនស៊ីចំណីដូចគ្នា ប៉ុន្តែខុសត្រង់ជំងឺគ្រុនក្រៀល មានចំណុចក្រហមលើស្បែករាងមូល ឬរាងបួនជ្រុងនិងស្ពឹកជើងក្រោយទាំងពីរ។

ជំងឺសាល់ម៉ូណេឡូស

ជំងឺនេះក៏បណ្តាលឱ្យជ្រូកក្តៅខ្លាំង មិនស៊ីចំណី ប៉ុន្តែវាគ្មានរោគសញ្ញាពិបាកដកដង្ហើម ហៀរទឹកសំបោរ ទឹកមាត់ទេ ហើយកាលណាយើងព្យាបាលដោយ Streptomycine គឺវាមិនជាទេ ។

ជំងឺផ្តាសាយ :

ក៏ក្តៅខ្លាំង និង ពិបាកដកដង្ហើម ប៉ុន្តែមិនដេកស្ពឹកមួយកន្លែងទេ ពេលចាក់ Streptomycine ក៏ដៅខ្លួនមិនចុះទេ ។

វិធីការពារ :

ត្រូវធ្វើអនាម័យ សំអាតទ្រុងជាប្រចាំ ។ ឱ្យជ្រូកស៊ីចំណីមានជីវជាតិគ្រប់គ្រាន់ ខែភ្លៀងកុំលែងជ្រូកឱ្យចេញក្រៅធ្លា ត្រូវលាងបន្លែឱ្យស្អាតមុនឱ្យជ្រូកស៊ី ។

កាលណាមានជ្រូកណាមួយនៅក្នុងទ្រុងឈឺ ត្រូវយកចេញ ហើយធ្វើអនាម័យទ្រុង ជ្រូកដទៃទៀតដែលនៅសល់ ត្រូវចាក់ថ្នាំការពារជំងឺសារទឹក (Serum Pasteurella ) ចាក់សើស្បែក ឬក៏ចាក់សាច់ ក្នុងកំរិត

០,៥០មល ក្នុង ទំងន់ជ្រូក ១គក្រ ឬក៏ចាក់ Streptomycine ឬ Terramycine 15-20 mg ក្នុងទំងន់ជ្រូក ១គក្រ ។

ការព្យាបាល :

ត្រូវព្យាបាលជាបន្ទាន់ ព្រោះជំងឺនេះអាចបណ្ដាលឱ្យជ្រូកងាប់រហ័សណាស់ យើងអាចប្រើថ្នាំណាមួយក្នុងចំណោមថ្នាំខាងក្រោមនេះ :.

- Streptomycine 15-20 mg ក្នុងទំងន់ជ្រូក ១គក្រ ចាក់មួយថ្ងៃពីរដង ចាក់ក្នុងរយៈពេល ៣-៤ថ្ងៃ កាលណាឃើញកំដៅខ្លួនជ្រូកចុះ ត្រូវចាក់ថែមមួយម្ជុលទៀត កុំឱ្យជំងឺរើឡើងវិញ។
- Pénicilline 20 000 UI/ទំងន់ជ្រូក ១គក្រ ចាក់សាច់ ៣-៤ថ្ងៃ។
- Terramycine 10-15 mg ក្នុងទំងន់ជ្រូក ១គក្រ ចាក់ ៣-៤ថ្ងៃ ពេលណាឃើញកំដៅចុះ ត្រូវចាក់ថែមមួយម្ជុលទៀត ។

ប្រើប្រភេទថ្នាំស៊ុលហ្វាមីត ( Sulfamide ) ដូចជា Sulfamerazine. Sulfaméthazine. Sulfathiazol : 0.15g ក្នុងទំងន់ជ្រូក ១គក្រ ចែកជាពីរ មួយថ្ងៃឱ្យផឹកពីរដង ឱ្យផឹក ៣-៤ថ្ងៃ ។

ប្រើថ្នាំប្រភេទនេះ ត្រូវឱ្យជ្រូកផឹកទឹកឱ្យបានច្រើន ។

# ជំងឺរបេង

**La tuberculose**
**Tuberculosis**

---

មូលហេតុ :

ជំងឺរបេងជាជំងឺរ៉ាំរ៉ៃ បង្កជាមហន្តរាយយ៉ាងស្មៀមស្ងាត់ដល់អ្នកចិញ្ចឹមជ្រូក ជំងឺរបេងចំលងពីមនុស្សទៅសត្វ និង ពីសត្វទៅមនុស្ស ។ ជំងឺនេះបង្កឡើងដោយមេរោគ Mycobactérium tuberculosis (Bacille de Koch ) មនុស្សក៏ដូចជាសត្វដែរ សុទ្ធតែកើតជំងឺរបេង លើកលែងតែសត្វដែលគ្មានទ្រនង់ឆ្អឹងខ្នង ដូចជាជន្លេន បង្កង បង្គារ ក្តាម ។ ល ។

សត្វជ្រូកអាចនឹងឆ្លងមេរោគរបេងពីសត្វគោ ពីមាន់ ពីមនុស្ស ប្រសិនបើជ្រូកនោះផឹកទឹកដោះគោ យកពីសត្វគោកើតរោគរបេង ឬក៏សត្វជ្រូកនោះរស់នៅរួមគ្នាជាមួយសត្វមាន់កើតរបេង ឬ មួយវិញទៀតមកពីយើងយកចំណីអាហារសេសសល់ពីមនុស្សកើតរបេងទៅឱ្យជ្រូកស៊ី ។ ប៉ុន្តែភាគច្រើនគឺសត្វជ្រូកឆ្លងមេរោគរបេងពីសត្វគោ ពីព្រោះដោយសារយើងចិញ្ចឹមគោ និង ជ្រូកលែងឱ្យដើររកស៊ីជាមួយគ្នា ។ សត្វជ្រូកកើតរបេងតិចជាងសត្វគោ ព្រោះអាយុជ្រូកដែលគេសំលាប់ខ្លីជាងសត្វគោ ។

រោគសញ្ញា :

សត្វជ្រូកនៅគ្រប់អាយុកាល សុទ្ធតែអាចកើតជំងឺរបេង ប៉ុន្តែក្នុងករណីស្រាល គេមិនឃើញមានរោគសញ្ញាអ្វីទាំងអស់ ។ ក្នុងសភាពធ្ងន់ធ្ងរ

ជ្រូកនៅតែស៊ីចុកជាធម្មតា ប៉ុន្តែចេះតែស្គមទៅៗ ។ បើយើងប្រើថ្នាំបញ្ចុះព្រូន និង ចាក់វីតាមីន លើកកំលាំងឱ្យជ្រូកស្គមនោះហើយ វានៅតែស្គមទៀត ត្រូវសង្ស័យថាមានជំងឺ របេង ។

បើជំងឺរបេងកើតនៅលើសួតនោះ តែក្នុងប៉ុន្មានអាទិត្យ អាចបណ្តាលឱ្យជ្រូកងាប់ដោយសារបាត់កំលាំង និង ស្ទះដង្ហើម ។ បើកើតនៅលើប្រដាប់រំលាយអាហារ នោះបណ្តាលឱ្យម្តងរាគ ម្តងទល់លាមក រួចហើយចុះស្គមជាបណ្តើរៗ រហូតដល់ ២-៣ខែ ទើបងាប់ ។ បើកើតរបេងឆ្អឹង នោះបណ្តាលឱ្យហើមសន្លាក់ឆ្អឹង ជ្រូកពិការជើង និង ហើមមុខ ។

**រោគវិនិច្ឆ័យ :**

កន្លែងណាមានជំងឺ កន្លែងនោះមានដុំកំបោរពណ៌លឿង ឬ សមានខ្ទុះខាប់ពណ៌លឿងនៅខាងក្នុង ។ ដុំកំបោរនេះគឺជាគ្រាប់របេង មានទំហំប៉ុនគ្រាប់អង្ករ ឬ ធំជាងនេះ ។ បើរបេងសួតយើងអាចឃើញដុំ ( Kyste ) ធំប៉ុនគ្រាប់សណ្តែកបាយ ឬ ប៉ុនម្រាមដៃ បើយើងកាត់វា នោះនឹងឃើញខ្ទុះខាប់ហូរចេញ ។ កន្លែងណាកើតរបេង កូនកណ្តុរកន្លែងនោះហើមប៉ុនពងមាន់ កាលណាយើងវះឃើញខ្ទុះហូរចេញ ដូចជាកូនកណ្តុរនៅក្រោមចង្កា នៅដើមបំពង់ក នៅភ្លៅខាងក្រោយ នៅឆ្អឹងជំនី ។ ល ។

**វិធីការពារ :**

- រក្សាអនាម័យទ្រុងចិញ្ចឹម
- ចំអិនចំណីដែលសេសសល់ពីមនុស្សឱ្យឆ្អិន មុននឹងឱ្យជ្រូកស៊ី

- កុំចិញ្ចឹមមាន់លាយឡំនឹងជ្រូក
- កុំលែងជ្រូកឱ្យដើររកស៊ីចំណីជាមួយគោ
- ត្រូវសំលាប់ជ្រូកដែលសង្ស័យថាកើតរបេងចោល

**ការព្យាបាល**

បើដឹងច្បាស់ថាជ្រូកនោះកើតរបេងហើយ ត្រូវសំលាប់ចោល ព្យាបាល ឥតប្រយោជន៍នាំតែខាតថ្នាំ ព្រោះជំងឺរបេងត្រូវព្យាបាលយូរទើបជា ហើយជាកត្តាចំលងមេរោគរបេងឱ្យដល់ជ្រូកដទៃទៀត និង ដល់អ្នកចិញ្ចឹមផង ។

## ជំងឺរលូតកូន

**La brucellose**
**Brucellosis**

ជំងឺរលូតកូន ត្រូវបានរកឃើញដោយលោក Traum ក្នុងឆ្នាំ ១៩១៤ ។ ជំងឺនេះបណ្ដាលឡើងដោយមេរោគឈ្មោះ Brucella ដែលអាចកើតមានផងដែរនៅលើសត្វសេះ សត្វគោ សត្វឆ្កែ និង សត្វស្លាប ប៉ុន្តែក្នុងកំរិតស្រាលជាងនៅលើសត្វជ្រូក ។ ជាទូទៅជំងឺរលូតកូននៅលើគោ គឺបណ្ដាលមកពី Brucella abortus នៅលើជ្រូកគឺ Brucella suis ហើយនៅលើសត្វចៀម ពពែគឺ Brucella melitensis ។ ប៉ុន្តែសត្វជ្រូកអាច

និងមានជំងឺរលូតកូនបណ្តាលមកពី Brucella abortus របស់គោ ក្របី ឬក៏ Brucella melitensis របស់ចៀម ពពែដែរ ឬក៏ ផ្ទុយមកវិញ ។

ប្រការដែលគួរឱ្យចាប់អារម្មណ៍គឺថា ជំងឺរលូតកូនរបស់សត្វ ក៏អាចចំលងមកមនុស្សដែរ ។

រោគសញ្ញា :

ចាប់ពីពេលដែលមេរោគចូលទៅក្នុងខ្លួនរបស់សត្វជ្រូក រហូតដល់ពេលជំងឺចាប់ផ្តើម គឺមានរយៈពេលពី ១-២អាទិត្យ ទៅតាមកំលាំងរបស់មេរោគ ។ ជាដំបូងមេរោគចូលទៅក្នុងឈាម បណ្តាលឱ្យជ្រូកក្តៅខ្លួនកំដៅឡើងចុះមិនធម្មតា មិនសូវស៊ីចំណី ។ រយៈពេលដែលមេរោគរាតត្បាត មិនហួសពីបីអាទិត្យទេ មេរោគច្រើនប្រមូលផ្តុំនៅលើប្រដាប់បន្តពូជ និង នៅសន្លាក់ឆ្អឹង បណ្តាលឱ្យជ្រូកឈឺជើង ពិបាកដើរ ។

កាលណាមេរោគប្រមូលផ្តុំនៅលើប្រដាប់បន្តពូជ នោះបណ្តាលឱ្យជ្រូកញី និង ជ្រូកឈ្មោលមានរោគសញ្ញាដូចតទៅ :-

- មេជ្រូក :

មិនមានកូន មេរោគអាចរស់នៅក្នុងស្បូនជាច្រើនខែ ចំពោះមេដែលមានកូនហើយរលូត នោះមេរោគអាចរស់នៅក្នុងស្បូនរហូតដល់ ២-៣ឆ្នាំ ។ ជាទូទៅមេរោគ Brucella មិនបណ្តាលឱ្យស្បូនមានខ្ទុះទេ ប៉ុន្តែអាចហើម ហើយមានខ្ទុះតែក្នុងករណីដែលស្បូនមានមេរោគផ្សេងទៀតរាតត្បាតក្រោយពេលរលូតកូនតែប៉ុណ្ណោះ ។

ប្រសិនបើមេជ្រូកមានមេរោគនេះរាតត្បាត មុនពេលដាក់ឈ្មោល ឬក៏ មានជំងឺដោយសារការដាក់ឈ្មោល នោះបីអាទិត្យក្រោយវានឹងរលូតកូន ជួនកាលម្ចាស់អ្នកចិញ្ចឹមមិនបានដឹងទេ ព្រោះកូនតូចពេក ហើយប្រហែល ៣០-៤៥ថ្ងៃ ក្រោយមកមេជ្រូករកឈ្មោលឡើងវិញ ។ ដូច្នេះកាលណាយើងឃើញមេជ្រូក ក្រោយពេលដាក់ឈ្មោលហើយមួយខែ ឬមួយខែកន្លះក្រោយ រកឈ្មោលឡើងវិញ នោះត្រូវចាប់អារម្មណ៍នឹងការរលូតកូន ដោយសារជំងឺ Brucellose ។

ក្រោយពេលរលូតកូន បើសិនមេរោគរស់នៅក្នុងស្បូន នោះការដាក់ឈ្មោលមិនបានលទ្ធផលទេ ។ ប៉ុន្តែក្រោយពេលរលូតកូន ២-៣ដង មេរោគងាប់ នោះទើបមេជ្រូកអាចមានកូនឡើងវិញ ។

- បាជ្រូក :

មេរោគរាតត្បាតនៅត្រង់សន្លាក់ឆ្អឹង និង នៅលើប្រដាប់បន្តពូជ មេរោគ នេះអាចរស់នៅលើប្រដាប់បន្តពូជរបស់ជ្រូកឈ្មោលអស់មួយជីវិត មិនងាប់ដូចរស់នៅលើប្រដាប់បន្តពូជរបស់ជ្រូកញីទេ ។ បាជ្រូកដែលមានជំងឺនេះ ចំលងមេរោគដល់គ្រប់មេជ្រូកដែលវាពាក់ ។ ក្រៅពីរោគសញ្ញាហើមពងម្ខាង និង ហើមសន្លាក់ឆ្អឹងនោះ គ្មានរោគសញ្ញាអ្វីផ្សេងទៀតទេ ស៊ីចុកធម្មតា ហើយខ្លាំងក្លាក្នុងការពាក់ញីទៀតផង ។

- កូនជ្រូក :

រោគសញ្ញានៅលើកូនជ្រូក គឺហើមសន្លាក់ឆ្អឹងជើង ប៉ុន្តែក៏មានករណីខ្លះកូនជ្រូកឈឺ គ្មានបង្ហាញរោគសញ្ញាអ្វីទាំងអស់ ។

ដូច្នេះយើងឃើញថាមានរោគសញ្ញាបី : ទីមួយរលូតកូន ទីពីរ ហើមពង ទីបីហើមសន្លាក់ឆ្អឹង ។ ប៉ុន្តែរោគសញ្ញាទាំងបី មិនមែនជារោគសញ្ញាដែលមានតែចំពោះជំងឺរលូតកូនតែប៉ុណ្ណោះទេ ត្រូវពឹងផ្អែកលើមន្ទីរពិសោធន៍ ដើម្បីបញ្ជាក់ពីប្រភេទជំងឺ ។

វិធីការពារ :

អនុវត្តវិធានការអនាម័យ ដើម្បីការពារកុំឱ្យមេរោគ ចំលងទៅជ្រូកដទៃ ត្រូវដាក់ជ្រូកឈឺឱ្យនៅដោយឡែក កប់ ឬ ដុតចោលកូនជ្រូកដែលរលូត។ លាងសំអាតទ្រុងដោយទឹក Crésyl 4% ស្អួកទឹក ស្អួកចំណីលាងសំអាតដោយ ទឹកកំបោរ ១០% ហើយទុកវាឱ្យនៅទំនេរ ៤-៥ថ្ងៃ ។

មិនបាច់ចាក់ថ្នាំការពារជំងឺនេះទេ ។

ការព្យាបាល :

គប្បីព្យាបាលតែមេជ្រូកពូជល្អ ចិញ្ចឹមសំរាប់យកកូនទុកចិញ្ចឹមយកសាច់បានហើយ ។ ជ្រូកក្រៅពីនេះមិនបាច់ព្យាបាលទេ ។

- Auréomycine 1g ក្នុងជ្រូកមួយក្បាល
- Streptomycine 15-20 mg ក្នុងទំងន់ជ្រូក ១គក្រ
- Sulfadiazine 1g ក្នុងជ្រូកមួយក្បាល
- Terramycine កំរិតប្រើដូចគ្នានឹងជំងឺដទៃទៀត ។

# ជំងឺឡិបតូ

## Leptospirose
## Leptospirosis

---

ឡិបតូ ជាជំងឺមួយដែលគេកំណត់ថាមានសារសំខាន់នៅលើជ្រូក តាំងពីឆ្នាំ ១៩៥០ ។ ជំងឺនេះបង្កឱ្យមានមហន្តរាយធំគួរសមខាងសេដ្ឋកិច្ច។

តាមរបាយការណ៍របស់ក្រសួងកសិកម្មអាមេរិកថា ឆ្នាំ ១៩៥៤ សហរដ្ឋអាមេរិកខាតបង់ទឹកប្រាក់ចំនួន ៤៣៨លានដុល្លារ ដោយសារការងាប់កូនជ្រូកបណ្ដាលមកពីជំងឺនេះ ។ ជំងឺឡិបតូ រាតត្បាតនៅក្នុងកសិដ្ឋានបណ្ដាលឱ្យកូនជ្រូកងាប់មុនពេលកើត ជួនកាលកើតភ្លាមងាប់ភ្លាម ជួនកាលកើតបានមួយអាទិត្យ ងាប់ទាំង ១00% ។

### មូលហេតុ :

ជំងឺនេះត្រូវបានរកឃើញជាលើកដំបូង នៅប្រទេសអូស្ត្រាលី ក្នុងឆ្នាំ ១៩៣៧ ដោយលោក Clayton និង សហការី នៅលើមនុស្សម្នាក់ដែលមានជំងឺគ្រុន ៧ថ្ងៃ ( Fièvre des 7 jours ) ដោយសារជននេះផឹកទឹកក្នុងជ្រោះតូចមួយ មុនពេលមានរោគសញ្ញាជាលើកដំបូងលេចចេញ ។ ក្រោយមកគេបានរកឃើញមេរោគនេះនៅលើសត្វជ្រូក និង នៅលើសត្វគោ ។

គេអាចនឹងនិយាយថាជំងឺឡិបតូ ជាជំងឺដែលកើតមាននៅលើសត្វជ្រូក ក្នុងកាសពេញពិភពលោក ។

**ការឆ្លងរាលដាល :**

ជាទូទៅមេរោគឆ្លងតាមកន្ទែងរបួស រលាត់ស្បែក ។ មេរោគនេះអាចរស់បានក្នុងផ្លោកនោមរហូតដល់ ៦ខែ ឬក៏យូរជាងនេះទៅទៀតក៏មាន ហើយអាចរស់បានក្នុងទឹកនោមតិចបំផុត ក៏បានច្រើនម៉ោងដែរ ។ ការចំលងគឺតាមរយៈទឹកនោមដែលមានជំងឺនេះ ទៅប៉ះភ្នាសស្តើងនៅភ្នែកមាត់ ច្រមុះ ឬក៏ឆ្លងតាមកន្លែង រលាត់ពីជ្រូកឈឺមកជ្រូកជា ។

ជំងឺនេះរាតត្បាតជាលើកដំបូងទៅលើកូនជ្រូក ហើយបន្ទាប់មករាតត្បាតគ្រប់ជ្រូកទាំងអស់ក្នុងទ្រុង ។ ជំងឺនេះអាចឆ្លងពីគោទៅជ្រូក និងពីជ្រូកទៅគោ តាមរយៈទឹកនោម ។

**រោគសញ្ញា :**

ក្តៅ ( ៤០-៤២°C ) មិនស៊ីចំណី រាគ ដង្ហើមធម្មតា ប៉ុន្តែ ១-២ថ្ងៃក្រោយ គេឃើញភ្នាសស្បែកភ្នែកស្លេកស្លាំង លឿង ហើយទឹកនោមពណ៌ក្រហម ដោយសារការបែកធ្លាយផ្លោកនោម និង ដោយសាររលាកថ្លើម ។ ក្នុងកំរិតស្រាល ( ភាំរៃ ) គេមិនឃើញមានរោគសញ្ញាក្តៅ និង ទឹកនោមក្រហមទេ គេគ្រាន់តែឃើញវាស្តែងចេញនៅលើមេជ្រូក ដោយការរលូតកូន ងាប់កូនក្នុងពោះ និង កូនមិនគ្រប់ខែតែប៉ុណ្ណោះ ។

**រោគវិនិច្ឆ័យ :**

ស្បែកលឿង ស្លេកស្លាំង ខ្លាញ់លឿង ហិតទៅធុំក្លិនឈ្មៀម

( ផ្ទិត ) ថ្លើមលឿង ប្រមាត់រួញស្វិត គ្រលៀនលឿង នៅក្នុងផ្លោកនោម គេឃើញទឹកនោមពណ៌លឿង ក្រហម ផាល ( Rate ) ហើម មានដក់ទឹក ក្នុងទ្រូង និង ក្នុងពោះ ។

**ការតាមដានជំងឺ :**

ការតាមដានពីជំងឺនេះ មានសារសំខាន់ទាំងខាងផ្នែកសេដ្ឋកិច្ច ទាំងខាង ការទប់ស្កាត់មិនឱ្យជំងឺនេះឆ្លងពីសត្វជ្រូកទៅសត្វដទៃទៀត ។ បើ យើងចិញ្ចឹមលាយគ្នា ជ្រូកផង គោផង នោះកាលណាជ្រូកឈឺ គោក៏ឈឺ ដែរ ។

គោឈឺជំងឺនេះ គឺដោយសារស៊ីចំណីមានមេរោគនៃជំងឺនេះ ឬក៏ ដោយសារលិទ្ធទឹកនោមមេគោឈឺ មេរោគនេះក៏អាចចូលតាម ភ្នែក ច្រមុះ និង តាមកន្លែងរលាត់ស្បែក ឬក៏ដោយសារប៉ះផ្ទាល់នឹងទឹកនោមសត្វឈឺ ។

**វិធីការពារ :**

មេរោគអាចរស់ក្នុងទឹកនោមគោរហូតដល់ ១៥ថ្ងៃ ។ វិធានការ ការពារដ៏ប្រសើរបំផុត គឺរក្សាអនាម័យទ្រុងចិញ្ចឹម និង ជុំវិញទ្រុងឱ្យស្អាត បាត មិនត្រូវឱ្យទឹកនោមទ្រុងមួយ ហូរចូលទ្រុងមួយទៀតទេ ។ បន្ថយការ ផ្លាស់ប្តូរជ្រូកពីទ្រុងមួយទៅទ្រុងមួយ ។ សត្វចៀមមិនសូវកើតជំងឺនេះ ដូច សត្វគោ សត្វជ្រូក និង សត្វ ពពែទេ ។ ត្រូវដាក់ជ្រូកឈឺដោយឡែក កុំឱ្យនៅលាយឡំជាមួយជ្រូកជា ។

ចាក់វ៉ាក់សាំងការពារជំងឺឡិបតូ ២មល ក្នុងជ្រូកមួយក្បាល ( ចំពោះកូនជ្រូកអាយុលើសមួយខែ ) ៧ថ្ងៃក្រោយចាក់ម្តងទៀត ចាក់ ៣មល។

ភាពស៊ាំនឹងជំងឺនេះអាចមានពី ៦ខែ-១ឆ្នាំ ។ ចំពោះមេជ្រូកចាក់មុនពេលដាក់ឈ្មោល ២១ថ្ងៃ ។ ចាក់លើកទី១ ៣មល ហើយ៧ថ្ងៃក្រោយ ចាក់លើកទី២ ក្នុងកំរិត៥មល។

ការព្យាបាល :

អាចប្រើថ្នាំណាមួយ ក្នុងចំណោមថ្នាំខាងក្រោមនេះ ដើម្បីព្យាបាល :-

- Strepnovil ចាក់សាច់ ជ្រូកតូច ១មល ក្នុងទំងន់ជ្រូក ៥គក្រ ជ្រូកធំ ១មល ក្នុងទំងន់ជ្រូក ១០គក្រ មួយថ្ងៃចាក់ពីរដង ចាក់ជាប់គ្នាក្នុងរយៈពេល ៣-៤ថ្ងៃ ។

- Tylan ចាក់សាច់ ១មល ក្នុងទំងន់ជ្រូក ៥គក្រ ចាក់ ៣-៥ថ្ងៃ

- Terramycine, Chlortétrasone ចាក់សាច់ ១មល ក្នុងទំងន់ជ្រូក ១០គក្រ មួយថ្ងៃចាក់ម្តង ចាក់ក្នុង ៤-៥ថ្ងៃ ។

- ចាក់បន្ថែមថ្នាំប៉ូវកំលាំងដូចជា B1, B12, C, Bécomplexe ។

ជំងឺឡិបតូ ជាជំងឺដែលងាយកំចាត់ចេញ ។

# ជំងឺសាល់ម៉ូណេឡូស
## La salmonellose
## Salmonellosis

ជំងឺសាល់ម៉ូណេឡូស ជាជំងឺឆ្លង បង្កឡើងដោយមេរោគ Salmonella choleraesuis ។ ជាទូទៅមេរោគចូលទៅក្នុងខ្លួនសត្វតាមមាត់ ហើយរីកដុះដាលនៅក្នុងពោះវៀនតូច បណ្ដាលឱ្យរលាកពោះវៀន ( ជ្រូកភាគ ) ។

មេរោគ Salmonella រស់នៅយ៉ាងស្ងៀមស្ងាត់ក្នុងពោះវៀនជ្រូកជា ដោយមិនបង្កជាមហន្តរាយអ្វីទេ ប៉ុន្តែកាលណាជួបលក្ខណៈអំណោយផលដូចជាជ្រូកចុះខ្សោយ ឬក៏មានជំងឺឆ្លងដទៃទៀត ពិសេសកាលណាមានជំងឺប៉េស្ដ ឬក៏ពុលដោយសារស៊ីចំណីផ្សរផ្សម មេរោគនេះរីកដុះដាលរហ័ស ។

ជំងឺឆ្លងដោយផ្ទាល់ពីជ្រូកឈឺទៅជ្រូកជា តាមរយៈទឹកនោម និងលាមក ពិសេសក្នុងពេលជ្រូកឡើងកំដៅខ្លួន ។ ឆ្លងជាប្រយោលតាមរយៈអ្នកចិញ្ចឹម តាមកណ្ដុរ រុយ ពាំនាំមេរោគទៅទំលើស្បូកចំណី ។

ជំងឺសាល់ម៉ូណេឡូស អាចចំលងទៅគោ ឆ្កែ មាន់ និង មនុស្ស ហើយផ្ទុយទៅវិញ ជំងឺរបស់គោ ឆ្កែ មាន់ និង មនុស្ស ក៏អាចចំលងដល់ជ្រូកវិញដែរ ។

រោគសញ្ញា : ចែកជាពីរកំរិត :

- ករិតធ្ងន់ :

សំលាប់កូនជ្រូកក្រោយពេលផ្តាច់ដោះ ក្នុងរយៈពេល ៧-៨ថ្ងៃ ។

- ករិតរ៉ាំរ៉ៃ :

ច្រើនកើតមាននៅលើជ្រូកជំទើរ និង ជ្រូកធំ ជ្រូកឈឺមិនងាប់ទេ តែក្រោយពេលជា ពាំមេរោគសម្ងំក្នុងខ្លួន ហើយចំលងទៅជ្រូកដទៃទៀត ដែលរស់នៅក្នុងទ្រុងជាមួយវា មេជ្រូកមានជំងឺនេះបណ្តាលឱ្យរលូតកូន ។

កូនជ្រូកបៅដោះមេ មានអង្គប្រយុទ្ធការពារទប់ទល់នឹងជំងឺរាគ ដូចនេះមិនសូវមានជំងឺនេះទេ បើមានក៏ក្នុងកំរិតស្រាលដែរ ហើយកូនជ្រូក អាចនឹងជាពីជំងឺនេះ ។

កូនជ្រូកអាយុពី ២-៤ខែ ច្រើនមានជំងឺនេះក្នុងកំរិតធ្ងន់ ។

ជ្រូកពីអាយុ ៤ខែឡើង មានជំងឺនេះក្នុងកំរិតរ៉ាំរ៉ៃ ។

- ករិតធ្ងន់ :

ក្តៅខ្លួន មិនស៊ីចំណី គ្រាន់តែលិទ្ធបន្តិចបន្តួច ហើយច្រើនត្បុល ចូលគ្នា ។ ក្រោយមានជំងឺ ២-៣ថ្ងៃ កូនជ្រូកមានសភាពដូចជាពីជំងឺ ប៉ុន្តែក្រោយមកត្រឡប់ជាបើឡើងវិញ ធ្ងន់ជាងមុន បណ្តាលឱ្យក្តៅខ្លាំង រាគ លាមកមានក្លិនស្អុយខ្លាំង ។ ក្នុងលាមកមានលាយសំបោរ ជ្រូករាគរហូត ដល់បាក់កំលាំង ដើរព័ន្ធជើង ដេកដួលមួយកន្លែង ហើយ ២-៣ថ្ងៃ ក្រោយមក ជ្រូកងាប់ដោយបាក់កំលាំង ។

- ករិតស្រាល ( រ៉ាំរ៉ៃ ):

ជ្រូកអាយុ ៤ខែឡើង កើតជំងឺនេះស្រាលជាងជ្រូកទើបផ្តាច់ដោះ

ហើយ អាចជាពីជំងឺ ។ មេរោគ Salmonella រស់នៅយ៉ាងស្ងៀមស្ងាត់ក្នុងថ្លើម ប្រមាត់ ក្នុងប្រដាប់រំលាយអាហារ និង នៅលើប្រដាប់បន្តពូជ ហើយកាលណាជួបលក្ខណៈអំណោយផល ក៏ចំលងទៅជ្រូកជាដែលរស់នៅជាមួយគ្នា ។

ក្នុងកំរិតនេះ មិនបង្ហាញរោគសញ្ញាគ្រោះថ្នាក់អ្វីទេ ជ្រូកខ្លះឈឺស្អែក ខ្លះរាគ ប៉ុន្តែចំពោះមេដើម អាចបណ្តាលឱ្យរលូតកូន ឬជួនកាលមិនរលូតទេ តែបណ្តាលឱ្យកូនមួយចំនួនងាប់ ក្រៀមស្វិតក្នុងពោះ ហើយមិនធ្លាក់ចេញមកក្រៅទេ លុះដល់ពេលកូនដទៃទៀតកើត ក៏ចេញមកក្រៅជាមួយគ្នាតែម្តង ។

រោគវិនិច្ឆ័យ :

វះពិនិត្យមើលកូនជ្រូកងាប់ដោយជំងឺនេះ ក្នុងកំរិតធ្ងន់ឃើញថាពោះវៀនមានដំបៅចេញឈាម កូនកណ្តុរពោះវៀនហើម ស្រោមបេះដូងមានខ្ទុះ ស្រោមពោះមានទឹកពណ៌លឿង ។

ក្នុងកំរិតស្រាលឃើញ ក្នុងពោះមានទឹក ពោះវៀនហើម មានដំបៅកូនកណ្តុរ ពោះវៀនមានខ្ទុះប្រែជាស្លូតពណ៌លឿងដូចកូនកណ្តុរជ្រូកដែលកើតជំងឺរបេងដែរ ។

វិធីការពារ :

រក្សាអនាម័យទ្រុងចិញ្ចឹម ជាវិធានការស័ក្តិសិទ្ធសំរាប់ប្រយុទ្ធប្រឆាំងនឹងជំងឺនេះ ។ ត្រូវយកកូនជ្រូកឈឺចេញ ទុកចិញ្ចឹមដោយឡែក ដើម្បី

ងាយស្រួលក្នុងការតាមដានជំងឺ វិធីបានការការពារដ៏ប្រសើរបំផុតនោះ គឺចាក់វ៉ាក់សាំងការពារ។

**ការព្យាបាល :**

ព្យាបាលជំងឺរាគបណ្តាលឱ្យរលាកពោះវៀនរបស់ជ្រូក ដូចគ្នានឹងព្យា-បាលជំងឺរាគរបស់មនុស្សដែរ ។

- Sulfaguanidine ( Guanidan ) 1g ក្នុងទំងន់ជ្រូក ១០គក្រ ១ថ្ងៃ ៤ដង ប្រើក្នុងរយៈពេល ៥ថ្ងៃ
- Auréomycine 40mg ក្នុងទំងន់ជ្រូក ១គក្រ

បើជ្រូករាគខ្លាំងត្រូវចាក់សេរ៉ូមផ្អែម ឬសេរ៉ូមប្រៃ ហើយឱ្យស៊ីចំណីសំបូរជីវជាតិ ឬក៏ឱ្យផឹក Polyvitamine ។

- ចាក់ Sérum salmonellose ចាក់សើស្បែក :

៣០-៦០ មល / ជ្រូកអាយុ ១៥-៣០ថ្ងៃ

៥០-៨០ មល / ជ្រូកអាយុច្រើនជាង ៣០ថ្ងៃ

សេរ៉ូមនេះថ្លៃ ហើយពិបាករក ។

# ជំងឺរាគស

## La colibacillose
## White scours

---

ជំងឺរាគស ( Diarrhée blanche ) ជាជំងឺកើតមាននៅលើកូនជ្រូក ។ ភ្នាក់ងារដែលបង្កឱ្យមានជំងឺនេះ មិនមែនមានតែមួយទេ គឺមានច្រើនដូចជា Escherichia Coli, Salmonella choleraesuis ។ ល ។

វះពិនិត្យសាកសពជ្រូកងាប់ ជាទូទៅបង្ហាញឱ្យឃើញថាបណ្ដាលមកពី E.Coli ។

មូលហេតុដែលមេរោគនេះធ្វើសកម្មភាព គឺបណ្ដាលមកពី :-

- កូនជ្រូកបៅច្រើនពេក ( មេមានទឹកដោះច្រើន )
- ការផ្លាស់ប្ដូរអាកាសធាតុ ( ក្ដៅ មកត្រជាក់ )
- ទ្រុងចិញ្ចឹមក្រខ្វក់ សើម
- មេជ្រូកស៊ីចំណីមិនល្អ កន្ទក់ កាកសំណល់ចាស់ ដុះផ្សិត ។ល ។

រោគសញ្ញា :

ចាប់តាំងពីពេលទើបកើត កូនជ្រូកហាក់ដូចជាមិនមានប្រតិកម្មអ្វីទាំងអស់ ( Apathique ) ហើយរាគ លាមកពណ៌ស-លឿង ( Blanc-jaunâtre ) ក្លិនស្អុយ ។ កូនជ្រូកដែលមានជំងឺនេះ ចុះខ្សោយ និង ថយទំងន់យ៉ាងច្រើន ងើបមិនរួច ដេកមួយកន្លែង រួចហើយសេចក្ដីស្លាប់ក៏មកដល់ ។ គូថប្រឡាក់លាមករាវ បើសិនជាកូនជ្រូកនោះមិនងាប់ទេ លាមកក៏ក្លាយជា

វិញមកវិញ ។ អត្រាកូនជ្រូកឈឺ ងាប់ដោយសារជំងឺនេះដោយមិនបាន ព្យាបាល អាចមានរហូតដល់ ១០០% ។

**រោគវិនិច្ឆ័យ :**

បញ្ជាក់ដោយលាមកពណ៌ស-លឿង តែមិនត្រូវច្រឡំនឹងរោគសញ្ញានៃ ជំងឺរាគដទៃទៀតទេ ។

- ជំងឺប៉េស្ត ក្រៅពីរាគនៅមានរោគសញ្ញាដទៃទៀតជាច្រើន

- ជំងឺរាគកូនជ្រូក ( សាល់ម៉ូណេឡូស ) ច្រើនកើតនៅលើកូនជ្រូកអាយុលើសមួយខែ ។

**វិធីការពារ និង ព្យាបាល :**

ក្នុងករណីមេជ្រូកមានទឹកដោះច្រើន ត្រូវបន្ថយចំណីបន្តិច ដើម្បីឱ្យទឹកដោះថយចុះ ។ ទ្រុងចិញ្ចឹមត្រូវស្ងួត មានខ្យល់អាកាសចេញ-ចូល ទ្រុងកំដៅកូនជ្រូកត្រូវមានអំពូលភ្លើង និង ចំបើងទ្រាប់បាតទ្រុង និង ការពារកុំឱ្យភ្លៀងសាចចូល ។

- ចាក់ Serum glucosé ក្នុងរយៈពេល ២-៣ថ្ងៃ

- ចាក់ Streptomycine ក្នុងរយៈពេល ២-៣ថ្ងៃ

ឱ្យកូនជ្រូកផឹកបន្ថែម

- Sulfaguanidine ( Guanidan ) ឬ Sulfadiazine រាល់ថ្ងៃ រហូតដល់ពេលជា ។

ក្នុងករណីឱ្យផឹក និង ចាក់ថ្នាំខាងលើនេះហើយមិនជា ត្រូវប្តូរប្រើថ្នាំ ដូចតទៅនេះ :-

- ចាក់ Chlortétrasone 1/2 cc / ថ្ងៃ / ជ្រូកមួយក្បាល

- ឱ្យផឹក Bactrim. Métrodinazole 0.25 ១ថ្ងៃ មួយគ្រាប់ចែកជាពីរ ព្រឹក ½ និង ល្ងាច ½ ផឹក ៣ថ្ងៃ ។

## ជំងឺតេតាណូស

**Le tétanos**
**Tetanus**

ជួនកាលគេហៅជំងឺនេះថាជំងឺរឹងថ្គាម ។ គ្រប់ប្រភេទសត្វសុទ្ធតែកើតជំងឺនេះ លើកលែងតែសត្វមាន់ និង សត្វទា ។

ងាយកើតជំងឺតេតាណូសជាងគេគឺមនុស្ស ។ ជំងឺនេះកើតមាននៅលើកូនជ្រូក ច្រើនជាងនៅលើជ្រូកធំ ។

ជំងឺតេតាណូសបង្កឡើងដោយមេរោគ Clostridium tétani ដែលរាតត្បាតចូលទៅក្នុងខ្លួនមនុស្ស ឬ សត្វ តាមរយៈមុខរបួសជ្រៅ ។ សត្វជ្រូកកើតជំងឺនេះ ច្រើនបណ្តាលមកពីការក្រៀវ ឬ ជួនកាលឆ្លងតាមរន្ធផ្ចិត ក្រោយពេលកើត ហើយជួនពេលខ្លះ គេរកមិនឃើញស្នាមរបួសទេ តែមានជំងឺនេះ ។

រយៈពេលសម្ងំនៃមេរោគគឺ ១.២ថ្ងៃ ឬក៏រហូតដល់ ២.៣អាទិត្យ អាស្រ័យលើចំនួនមេរោគរាតត្បាត និង អាស្រ័យលើទំហំនៃស្នាមរបួស ។

**រោគសញ្ញា :**

ដំបូងរឹងសាច់ដុំ រួចហើយរឹងពេញខ្លួនតែម្តង ចំកោងខ្នងដូចដងវែក ។

- រឹងថ្គាម ហាមាត់មិនកើត
- ភ្នែករឹងមិនកំរើក ប្រស្រីក្រឡាប់ចុះ
- កន្ទុយលើកឡើងលើ
- ដេកមួយចំហៀង សណ្តូកជើងទាំងបួនមកក្រោយ ក្រោកលែងរួច ។
- ជង្ហើមហត់ កំដៅឡើងដល់ ៤០°C
- ត្រចៀកបះឡើងលើ

ជ្រូកកើតជំងឺនេះ ច្រើនងាប់ក្នុងរយៈពេល ៤-៥ថ្ងៃក្រោយ ដោយសារខ្សោយបេះដូង និង ខ្សោយដង្ហើម ។

**រោគវិនិច្ឆ័យ :**

រោគសញ្ញានៃជំងឺតេតាណូស
មិនច្រឡំនឹងរោគសញ្ញានៃជំងឺដទៃទៀតទេ
លើកលែងតែការពុលដោយសារ Strychnine ប៉ុន្តែជំងឺតេតាណូសច្រើនកើតនៅលើជ្រូកទើបគ្រៀវ ឬ ក៏ជ្រូកដែលមានស្នាមរបួស ។

**វិធីការពារ :**

- លាងសំអាតផ្ចិតកូនជ្រូកទើបកើត
- លាងសំអាតស្នាមរបួស កន្លែងគ្រៀវរួចហើយ

+ ចាក់ Pénicilline 10 000UI ក្នុងទំងន់ជ្រូក ១គក្រ

+ ចាក់ Serum antitétanique 20 000-100 000UI ចាក់សើស្បែក ឬក៏ចាក់ Anatoxine antitétanique 3-5 cc

គារព្យាបាល :

ក្នុងសភាពធ្ងន់ធ្ងរ មិនអាចព្យាបាលជាទេ តែក្នុងសភាពស្រាល យើងអាចព្យាបាលជា ដោយប្រើថ្នាំដូចតទៅនេះ :-

១- Serum antitétanique 10-40 cc ទៅតាមជ្រូកតូច ឬ ធំ

២- Pénicilline 20 000UI ក្នុងទំងន់ជ្រូក ១គក្រ

៣- Streptomycine 20 mg ក្នុងទំងន់ជ្រូក ១គក្រ

៤- Terramycine injectable solution 2-4 cc ក្នុងទំងន់ជ្រូក ៤៥គក្រ ចាក់ម្តងកុំឱ្យលើសពី ១០ cc ។

ដើម្បីទប់កុំឱ្យប្រកាច់ យើងត្រូវចាក់ Largatil ( ឬ Gardénal ) មួយថ្ងៃចាក់បីដង ជ្រូកតូចចាក់ម្តង ១-២ cc ជ្រូកធំ ៥ cc ។

# ជំងឺប៉ារ៉ាស៊ីត

## Maladies parasitaires
## Parasitic diseases

## ជំងឺព្រូនចង្អឹះ

### Ascaris suum

ព្រូនចង្អឹះ ជាជំងឺប៉ារ៉ាស៊ីត ដែលច្រើនកើតមាននៅលើជ្រូក បង្ក ជាមហន្តរាយយ៉ាងធំធេងដល់គ្រប់ប្រភេទជ្រូក ។ ព្រូនរបស់សត្វជ្រូក ឈ្មោះថា (Ascaris lumbricoïde suis ) ទំហំប៉ុនចុងចង្អឹះ ប្រវែង១៥-៣០ សម ។ កូនជ្រូកទើបផ្តាច់ដោះ និង ជ្រូកជំទើ កើតព្រូនចង្អឹះ ច្រើនជាងព្រូនធំ ។ ក្នុងលាមករបស់ជ្រូកកើតព្រូនចង្អឹះ មានពងព្រូន កាលណាជ្រូកស៊ីលាមកនោះ ពងព្រូនក៏ចូលទៅក្នុងពោះវៀន ញាស់ក្លាយ ទៅជាព្រូន ។ កូនព្រូនត្បុលចេញពីពោះវៀន ចូលទៅក្នុងឈាម ឡើង ទៅថ្លើម ទៅបេះដូង ឆ្លងកាត់សួត ឡើងទៅទងសួត ទៅដល់បំពង់ក រួចហើយក៏ត្រូវជ្រូកលេបចូលទៅក្នុងពោះវៀនវិញ ។ កូនព្រូនពេលត្រឡប់ ទៅកាន់ពោះវៀនវិញ ក៏ក្លាយជាព្រូនធំ ហើយតាំងទីលំនៅនៅទីនោះ តែម្តង ។ រស់ជាបញ្ញើនៅទីនោះ បង្កើតជាពង ពងព្រូនធ្វើដំណើរមកក្រៅ ជាមួយលាមក ។ ជ្រូកដទៃទៀត ស៊ីលាមកមានពងព្រូន ពងព្រូនក៏ក្លាយជា

ព្រូន ។ រយៈពេលពីពងព្រូន រហូតដល់ក្លាយជាព្រូនធំ គឺ ១០អាទិត្យ ។ បញ្ហានេះបញ្ជាក់ឱ្យយើងយល់បានថា ហេតុអ្វីបានជាក្នុងពោះកូនជ្រូកនៅបៅដោះមិនទាន់មានព្រូន ។

**រោគសញ្ញា :**

ជាទូទៅស្ទើរតែគ្រប់សត្វជ្រូក សុទ្ធតែមានព្រូនចង្កឹះ បើមានតិចជ្រូកនៅតែមានសុខភាពល្អ តែចិញ្ចឹមក្រធំ ។ កាលណាចំនួនព្រូនមានរហូតដល់ ១០០ ដល់ ២០០ក្បាល នោះនឹងបណ្តាលឱ្យធំពោះ រាគ ស្គមខ្សោយ ក្រធំ ស្បែកលឿង ( ព្រោះព្រូនស៊ុលចូលទៅក្នុងថ្លើម ធ្វើឱ្យស្ទះបំពង់នាំទឹកប្រមាត់ ) កន្ត្រាក់ខ្លួន (ដោយសារជាតិពុល Ascaron ដែលពពួកព្រូនបញ្ចេញមកប៉ះពាល់ដល់សសៃប្រសាទ ) ។ ព្រូនច្រើនអាចបណ្តាលឱ្យស្ទះពោះវៀន បង្កឱ្យមានរបួសធ្ងន់ធ្ងរ តឹងពោះវៀន ធ្វើឱ្យហើមស្រោមពោះ រួចបណ្តាលឱ្យជ្រូកងាប់ ។

**វិធីការពារ :**

- ត្រូវទំលាក់ព្រូនឱ្យមេជ្រូកមុនពេលកើតកូន ដើម្បីកុំឱ្យកូនជ្រូកឆ្លងព្រូនពីមេ ។

មុជទឹក លាងសំអាតមេជ្រូកមុនពេលកើតកូន រួចហើយបញ្ជូនវាទៅកាន់ទ្រុងដែលបានសំអាត អនាម័យរួចហើយ ។

- ត្រូវបញ្ចុះព្រូនឱ្យកូនជ្រូកក្រោយពេលផ្តាច់ដោះ មួយខែម្តងរហូតដល់អាយុ ៤ខែ ។

- ត្រូវចិញ្ចឹមកូនជ្រូកក្នុងទ្រុងស្ងួត ស្អាតបាត

- ទីធ្លាសំរាប់ឱ្យជ្រូកធ្វើចលនា មិនត្រូវមានភក់ជ្រាំ ហើយត្រូវឧស្សាហ៍បាចកំចោរសំលាប់មេរោគ ។

- មិនត្រូវចិញ្ចឹមកូនជ្រូកក្នុងទ្រុងជាមួយជ្រូកធំទេ

- ត្រូវឧស្សាហ៍មុជទឹក ដុសសាប៊ូឱ្យមេជ្រូកបំបៅកូន

- មិនត្រូវឱ្យជ្រូកឈ្មុលត្បុលគំនរលាមកទេ

- ត្រូវមានកន្លែងផ្ចាប់លាមក ហើយត្រូវរោយកំបោរសំលាប់ពងព្រូន ។

ការព្យាបាល :

ថ្នាំទំលាក់ព្រូនដែលគេនិយមប្រើនាពេលបច្ចុប្បន្ននេះគឺ Ivomec ។ ក្រៅពីនេះមានថ្នាំពីរប្រភេទទៀត ដែលមានប្រសិទ្ធិភាពទៅលើព្រូនគឺ :-

- **Tetramisol :** ចាក់សើស្បែក ១០មក្រ ក្នុងទំងន់ជ្រូក ១គក្រ អនុវត្តចំពោះជ្រូកតូច ទំងន់តិចជាង ២០គក្រ ។ ៥-៧មក្រ ក្នុងទំងន់ជ្រូក ១គក្រ ចំពោះជ្រូកធំជាង ២០គក្រ ។ ចំពោះប្រភេទម្សៅ គឺឱ្យផឹក ១ក្រ ក្នុងទំងន់ជ្រូក ២០គក្រ ។

- **Levamisol :** ( ឈ្មោះផ្សេងទៀត Nemisol. Anthelsol. Paglisol. Decaris. Vinacor ) កំរិតចាក់សើស្បែក ៧.៥មក្រ ក្នុងទំងន ជ្រូក ១គក្រ ចំពោះជ្រូកទំងន់ក្រោម ២០គក្រ ។ កំរិត ៥មក្រ ចំពោះជ្រូកទំងន់ពី ២០-៥០គក្រ ។ ចំពោះជ្រូកធំជាង ៦០គក្រ គឺចាក់ ២មក្រ ក្នុងទំងន់ជ្រូក ១គក្រ ។

*ប្រយ័ត្ន :

ត្រូវប្រើតាមកំរិតដែលបានបង្ហាញលើសំបកដប ថ្នាំទាំងពីរប្រភេទខាង លើចាក់ឱ្យជ្រូកនៅពេលណាក៏បានដែរ ទោះបីជាជ្រូកទើបស៊ីឆ្អែតក៏អាចចាក់បាន ។ ថ្នាំទាំងនេះមានប្រសិទ្ធិភាពទៅលើព្រូនច្រើនប្រភេទ រួមទាំងព្រូនសូតផងដែរ។

មានថ្នាំមួយចំនួនទៀត ដែលគេនិយមប្រើដែរនោះគឺ :-

- **Dipterex** : កំរិតប្រើ ០,១២-០,១៥មក្រ ក្នុងទំងន់ជ្រូក ១គក្រ លាយក្នុងចំណីឱ្យជ្រូកស៊ីនៅពេលព្រឹក ( លាយជាមួយចំណីតែបន្តិចបានហើយ ) ។ ប្រើលើសកំរិតបណ្តាលឱ្យជ្រូកប្រកាច់ បែកពពុះមាត់ បើឃើញមានរោគសញ្ញាបែបនេះត្រូវចាក់ថ្នាំបន្សាប ចាក់ Atropin មួយអំពូល ២មល ក្នុងទំងន់ជ្រូក ២០-៣០គក្រ

- **Piperazine** : ( Pixon, Pipcide, Pyrex, Dowzène, Piperazine Wormer Pfizer --- ។ល។ )

កំរិតប្រើ : ០,១៥ក្រ ក្នុងទំងន់ជ្រូក ១គក្រ ឱ្យផឹក ឬ លាយជាមួយចំណី ( ប្រើក្នុងរយៈពេលបីថ្ងៃ )

- **Phenothiazine** : ឱ្យផឹក ០,០២ក្រ ក្នុងទំងន់ជ្រូក ១គក្រ

- **Mebenvet** : ឱ្យផឹក ០,២ក្រ ក្នុងទំងន់ជ្រូក ១គក្រ

- **Hygromycine** : លាយ ១០មក្រ ក្នុងចំណី ១គក្រ ឱ្យស៊ីចាប់តាំងពីពេលផ្តាច់ដោះ រហូតដល់ទំងន់ ៤៥គក្រ ។

ផ្លែស្លា :

ក- ស្លាខ្ចី :

មុនពេលផ្តាច់ដោះ យកស្លាខ្ចី ( ១/៤ នៃផ្លែ ) ជំឱ្យហួត ឱ្យជ្រូកស៊ី ៧ថ្ងៃម្តង រហូតដល់ពេលផ្តាច់ដោះ ។ ក្រោយពេលផ្តាច់ដោះ ឱ្យស៊ីពាក់កណ្តាលផ្លែ (១/២ នៃផ្លែ ) ៧ថ្ងៃឱ្យស៊ីម្តង រហូតដល់អាយុ ៣ខែ ។ ចាប់ពីអាយុ ៣-៦ខែ ៧ថ្ងៃ ឱ្យស៊ីម្តង ក្នុងម្តងឱ្យស៊ីមួយផ្លែ ។

ខ- ស្លាទុំ :

បើប្រើផ្លែស្លាទុំ ត្រូវកិនឱ្យហួត ឱ្យស៊ី ៥ - ២០ក្រ ទៅតាមជ្រូកតូច ឬ ធំ ។

## ជំងឺព្រូនសួត

**Métastrongylosis**

ជំងឺព្រូននៅសួត ក៏ជាជាជំងឺប៉ារ៉ាស៊ីត កើតមាននៅលើជ្រូកនៅគ្រប់ទីសទីក្នុងប្រទេសយើង ។ ជំងឺនេះបង្កឡើងដោយព្រូន Métastrongylus elongatus ប្រវែង ២-៣សម រាងមូល ទំហំប៉ុនម្ជុល រស់នៅក្នុងទងសួត និង ក្នុង ផ្លូវដង្ហើម ។ កាលណាព្រូនតិច បណ្តាលឱ្យជ្រូករមាស់ក ក្អក ។ កាលណាព្រូនច្រើន ធ្វើឱ្យស្ទះបំពង់ខ្យល់ បណ្តាលឱ្យជ្រូកងាប់ដោយថប់ដង្ហើម ។

នៅក្នុងផ្លូវដង្ហើម បំពង់ក ( Trachée artère ) ព្រូនបង្កើតពង ។ ពងព្រូនស្អិតជាប់នឹងកំហាក ធ្លាក់ចូលក្នុងមាត់ ជ្រូកលេបចូលទៅក្នុងពោះវៀន ហើយចេញមកក្រៅតាមលាមក ។ ពពួកដង្កូវ ជន្លេន ស៊ីលាមកនោះដោយទាំងពងព្រូន ហើយជ្រូកដែលចិញ្ចឹមលែង ឈ្មុសដីស៊ីដោយជន្លេនដែលមានពងព្រូន ក៏កើតព្រូន។ នៅក្នុងពោះវៀន ពងព្រូនញាស់ក្លាយជាកូនព្រូន កូនព្រូនធ្លុងកាត់ពោះវៀនចូលទៅក្នុងឈាម ឡើងទៅសួត តាំងទីលំនៅនៅទីនោះបង្កឱ្យមានជំងឺ និង ផ្តល់ពងព្រូន បន្តការចំលងព្រូនទៅជ្រូកដទៃទៀត ។

**រោគសញ្ញា** :

ដែលស្រួលសំគាល់ជាងគេនោះគឺ ជ្រូកក្អក តែមិនឡើងកំដៅខ្លួនទេ ជ្រូកឈឺ ក្អកខ្លាំង ហត់ ពិបាកដកដង្ហើម ខាកចេញស្លេស ស៊ីចុកធម្មតា តែចិញ្ចឹមក្រជំ ។

**វិធីការពារ និង ព្យាបាល** :

កុំលែងជ្រូកឱ្យឈ្មុសដី រួចហើយត្រូវមានវិធានការការពារដូចគ្នានឹងជំងឺព្រូនចង្កឹះ ។

- លាយថ្នាំ Piperazine 0,5g ក្នុង ១គក្រ ចំណី

**កំណត់សំគាល់** :

ក្នុងពេលដែលយើងប្រើថ្នាំបញ្ចុះព្រូនចង្កឹះ នោះពងព្រូន Métas-tron-gylus ក៏ត្រូវបញ្ចុះចេញក្រៅដែរ ។

# ជំងឺចុងអង្ករ

## Ladrerie

---

ជំងឺចុងអង្ករ ជាជំងឺបណ្ដាលមកពីពងព្រូនសំប៉ែត Taenia solium របស់មនុស្ស ។ គ្រាប់អង្ករដែលយើងឃើញក្នុងសាច់នោះ គឺជាពង Cysticercus cellulosae នៃព្រូន Taenia solium ។

មនុស្សដែលមានព្រូនសំប៉ែត ក្នុងលាមកតែងមានកំណាត់ព្រូនសំប៉ែត ។ ក្នុងកំណាត់ព្រូនសំប៉ែតមួយកង់ៗ មានពងព្រូនច្រើនណាស់ ។ ជ្រូកដែលស៊ីលាមកមនុស្ស ដោយទាំងកំណាត់ព្រូនចូលដល់ក្នុងពោះវៀន ពងនីមួយៗញាស់ចេញជាដង្កូវមួយ ដង្កូវព្រូនចូលទៅក្នុងឈាម ហើយធ្វើដំណើរទៅគ្រប់សាច់ដុំ ហើយស្ថិតនៅទីនោះ បង្កើតបានជាចុងអង្ករ ពីព្រោះវាមានទំហំ និង ពណ៌សល្អក់ដូចគ្រាប់អង្ករ ។ សាច់កន្លែងណាដែលមានសកម្មភាពខ្លាំង សាច់កន្លែងនោះសំបូរចុងអង្ករ ដូចជា បេះដូង សន្ទះខ័ណ្ឌពោះ និង ទ្រូង សាច់ថ្គាល់ អណ្ដាត សាច់ភ្លៅ ។ ល ។

មនុស្សណាហូបណែម ( ធ្វើពីសាច់ឆៅ ) អាចមានគ្រោះថ្នាក់ដោយសារសាច់ដែលគេយកមកធ្វើណែមនោះមានពងព្រូន ។ ក្នុងមនុស្សម្នាក់អាចមានព្រូនសំប៉ែតក្នុងពោះវៀនតែមួយក្បាលប៉ុណ្ណោះ ។

**រោគសញ្ញា :**

គ្មានរោគសញ្ញាច្បាស់លាស់ទេ ជ្រូកដែលមានជំងឺចុងអង្ករ មានសុខភាពធម្មតា ។ បើចុងអង្ករមាននៅលើអណ្ដាត វាបណ្ដាលឱ្យស្ពឹក

អណ្តាត បើមាននៅលើជើង នោះនឹងបណ្តាលឱ្យពិបាកដើរ ។ បើកើតមានសព្ទទឹកខ្លែង វាអាចបណ្តាលឱ្យរលាកពោះវៀន រលាកថ្លើម និងរលាកសាច់ដុំ ពេលនោះរោគសញ្ញារបស់វាគឺ មិនសូវស៊ីចំណី រាគ ចុះស្គមស្លឹកស្រពន់ ហើយអាចងាប់ ។

**វិធីការពារ :**

កុំចិញ្ចឹមជ្រូកលែងឱ្យដើរស៊ីពាសវាលពាសកាល ដោយទាំងលាមកមនុស្ស ។ កុំឱ្យក្មេងជុះដាក់ទ្រុងជ្រូក ឬ ក៏ជុះតែពីសតែពាស ព្រោះសត្វកណ្តុរ សត្វរុយ អាចពាំនាំពងព្រូនទៅលើចំណីរបស់ជ្រូក ។

**ការព្យាបាល :**

គ្មានថ្នាំព្យាបាលជ្រូកកើតជំងឺចុងអង្គរទេ ។

## ជំងឺកមរមាស់

**Gale**

—

ជំងឺកមរមាស់ ជាជំងឺចាក់ស៊ីតសើស្បែក បង្កឡើងដោយចៃពីរប្រភេទ គឺ Sarcoptes Scabiei var-suis និង demodex phylloides ដែលបណ្តាលឱ្យជ្រូករមាស់ ពិបាកទ្រាំ ត្រដុសមិនឈប់ រង្គោះរោម មិនសូវស៊ី មិនសូវដេក ចុះស្គម បង្កជាលក្ខណៈអំណោយផលដល់មេរោគដទៃទៀតចូលរាតត្បាតទៅលើខ្លួនជ្រូក ។

រោគសញ្ញា :

ជំងឺនេះច្រើនកើតមាននៅលើកូនជ្រូកចិញ្ចឹមរួមបណ្តាលឱ្យស្បែកមានជំងឺរលាកយ៉ាងធ្ងន់ធ្ងរ ។ សត្វចៃនេះធ្វើរន្ធនៅក្នុងស្បែក ខ្លួនរបស់វាមានទំហំតូច ពណ៌ប្រផេះ ប្រវែង ០,៥០មម មើលនឹងភ្នែកទទេមិនឃើញទេ ។ បើចង់ឃើញចៃនេះ ត្រូវយកកូនកាំបិតមុតកោសរោមចេញ រួចហើយយកកែវពង្រីក ( Loupe ) ឆ្លុះមើលទើបឃើញ ។ ជាទូទៅជំងឺកមរមាស់ ច្រើនកើតមាននៅលើត្រចៀក ជុំវិញមាត់ ភ្នែក និងនៅកន្លែងស្បែកស្តើង រោមតិច បណ្តាលឱ្យរមាស់ខ្លាំង របក ស្បែកកើតជាក្រមរពណ៌ប្រផេះ ឬ ក្រមៅ ។ ក្រមររបកទាំងផ្ទាំង កូនជ្រូកចុះស្គម ស្បែកជ្រួញ ភ្នែកបិទ រង្គោះរោម ហើយអាចបណ្តាលឱ្យកូនជ្រូកងាប់ ។

ជំងឺរមាស់ អាចឆ្លងដល់មនុស្ស និង សត្វដទៃទៀត ។

វិធីការពារ និង ព្យាបាល :

កាលណាជំងឺនេះទើបកើតមាន យើងស្រួលព្យាបាលទេ តែដល់ពេលកើតពេញខ្លួន រង្គោះរោមអស់ ស្បែកចេញទឹករងៃ គឺត្រូវព្យាបាលយូរពេលណាស់ ។

ដើម្បីព្យាបាលជំងឺរមាស់ឱ្យមានប្រសិទ្ធិភាព ត្រូវអនុវត្តវិធានការបីយ៉ាង ដូចតទៅ :-

- សំលាប់ចៃដែលបង្កឱ្យមានជំងឺកមរមាស់
- ទប់ស្កាត់កុំឱ្យជំងឺនេះរាលដាលទៅកន្លែងដទៃទៀត

. បំប៉នជ្រូកដែលមានជំងឺកមរមាស់ ដើម្បីឱ្យវាមានកំលាំងប្រយុទ្ធប្រឆាំងនឹងជំងឺ ។

ដំបូងត្រូវកោសរោមកន្លែងកើតរមាស់ យកច្រាសរូសកន្លែងរមាស់ជាមួយទឹកក្តៅឧណ្ហៗនិងសាប៊ូ ដើម្បីឱ្យចៃចេញពីរន្ធលាក់ខ្លួន ងាយស្រួលដល់ការលាបថ្នាំរបស់យើង ដើម្បីឱ្យថ្នាំនោះប៉ះផ្ទាល់នឹងសត្វចៃ ។ របៀបលាបថ្នាំ គឺយើងលាបជុំវិញកន្លែងរមាស់ជាមុន សឹមលាបកន្លែងរមាស់ជាក្រោយ លាបក៏បាន ឬ ក៏លាយក្នុងទឹកឱ្យជ្រូកត្រាំ មួយអាទិត្យពីរដង ។

ក –

| | |
|---|---|
| - Sulfure de potassium | ៥ក្រ |
| - ទឹក | ១ល |

ខ –

| | |
|---|---|
| . ស្ពាន់ធ័រ | ១០០ក្រ |
| . កំបោររស់ | ៥០ក្រ |
| . ទឹក | ៥ល |

យកក្រណាត់ខ្ចប់ស្ពាន់ធ័រ និង កំបោររស់ ដាក់ក្នុងធុងទឹក ៥លីត្រ ដាំឱ្យពុះក្នុងរយៈពេលពីរម៉ោង ទុកឱ្យត្រជាក់សឹមយកមកប្រើ ។

ក្នុងរយៈពេលកំពុងព្យាបាលជំងឺនេះ ត្រូវបំប៉នជ្រូកដោយចំណីល្អរួច ហើយចាក់ វីតាមីន C ឱ្យជ្រូកផង ។

ជំងឺកមរមាស់ឆ្លងរាលដាលរហ័សណាស់ ដូច្នេះកាលណាឃើញកូនជ្រូកណាមួយកើតរមាស់ ត្រូវយកចេញ ទុកដោយឡែក ហើយត្រូវ

សំអាតអនាម័យទ្រុងចិញ្ចឹម ដោយទឹកក្រេស៊ីល ឬ ក៏យកអង្កាម ចំបើង ស្មៅស្ងួត រោយស្ពាន់ធ័រ ដុតបង្ហុយផ្សែង សំលាប់ចៃនេះនៅលើកំរាល និង កៀនកោះប្រឡោះទ្រុង ។

ជំងឺកមរមាស់ មិនសូវកើតមាននៅលើកូនជ្រូកដែលមានសុខភាព ល្អទេ ។ ដូច្នេះអនាម័យទ្រុង ចំណីអាហារ និង ទឹកផឹក ជាវិធានការ ដ៏ប្រសើរ សំរាប់ទប់ស្កាត់ការកើតមានជំងឺកមរមាស់ ។

## ជំងឺកុកស៊ីឌីយូស

**Coccidiose**

**Coccidiosis ( Isospora.Suis )**

កូនជ្រូកក្រោយពេលផ្តាច់ដោះ លែងឱ្យដើររកស៊ីចំណីក្នុងធ្លាមាន ភក់ជ្រាំ ខ្វះអនាម័យ ច្រើនកើតជំងឺនេះ ។

ជំងឺកុកស៊ីឌីយូស បង្កឡើងដោយប៉ារ៉ាស៊ីតមួយប្រភេទ រស់ក្នុង កោសិកានៃភ្នាសពោះវៀន ។ ជ្រូកដែលកើតមានជំងឺ គឺដោយសារស៊ីចំណី ឬ ក៏ផឹកទឹកមាន ពងប៉ារ៉ាស៊ីត ( Oocysts ) នេះ ។

រោគសញ្ញា :

ស្លេកចេញយឹក ។ ខ្ជិលស៊ីចំណី ក្រធំ ស្គមទៅៗ មិនដូចនៅលើ

សត្វគោ ឬ សត្វមាន់ទេ ជ្រូកដែលកើតជំងឺនេះ ជួនកាលទល់លាមក ជួនកាលរាគ តែគ្មានឈាមទេ ។ នៅពេលដែលយើងឃើញជ្រូករាគ នោះជាសញ្ញាប្រាប់ថា ជ្រូកនោះជិតងាប់ហើយ ។

**វិធីការពារ :**

មិនត្រូវលែងកូនជ្រូក ឱ្យដើររកស៊ីក្នុងធ្លាមានភក់ជ្រាំ ខ្វះអនាម័យទេ ។ គប្បីលើកដីក្នុងធ្លាឱ្យខ្ពស់ កុំឱ្យមានភក់ជ្រាំ រួចហើយធ្វើអនាម័យបាចកំបោរ មួយឆ្នាំពីរដង ។ ទឹកផឹកត្រូវឱ្យស្អាត កុំឱ្យកណ្តុរ កន្លាតវារកាត់នៅកន្លែងដែលធ្លាប់មានជំងឺនេះ ត្រូវឱ្យកូនជ្រូកផឹកថ្នាំការពារ ។ ប្រើថ្នាំណាមួយក្នុងចំណោមថ្នាំខាងក្រោមនេះ :-

Sulfaquinoxaline, Sulmet, Nicarbazine, Furazone, High Furan, Nitrofurazone, Triple Sulfa --- 0,50g លាយទឹកមួយលីត្រ ឱ្យផឹកដោយសេរី ។ បើមានកូនជ្រូកណាមួយក្នុងហ្វូងឈឺ ត្រូវប្រើលើសកំរិតខាងលើមួយជាពីរ គឺ ១ក្រ ក្នុងទឹកមួយលីត្រ ។ ឱ្យជ្រូកផឹកថ្នាំដែលបានលាយហើយនេះបីថ្ងៃ រួចឱ្យផឹក Bicarbonate de soude ៣ថ្ងៃ ២ ‰ ( ២ក្រ ក្នុងទឹក ១ល ) ផ្លាស់ប្តូរឱ្យជ្រូកផឹកថ្នាំរបៀបនេះ រហូតដល់អាយុ ៤ខែ ឬ ក៏លាយថ្នាំ Coccidiostat ក្នុងចំណីឱ្យកូនជ្រូក ( ១០០ក្រ ក្នុង ១០០គក្រ ចំណី ) ឱ្យស៊ីតាំងពីតូចរហូតដល់អាយុ ៤ខែ ។

**ការព្យាបាល :**

យើងពិបាកព្យាបាលជំងឺនេះឱ្យជាដាច់ស្រឡះ ព្រោះប៉ារ៉ាស៊ីតនេះធាប់ស៊ាល់ ( ស៊ាំ ) ថ្នាំណាស់ ។ ដូច្នេះបើព្យាបាលដោយថ្នាំណាមួយ

ក្នុងរយៈពេលបីថ្ងៃហើយ ជំងឺមិនធូរស្បើយត្រូវដូរថ្នាំភ្លាម គប្បីប្រើថ្នាំថ្លៃថោកជាមុន រួចហើយសឹមប្រើថ្នាំថ្លៃខ្ពស់ជាក្រោយ ។

ត្រូវចាប់កូនជ្រូកម្តងមួយៗ ឱ្យផឹកថ្នាំនេះ ។ អាចប្រើថ្នាំណាមួយក្នុងចំណោមថ្នាំខាងក្រោម ដើម្បីឱ្យកូនជ្រូកផឹកក្នុងរយៈពេលបីថ្ងៃ :-

- **Quinoxaline** លាយទឹកឱ្យផឹក ២០មក្រ ក្នុងទំងន់ជ្រូក ១គក្រ

- **Thymol** ០,៥ក្រ ក្នុងជ្រូក ១ក្បាល ( លាយជាមួយ ៥០ cc ប្រេងសណ្តែកដី )

- **Terramycine Animal formula** ឬ **Auréomycine** 20mg ក្នុងទំងន់ជ្រូក ១គក្រ ( លាយជាមួយទឹកឱ្យផឹក )

- **Terramycine triple sulfa, Auréomycine triple sulfa** 30mg ក្នុងទំងន់ជ្រូក ១គក្រ

- អាចប្រើប្រភេទថ្នាំ Sulfamide ណាមួយក្នុងចំណោមថ្នាំខាងក្រោម Sulfaquinoxaline, Sulmet, Nicarbazine, Furazone, Triple Sulfa, Nitrofurazone ។ល។ លាយទឹកឱ្យល្មមផឹកអស់ : ២០០មក្រ ក្នុងទំងន់ជ្រូក ១គក្រ ។

ក្នុងពេលព្យាបាលគប្បីឱ្យជ្រូកស៊ីចំណីស្រួលរំលាយ សំបូរជាតិប្រូតេអ៊ីន (ម្សៅទឹកដោះ ) សំបូរវីតាមីន A សំបូរបន្លែស្រស់ ( សាឡាដ ត្រកួនជំឡូងជ្វា ) ដើម្បីបង្កើនលទ្ធភាពប្រឆាំងជំងឺ ។

# ជំងឺមេជ្រូក

## ជំងឺពិបាកកើតកូន

ជ្រូកដែលចិញ្ចឹមលែងក្នុងផ្ទាទូលាយ ធ្វើចលនាដើរចុះឡើងច្រើន ស្រួលកើតកូន ដូចជាជ្រូកព្រៃយ៉ាងដូច្នោះដែរ ។ ជិតដល់ថ្ងៃកើត មេជ្រូកពាំស្មៅ ពាំចំបើង រកកន្លែងស្ងាត់ កាច់សំបុកសំរាប់កើតកូន ។

ជ្រូកដែលចិញ្ចឹមក្នុងទ្រុងចង្អៀត ច្រើនជួបបញ្ហាពិបាកកើតកូន ពិសេសមេជ្រូកកើតកូនលើកដំបូង ។

មូលហេតុដែលបណ្តាលឱ្យមេជ្រូកពិបាកកើតកូនមកពី :-

**កូនដេកមិនចំកន្លែង ( ខុសទីតាំង ) :**

- កូនដេកផ្ងារ : ជើងមុខទាំងពីរលើកឡើងលើ
- ជើងមុខទាំងពីចេញមុន តែច្រមុះងោកទៅរកទ្រូង
- ច្រមុះចេញមុន តែជើងមុខទាំងពីរទម្លាក់មករកទ្រូង
- កូនដេកទទឹង : ខ្នង ឬ ចង្កេះចេញមុន
- កូនដេកបញ្ច្រាស : គូទចេញមុន
- កូនដេកចំកន្លែង ស្រួលកើត : កាលណាវាដេកផ្កាប់ ច្រមុះហើយនឹងជើងមុខទាំងពីរចេញមុន ឬក៏ពេលណាវាដេកផ្កាប់ ហើយជើងក្រោយទាំងពីរចេញ តំណាលគ្នា ។

### កូនធំពេក :

កូនធំពេក ពិបាកនឹងចេញរួចពីកស្បូនណាស់ ជួនកាលមានកូនធំតែមួយរាំងស្ទះដល់កូនដទៃទៀត មិនឱ្យចេញរួច ។ បើមិនជួយធ្វើអន្តរាគមន៍ទេ នោះនឹងបណ្ដាលឱ្យងាប់កូនទាំងសំបុកតែម្ដង ។

### កូនងាប់ហើមក្នុងពោះ :

ប្រសិនបើយើងអាចទាញកូនដែលងាប់ឱ្យចេញក្រៅបាន នោះអាចជួយ ជីវិតកូនដទៃទៀត តែបើមេប្រឹងកើតហើយកូននៅតែមិនព្រមចេញក្នុងករណីនេះ បើធ្វើអន្តរាគមន៍មិនទាន់ទេ នោះកូនទាំងអស់នឹងងាប់ដោយសាររហែកស្បូន ។

### កូនចាស់ខែ ថ្ងៃ :

កាលណាដល់ថ្ងៃកើតហើយ កូនមិនកើត នោះវាកាន់តែធំ ធ្វើឱ្យតឹងស្បូន កើតមិនរួច បណ្ដាលឱ្យកូនងាប់ក្នុងពោះ ។

### កូនងាប់ក្រៀមក្នុងពោះ :

មានករណីខ្លះកូនជ្រូកងាប់ក្រៀមក្នុងស្បូនយូរហើយ ជួនកាលកូនងាប់ក្រៀមក្នុងស្បូននេះ ស្រួលចេញមកក្រៅ ជួនកាលស្ទះក្នុងស្បូនមិនព្រមចេញ ។

### ឆ្អឹងត្រគាក និង ទ្វារចង្អៀត :

មេជ្រូកដែលចិញ្ចឹមក្នុងទ្រុងចង្អៀត មិនបានធ្វើចលនា ហើយចំណីខ្វះជាតិកាល់ស្យូម និង ផូសស្វ័រ ច្រើនមានឆ្អឹងត្រគាកចង្អៀត ពិបាកកើតកូន ។ ជួនកាលទ្វារតូចចង្អៀតពេក ក៏បណ្ដាលឱ្យពិបាកកើតកូនដែរ ។

## មេខ្ជិលមិនប្រឹងបញ្ចេញកូន :

មេជ្រូកធាត់ និង មេចាស់ ច្រើនខ្ជិលប្រឹង ដោយសារមេជ្រូកខ្ជិលប្រឹង ទោះជាកូនតូចក៏មិនអាចចេញរួចដែរ ។

## រោគសញ្ញា :

ជ្រូកច្រើនកើតកូននៅពេលយប់ កម្រកើតនៅពេលថ្ងៃណាស់ ។ កាលណាឃើញទ្វារហើមធំ ដោះរីក មានទឹកដោះខាប់ និង មានទឹករំអិលហូរចេញ នោះបញ្ជាក់ថាមេជ្រូកជិតកើតកូនហើយ ។ កាលណាឃើញមានសញ្ញាដូចខាងលើនេះ ហើយ ៥-៦ម៉ោងក្រោយ មេជ្រូកនៅតែមិនទាន់កើត នោះបញ្ជាក់ថាមានបញ្ហាហើយ ។ ជួនកាលកើតបានកូន ២-៣ ហើយ ស្រាប់តែឈប់កើត ត្រូវជួយធ្វើអន្តរាគមន៍ជាបន្ទាន់ :-

កាលណាមេប្រឹងហើយ នៅតែមិនព្រមកើត ត្រូវពិនិត្យមើលទីតាំង និង សភាពរបស់កូនក្នុងពោះ ព្រមទាំងសភាពទ្វាររបស់មេជ្រូក ។

## ពិនិត្យទីតាំងរបស់កូន :

ឱ្យមេជ្រូកដេកសៀម ផ្អៀងមកម្ខាង សណ្តូកជើងទាំងបួន ។ លាងសំអាតទ្វារដោយទឹកស្អាត និង សាប៊ូ រួចហើយពាក់ស្រោមដៃដែលបានសំអាតអនាម័យរួចហើយ លាបប្រេងដូងឱ្យរអិល រួចហើយក្តោបម្រាមដៃរុញចូលក្នុងទ្វារបន្តិចម្តងៗ កាលណាមេប្រឹង ត្រូវឈប់រុញដៃ ។ ចូលជម្រៅប្រហែល ០,២៥ម ដល់ទ្វារ ពិនិត្យមើលឆ្អឹងត្រគៀក ចង្អៀត ឬទូលាយ រុញចូលទៅក្នុងទៀតប្រហែល ០,៤០ម យើងអាចពិនិត្យដឹងពីសភាពរបស់កូនជ្រូក ។ អន្តរាគមន៍ គឺអាស្រ័យទៅនឹងមូលហេតុ :-

បើកូនដេកទទឹង ត្រូវសំរួលវាឱ្យស្រួលមកវិញ ។ បើកូនធំពេក ទោះជាមេប្រឹងយ៉ាងណា ក៏នៅតែកើតមិនរួចដែរ មេប្រឹងយូរនឹងអស់ជាតិរំអិល កូនស្ងួត ដូច្នេះត្រូវធ្វើយ៉ាងណាឱ្យទ្វារ និង ស្បូនរអិល យកទុយោកៅស៊ូចាញ់បញ្ចូលប្រេងដូង ឬ ប្រេងសណ្តែកទៅខាងក្នុង រួចហើយយកដៃក្តោបជើងទាំងពីរ ហើយទាញចេញបន្តិចម្តងៗ ។ កាលណាកូនងាប់ហើម : បើទើបនឹងហើម យើងអាចយកចេញទាំងមូល តែបើហើមយូរហើយពេលទាញចេញអាចដាច់ជាកំណាត់ៗ ត្រូវយកបំណែកកូនដែលងាប់ហើមនោះឱ្យអស់ រួចហើយចាក់ Pénicilline, Strepto-mycine, Vitamine C, Vitamine Bécomplexe --- ។ល។ បើកូនចាស់ខែ: កាលណាកូនធំពេក យើងមិនអាចទាញចេញតាមទ្វារបានទេ ត្រូវតែវះយកកូនចេញ ។ បើកូនងាប់ក្រៀមក្នុងស្បូន : បើសិនជាកូនងាប់ក្រៀមក្នុងស្បូន យើងគ្រាន់តែចាក់ Post- hypophyse 10 UI នោះវានឹងធ្លាក់ចេញដោយមិនបាច់ទាញទេ ។ ក្នុងករណីឆ្អឹងត្រគៀកតូច ទ្វារចង្អៀត ទោះជាកូនមិនធំក៏ពិបាកកើតចេញដែរ យកដៃទាញក៏មិនកើត ត្រូវយកដង្កៀបវែងចាប់ទាញជើង កាលណាយើងកៀបទាញចេញបានមួយហើយ កូនក្រោយៗទៀតស្រួលទាញចេញទេ ។

គប្បីចាំថា កាលណាចំណីខ្វះកាល់ស្យូម និង ផូស្វ័រ នោះឆ្អឹងត្រគៀកក៏តូច កូនក៏តូច ដូច្នេះមិនពិបាកទាញចេញទេ មានករណីខ្លះដែលមេក្មេងមិនបានធ្វើចលនា នោះឆ្អឹងត្រគៀកក៏មិនរីកដែរ ។ បើមិនអាចប្រើដង្កៀបកៀបចេញទេ នោះមានវិធីតែម្យ៉ាងគត់ គឺវះយកកូនចេញ ។

*ប្រយ័ត្ន !

ថ្នាំ Post hypophyse មានប្រតិកម្មកន្ត្រាក់ស្បូន និង សរសៃឈាម ។ ចាក់ថ្នាំនេះហើយ ៥នាទី មេនឹងប្រឹងកើត ហើយដោះឡើងស្លេក ថ្នាំនេះអាចចូលទៅក្នុងខ្លួនកូនជ្រូក កន្ត្រាក់សរសៃឈាម បង្កឱ្យមានបញ្ហា ដូច្នេះត្រូវប្រយ័ត្ន កូនកើតមកងាប់ដោយសារហូរឈាម ។ ពេលកូនកើតចេញភ្លាម ត្រូវចងទងផ្ចិតឱ្យណែន បើធ្វើមិនទាន់ទេឈាមអាចហូរចេញដោយសារឥទ្ធិពលនៃថ្នាំនេះ កូនដែលកើតមកខ្វះឈាម សស្លេក ស្គមស្គាំង ពិបាកចិញ្ចឹមណាស់ ។

យើងអាចប្រើថ្នាំ Post hypophyse តែក្នុងករណីមេខ្ជិលប្រឹង ឬក៏ ពិបាកកើតតែប៉ុណ្ណោះ ។

វិធីការពារ :

ត្រូវជ្រើសរើសមេជ្រូកដែលមានត្រគៀករីកធំ ស្រួលកើតកូន ។ ចំណីត្រូវមានជីវជាតិគ្រប់គ្រាន់ និងត្រូវមានធ្លាឱ្យមេជ្រូកធ្វើចលនា ដើម្បីឱ្យឆ្អឹងត្រគៀករីក ហើយដល់ថ្ងៃកើត មេមិនពិបាកប្រឹង ។

របៀបវះមេជ្រូក ក្នុងករណីពិបាកយកកូនចេញ :

- ប្រើថ្នាំសន្លប់ Ether 120-150ml ឬ ក៏ប្រើ Pentobarbital-Natri 0,5-1g / មេទំងន់ ១០០គក្រ ។ ចាក់សរសៃអាចឱ្យសន្លប់ :១៥-២០នាទី បើវះយូរជាងនេះ ត្រូវចាក់ថ្នាំសន្លប់បន្ថែម ។

- ចាក់ថ្នាំស្ពឹកនៅកន្លែងវះ ដោយប្រើ Novocaine 3% = 30ml ចាក់ជុំវិញកន្លែងវះ ចំងាយ ២០សម ។

- ចាក់ថ្នាំឃាត់ឈាម Vit. K 15mg ចាក់មុនពេលវះ ១៥-២០នាទី

**ការវះ :**

នៅចង្កេះខាងឆ្វេង ឬ ខាងស្តាំ ចន្លោះឆ្អឹងភ្លៅ និង ឆ្អឹងជំនីខាងក្រោយបំផុត ចុះពីឆ្អឹងខ្នងប្រហែល ២០សម ខាងមុខឆ្អឹងភ្លៅប្រហែល ១០សម ( ទៅ តាមជ្រូកតូច ឬ ធំ ) ។ ក្រោយពេលចាក់ថ្នាំទាំងប៉ុន្មានខាងលើឱ្យជ្រូកសន្លប់ហើយ ត្រូវកោររោមកន្លែងវះ លាងអាល់កុល ៧០°C ។ វះពីលើចុះក្រោមប្រវែង ១៥-២០សម ទាញដៃស្បូនចេញក្រៅ រួចហើយវះដៃស្បូនទាញកូន និង សុកចេញ យកចេញយឺតៗ ធ្វើម្តងមួយចំហៀង ។ ក្រោយពេលយកកូន និង សុកចេញអស់ហើយ ត្រូវយកថ្នាំ Pénicilline ៣-៥ដប រោយទៅក្នុងស្បូន និង កន្លែងវះ ឬក៏ ម្សៅ Sulfamide 5g រោយទៅលើកន្លែងវះដូចខាងលើ រួចហើយដេរភ្ជិតវិញ ( ដេរស្បូន ដេរស្បែកពោះ ដេរសាច់ និង ដេរស្បែក ) ។ ក្រោយពេលវះហើយត្រូវចាក់ថ្នាំជំនួយកំលាំង ជំនួយបេះដូង ថ្នាំឱ្យមានទឹកដោះ និង អង់ទីប៊ីយ៉ូទីក ។

**ថ្នាំអង់ទីប៊ីយ៉ូទីក :**

- **Pénicilline** 15 000 UI ក្នុងទំងន់ជ្រូក ១គក្រ ចាក់មួយថ្ងៃម្តងក្នុងរវាង ៣-៤ថ្ងៃ ។

- **Ampicilline** 50mg ក្នុងទំងន់ជ្រូក ១គក្រ ចាក់សាច់ រយះពេលបីថ្ងៃ ឬក៏ **Tétracycline** 20mg ក្នុងទំងន់ជ្រូក ១គក្រ ចាក់សាច់ ១ថ្ងៃម្តង ចាក់ ៣-៤ថ្ងៃ ។

ឬក៏ Suanovil ឬ Tylan 50 ចាក់សាច់ ១មល ក្នុងទំងន់ជ្រូក ៥គក្រ ឬក៏ចាក់សរសៃ ១មល ក្នុងទំងន់ជ្រូក ១០គក្រ ១ថ្ងៃចាក់ម្តង ក្នុងរវាងរយៈពេល ៣-៤ថ្ងៃ ។

ឬក៏ Septotryl 1ml ក្នុងទំងន់ជ្រូក ១៥គក្រ

ឬក៏ Tétramydan 1ml ក្នុងទំងន់ជ្រូក ៤គក្រ ចាក់សាច់ បើចាក់សរសៃ ១មល ក្នុងទំងន់ជ្រូក ៥គក្រ ចាក់ ៤-៥ ថ្ងៃ ។

**ថ្នាំបង្កើនកំលាំង :**

- Vit. B1 200mg ( ស្មើនឹង ២ អំពូល ៥cc ) ចាក់សាច់ ១ថ្ងៃម្តង ចាក់ ៥-៧ថ្ងៃ ។

- Vit. B12 1000µg ចាក់សាច់ ៥-៧ថ្ងៃ

- Vit. C 2g ( ស្មើនឹង ៤អំពូល ៥cc ) ចាក់សាច់ក៏បាន សរសៃក៏បាន ១ថ្ងៃចាក់ម្តង ចាក់រយៈពេល ៥-៧ថ្ងៃ ។

- Bécozyme ចាក់សាច់ ឬ សរសៃ ១ថ្ងៃ ១-២អំពូល ឬ Bécomplexe ចាក់សាច់ ឬ សរសៃ ១ថ្ងៃ ៤-៦អំពូល

- Sirepa 3-5 cc ចាក់សាច់ ១ថ្ងៃម្តង ចាក់ ៤-៥ថ្ងៃ

បើជ្រូកខ្សោយចាក់ Sérum glucosé 5% = 500ml ក្នុង១ថ្ងៃ ។

**ថ្នាំជំនួយបេះដូង :**

- Camphora 10% = 10ml ចាក់សាច់ ១ថ្ងៃម្តង ចាក់ ៥-៧ថ្ងៃ

ថ្នាំឱ្យចេញទឹកដោះ :

- Thyrosine 2mg ចាក់សាច់ ១ថ្ងៃម្តង ចាក់ ៣-៥ថ្ងៃ ( អំពូល ១មល = ១មក្រ ) ។ នៅលើទីផ្សារមានប្រភេទថ្នាំគ្រាប់ ថ្នាំទឹក សំរាប់លាយក្នុងចំណី ។

## ជំងឺរលាកដោះ

**Mammite**
**Mastitis**

ជំងឺរលាកដោះ ច្រើនកើតមាននៅលើមេជ្រូកក្រោយពេលកើតកូនបាន ៤ - ៥ម៉ោង រហូតដល់ ៧ - ៨ថ្ងៃ បង្កឡើងដោយសារមេរោគ Staphylocoques និង Steptocoques ។

មូលហេតុដែលបណ្តាលឱ្យមានជំងឺរលាកដោះ គឺដោយសារ :-

- កូនជ្រូកមានធ្មេញមុតស្រួច ពេលបៅធ្វើឱ្យដោះរបួស បើកផ្លូវឱ្យមេរោគរាតត្បាត បង្កជាជំងឺហើមដោះ ។

- មកពីមេជ្រូកស៊ីចំណីសំបូរជាតិសាច់ ទឹកដោះចេញច្រើន កូនបៅមិនអស់ កកស្ទះក្នុងដោះ បង្កលក្ខណៈងាយស្រួលឱ្យមេរោគរាតត្បាត ។

- មេជ្រូកឱ្យកូនបៅដោះតែមួយជួរ ហើយមួយជួរទៀតដោះឡើងតឹង ដោយសារនៅសល់ទឹកដោះ ក៏បណ្តាលឱ្យរលាក ។

រោគសញ្ញា :

- ដោះហើម ក្រហម រឹង
- ក្តៅខ្លួន អត់ស៊ីចំណី ឬក៏ស៊ីតិច
- អត់ចេញទឹកដោះ ឬក៏ចេញតិច
- ទឹកដោះ ពីដោះដែលរលាក មានខ្ទុះពណ៌លឿង

ប្រសិនបើយើងរហ័សព្យាបាល ជំងឺនេះអាចជា តែផ្តល់ទឹកដោះតិច ។ បើមិនព្យាបាល នឹងបណ្តាលឱ្យដោះរឹង ហើយឈប់ចេញទឹកដោះតែម្តង ។

វិធីការពារ :

- យកទឹកក្តៅឧណ្ហៗ លាយសាប៊ូបន្តិច លាងសំអាតជួរដោះទាំងពីរ ហើយនឹងជើងក្រោយទាំងពីរ ឱ្យមេជ្រូកក្រោយពេលកើតកូន ។
- របបចំណីសំរាប់មេជ្រូក មួយអាទិត្យមុន និង ក្រោយពេលកើតត្រូវបន្ថយជាតិសាច់ ( ការពារកុំឱ្យសំបូរទឹកដោះពេក ) ។
- កូនជ្រូកកើតមក ត្រូវកាត់ធ្មេញចេញភ្លាម
- ធ្វើយ៉ាងណាឱ្យកូនជ្រូកបានបៅគ្រប់ដោះទាំងអស់

ការព្យាបាល :

ពេលទើបរលាកដំបូង យកទឹកកកលុញសង្កត់ចុះឡើង លើដោះដែលរលាក ដើម្បីកុំឱ្យហើមធំ ។ បើយើងបានដឹងតាំងពីថ្ងៃរលាកដំបូងនោះគ្រាន់តែយកទឹកកកលុញសង្កត់លើដោះច្រើនដង ដោះនឹងលែងហើម ប៉ុន្តែពេលដែលដោះហើមធំ ក្តៅនិងឈឺទៅហើយនោះ ត្រូវប្រើទឹកក្តៅ

បាញ់ដាក់ដោះ ឬក៏យកកន្សែងជ្រលក់ទឹកក្ដៅស្អំដោះ ១ថ្ងៃ ២-៣ដង ហើយស្អំម្ដងៗ គឺក្នុងរយៈពេល ២០-៣០នាទី ។

- យកប្រេងកូឡា ប្រេងខ្យល់ លាបដោះក៏បាន

- មិនត្រូវឱ្យកូនជ្រូកបៅដោះដែលរលាកនោះទេ ត្រូវប្របាច់ទឹកដោះពីដោះដែលរលាកនោះដាក់ក្នុងចាន រួចចាក់ចោល ។ មួយថ្ងៃប្របាច់ ៤-៥ដង ពេលប្របាច់ម្ដងៗ ត្រូវប្របាច់ឱ្យអស់ កាលណាប្របាច់ហើយដោះឡើងរឹង ត្រូវស្អាបអង្អែលដោះនោះដោយថ្នមៗ ។

- ឱ្យមេជ្រូកផឹក Sulfate de magnésie : 20-30g បើដោះដែលរលាកមិនទាន់មានខ្ទុះទេ យើងព្យាបាលតែ ២-៣ថ្ងៃ ដោះនោះនឹងជា ទន់ឡើងវិញ ហើយបញ្ចេញទឹកដោះជាធម្មតា ។

ប្រសិនបើអនុវត្តវិធានការ ដូចខាងលើ ២-៣ថ្ងៃហើយ ទឹកដោះនៅតែមានខ្ទុះ ត្រូវប្រើថ្នាំណាមួយក្នុងចំណោមថ្នាំខាងក្រោមនេះ ដើម្បីព្យាបាល :-

- Pénicilline ចាក់សាច់ 15 000 UI ក្នុងទំងន់ជ្រូក ១គក្រ ឬក៏ប្រើ Procaine pénicilline ក៏បាន ។

- Streptomycine ចាក់សាច់ 10 mg ក្នុងទំងន់ជ្រូក១គក្រ

- Combiotic ចាក់សាច់ (លាយ១កំរិត ជាមួយទឹកលាយ ២cc) រួចហើយចាក់ ១ cc ក្នុងទំងន់ជ្រូក ១០គក្រ ។

បើប្រើ Combiotic កុំចាក់ Pénicilline និង Streptomycine

- Pénicilline ឬ Terramycine ) បាញ់បញ្ចូលក្នុងដោះ ស្នាមរន្ធដោះ ក្រោយពេលច្របាច់ទឹកដោះអស់ ។

**ចាក់ថ្នាំជំនួយកំលាំង :**

- Vit. C: 3g ចាក់សាច់ ឬសរសៃ ១ថ្ងៃម្តង ចាក់ ៣-៤ថ្ងៃ

- Gluconate de calcium 10% : 40 cc ចាក់សរសៃ ១ថ្ងៃម្តង ចាក់ ៣-៤ថ្ងៃ ។

## ជំងឺរលាកស្បូន

**Métrite**
**Metritis**

**មូលហេតុ :**

បណ្តាលមកពីមេរោគ Streptocoques និង Colibacilles ។

មូលហេតុដែលបណ្តាលឱ្យមេរោគនេះ ចូលទៅក្នុងខ្លួនជ្រូក គឺដោយសារ :-

- ទ្រុងកើតកូនក្រខ្វក់ ទងផ្ចិតក្រោយពេលជ្រុះនៅបាតទ្រុងស្អុយរលួយ មានមេរោគ មេរោគនេះក៏ចូលទៅក្នុងស្បូន ។

- មេពិបាកកើតកូន មេរលូតកូន ច្រើនរលាកស្បូន

- មេកើតកូនហើយ ធ្លាក់សុកមិនអស់ ឬក៏ងាប់កូនក្នុងពោះ ក៏អាចបណ្តាលឱ្យហើមស្បូន ។

- អ្នកថែទាំជ្រូក ពេលលូកស្ទាបកូនក្នុងពោះ ដោយមិនបាន លាងសំអាតដៃ ក៏អាចឱ្យមេជ្រូកហើមស្បូន ។

- ពេលដោយឈ្នោល ដោយសារប្រដាប់បន្តពូជរបស់ជ្រូកបាក្រខ្វក់ នាំមេរោគចូលទៅក្នុងស្បូន មេរោគរីកដុះដាល ហើយបង្កឱ្យមានជំងឺពេលមេកើតកូន ។

រោគសញ្ញា :

ច្រើនកើតនៅលើមេជ្រូកកើតកូនហើយបាន ១-៣ថ្ងៃ

- មេក្តៅខ្លួន មិនស៊ីចំណី

- ២-៣ថ្ងៃក្រោយ មានខ្ទុះពណ៌ក្រហម-ស មានក្លិនស្អុយចេញពីទ្វារ ។

- បើសិនជារលាកស្បូន ដោយសារធ្លាក់សុកមិនអស់ នោះក្រៅពីមានខ្ទុះ មានឈាម យើងឃើញមានបំណែកសុកស្អុយរលួយចេញមកជាមួយ ។

- បើខ្ទុះចេញតិច ពណ៌ស នោះប្រហែលជារលាកទ្វារធម្មតាទេ ។

- បើរលាកស្បូន គឺមានខ្ទុះច្រើន ហើយស្អុយ ។ បើយើងធ្វើឱ្យជ្រូកស្រែក ដោយក្តាប់ត្រចៀកទាញដើរ នោះជ្រូកនឹងផតពោះ ហើយខ្ទុះនឹងហូរចេញយ៉ាងច្រើន ។

វិធីការពារ :

- លាងសំអាតមេជ្រូកមុនពេលកើតកូន

- លាងសំអាត អនាម័យទ្រុងកើត

- ក្រាលចាតទ្រុងដោយចំបើងស្ងួត ហើយត្រូវផ្លាស់ប្តូររាល់ថ្ងៃ

- ការពារ ធ្វើយ៉ាងណាកុំឱ្យមេជ្រូកពិបាកកើតកូន គឺមិនត្រូវឱ្យវាធាត់ពេកទេ ត្រូវលែងឱ្យវាដើរក្នុងធ្លា ឱ្យស៊ីបន្លែស្រស់ឱ្យច្រើន កុំឱ្យមេជ្រូកទល់លាមក ។

- មិនត្រូវឱ្យមានសេសសល់សុកក្នុងស្បូនទេ

- ត្រូវយកប្រភេទមេជ្រូកដែលរលូតកូនចេញ

ការព្យាបាល :

កាលណាមានរោគសញ្ញាដូចខាងលើត្រូវធ្វើអន្តរាគមន៍ជាបន្ទាន់:-

ក- លាងសំអាតស្បូន ដោយយកទឹកដាំពុះ ទុកឱ្យនៅក្តៅឧណ្ហៗ លាយជាមួយ Permanganate de potasium 1‰ ( 1g permanganate ក្នុងទឹក ១លីត្រ) លាងម្តង ២លីត្រ ។

ខ- Post hypophyse ចាក់សើស្បែក ១០UI ក្នុងមេជ្រូកមួយក្បាល ។

គ- បាញ់បញ្ចូលថ្នាំ ( Pénicilline 1 000 000 UI + 20 cc ប្រេងសណ្តែកដី ) ទៅក្នុងស្បូន ប្រើសីរ៉ាំងអត់ម្ជុលស៊កទុយោនីឡុងរុញបញ្ចូលឱ្យហួសមាត់ស្បូន ។

ឃ- ចាក់ Pénicilline 10 000 UI + 10mg Streptomycine ក្នុងទំងន់ជ្រូក ១គក្រ ។

ង- ដាក់ Chlorazone ក្នុងស្បូន ម្តងមួយគ្រាប់ ១ថ្ងៃពីរដងក្នុងរយៈពេល ៣-៤ថ្ងៃ ។

ច- Tylan 50 ចាក់សាច់ ១មល ក្នុងទំងន់ជ្រូក ៧គក្រ ក្នុងមួយថ្ងៃចាក់ ៣-៥ថ្ងៃ ។ បើចាក់សរសៃ ១ មល ក្នុងទំងន់ជ្រូក ១០គក្រ ក្នុងមួយថ្ងៃ ។

ចាក់បន្ថែមថ្នាំជំនួយកំលាំង :

- Vitamine B1 : 100mg ( ១អំពូល 5 cc ) ចាក់សាច់ ១ថ្ងៃម្តង ចាក់ ៥ថ្ងៃ ។

- Vitamine C : 4g ( ៨អំពូល 5 cc ) ចាក់សាច់ ឬ ចាក់សរសៃស្លឹកត្រចៀក ១ថ្ងៃម្តង ចាក់ ៥ថ្ងៃ ។

- Vitamine B12 : 1000µg ចាក់សាច់ ១ថ្ងៃម្តង ចាក់ ៥ថ្ងៃ ។

អាចចាក់ថ្នាំប៉ូវកំលាំងមួយចំនួនទៀត ដូចជា Bécozyme ១ថ្ងៃ ១-២ អំពូល Sirepa ១ថ្ងៃ 5ml ចាក់ ៣ថ្ងៃ ។

. ចាក់ថ្នាំឱ្យចេញទឹកដោះ Thyrosine ១ថ្ងៃ ១-២ អំពូល ចាក់ ២-៣ ថ្ងៃ ( ប្រើនៅពេលណាដែលកំដៅខ្លួនជ្រូកមានសភាពធម្មតា ៣៨-៣៩ °C ) ។

* ប្រយ័ត្ន !

មិនត្រូវចាក់ Vitamine C លាយជាមួយ Pénicilline, Sulfamide ឬក៏ B12 ទេ ព្រោះ Vitamine C ធ្វើឱ្យបាត់ប្រសិទ្ធិភាពនៃថ្នាំខាងលើនេះ ។

. ការដាក់បញ្ចូល Pénicilline ឬ Chlorazone ទៅក្នុងស្បូន គឺធ្វើក្រោយការលាងសំអាតស្បូន ៣០នាទី ។

# ជំងឺគ្មានទឹកដោះ

## Fièvre vitulaire ou paralysie post-parturition
## Milk fever

---

មេជ្រូកកើតកូនហើយ គ្មានទឹកដោះឱ្យកូនបៅ ដេកស្ពឹកមួយកន្លែងរហូតដល់ងាប់ បណ្តាលមកពីមូលហេតុច្រើនយ៉ាង :-

**ក- មកពីធ្លាក់ស្បូនមិនអស់ :**

សុកដែលនៅក្នុងស្បូនបញ្ចេញ Folliculine ។ ជាតិ Folliculine រាំងខ្ទប់ការបញ្ចេញ Hormone prolactine ។ ខ្វះ Prolactine ដោះមិនបញ្ចេញទឹកដោះ ។

**ខ- មកពីមេជ្រូក**

មានជំងឺរលាកដោះ រលាកស្បូន កាលណាមានជំងឺទាំងពីរនេះបណ្តាល ឱ្យមេជ្រូកក្តៅ អត់ទឹកដោះ ។

**គ- មកពីចំណីខ្វះជាតិស្ករ ( Carbohydrate ) :**

មេជ្រូកពេលកើតកូន ត្រូវការថាមពលច្រើន ហើយថាមពលនេះគឺបានមកពីជាតិស្ករ ។ កាលណាមេជ្រូលពិបាកកើតកូន កូនយូរនោះកាន់តែត្រូវការជាតិស្ករច្រើន ។ ជាតិស្ករជួយបំលែងជាតិសាច់ ឱ្យទៅជាទឹកដោះ ដូចនេះកាលណាខ្វះជាតិស្ករនោះ ទោះបីជាដោះឡើងតឹងក៏ដោយក៏គ្មានទឹកដោះចេញដែរ ។

ឃ- មគពីខ្វះជាតិកាល់ស្យូម :

មានអ្នកចិញ្ចឹមជ្រូកជាច្រើនមានយោបល់ថា កាលណាក្នុងចំណី ខ្វះជាតិកាល់ស្យូម នោះនឹងបណ្ដាលឱ្យអត្រាជាតិកាល់ស្យូមក្នុងឈាមថយចុះ បង្កឱ្យមានជំងឺគ្រុនទឹកដោះ ។

រោគសញ្ញា :

ជំងឺនេះច្រើនកើតមាន ក្រោយពេលកើតកូនភ្លាម ឬក៏ ៤-៥ថ្ងៃក្រោយពេលកើតកូន ។

ក- ជ្រូកមិនស៊ីចំណី ដំណើរទ្រេតទ្រោត ដួលដេកមួយកន្លែង ភ្នែកសន្លឹម ស្លឹកស្រពន់ សន្លប់ឥតដឹងខ្លួន លៀនអណ្ដាត រន្ធច្រមុះស្ងួត កំដៅចុះទាបជាងកំរិតធម្មតា ( ប្រសិនបើមិនមែនមានមូលហេតុមកពីធ្លាក់សុកមិនអស់ រលាកស្បូន ឬក៏ រលាកដោះ ) ។

ខ- ដោះឡើងតឹង តែច្របាច់ទៅមិនចេញទឹកដោះ

គ- កូនជ្រូកបៅដែរ តែមិនឆ្អែត ចុះស្គមទៅៗ

បើព្យាបាលមិនទាន់ពេលទេ ២-៣ថ្ងៃក្រោយមក មេជ្រូកអាចងាប់ ។

វិធីការពារ :

ការពារជំងឺគ្រុនទឹកដោះ គឺការពារកុំឱ្យមានជំងឺធ្លាក់សុកមិនអស់ ជំងឺរលាកដោះ និង ជំងឺរលាកស្បូន ។ មួយអាទិត្យមុន និង ក្រោយពេលកើត ត្រូវបន្ថយជាតិសាច់ក្នុងចំណី ( ដូចជា ម្សៅត្រី សណ្ដែក

សៀង ។ ល ។ ) រួចហើយបន្ថែមចំណីសំបូរជាតិស្ករ ( ដូចជាកន្ទក់ ចុងអង្ករ ពោត ។ ល ។ ) ។

កាលណាមេពិបាកកើតកូន កូនយូរ ត្រូវចាក់ Vitamine C ។

ការព្យាបាល :

ត្រូវរកមូលហេតុដែលបណ្តាលឱ្យជ្រូកមានជំងឺគ្រុនទឹកដោះ ។

. បើមេជ្រូកមានជំងឺធ្លាក់សុកមិនអស់ ឬក៏មានជំងឺរលាកស្បូន ត្រូវព្យាបាលជំងឺទាំងនេះ ។

. យកឈាមមកពិនិត្យមើល បើក្នុងឈាមខ្វះកាល់ស្យូម ត្រូវចាក់ Gluconate de calcium 10% ចាក់ពី 20-50 cc ទៅតាមជ្រូកតូច ឬ ធំ ។

ក្រៅពីវិធានការព្យាបាលជំងឺតាមបែបខាងលើនេះហើយ យើងត្រូវព្យាបាលជំងឺគ្រុនទឹកដោះ ទោះជាមកពីមូលហេតុអ្វីក៏ដោយ :

- Serum glucosé 200 cc
- Vitamine C 5 cc
- Pénicilline ចាក់សាច់ 10 000 UI ក្នុងទំងន់ជ្រូក ១គក្រ

ក្រោយពេលជា បើទឹកដោះចេញតិច នោះត្រូវចាក់ Thyrosine ដើម្បីជំរុញការបំលែងជាតិសាច់ឱ្យទៅជាទឹកដោះ ចាក់រាល់ថ្ងៃ ១ថ្ងៃ 1 cc រហូតដល់ទឹកដោះចេញជាធម្មតាវិញ ។

* ប្រយ័ត្ន !

ការចាក់ Thyrosine អាចធ្វើបានតែក្នុងករណីកំដៅខ្លួនជ្រូកធម្មតា ( 38-39°C ) បើជ្រូកកំពុងក្តៅ ( 40-41°C ) ការចាក់ Thyrosine

គឺអាចបណ្ដាលឱ្យជ្រូកងាប់ ។

## ជំងឺស្ពឹក
**Paralysis**

**មូលហេតុ :**

ជំងឺនេះច្រើនកើតមាននៅលើមេជ្រូកចាស់ កើតកូនច្រើនសារ ហើយកូនម្ដងៗមានចំនួនច្រើន ។ ទោះបីជាយើងឱ្យមេជ្រូកស៊ីចំណីសំបូរជាតិសាច់ហើយក៏ដោយក្ដី ប៉ុន្តែបើចំណីនោះខ្វះជាតិកាល់ស្យូម និង ផូសស្វ័រ ( Ca & P ) នោះវាចាំបាច់ទាញយកជាតិរ៉ែទាំងពីរនេះពីក្នុងខ្លួន ( ឆ្អឹង សរសៃប្រសាទ ... ។ ល ។ ) ដើម្បីបង្កើតជាទឹកដោះ ។ ជាលទ្ធផល គឺឆ្អឹង និង សរសៃប្រសាទ ខ្វះជាតិរ៉ែទាំងពីរនេះ ជ្រូកឈឺមិនអាចដើរបាន មានន័យថាវាមានជំងឺស្ពឹក ។

ជ្រូកដែលចិញ្ចឹមក្នុងទ្រុងងងឹត ខ្វះពន្លឺថ្ងៃ គឺខ្វះប្រភពវីតាមីន D កង្វះវីតាមីន D ការបឺតយកជាតិកាល់ស្យូម និង ផូសស្វ័រ ( Ca & P ) ក៏មិនអាចធ្វើទៅបានដែរ ។

រោគសញ្ញា :

ជំងឺនេះ ច្រើនកើតមាននៅលើមេជ្រូកដែលកើតកូនហើយបាន ២ ទៅ៣អាទិត្យ មានន័យថា ក្រោយពេលប្រើប្រាស់អស់ជាតិកាល់ស្យូមរបស់ឈាម ដែលជាជាតិរួមផ្សំជាមួយជាតិសាច់ ដើម្បីបង្កើតជាទឹកដោះ ។

- ខ្សោយជើងក្រោយទាំងពីរ ដំណើរឃ្លេងឃ្លោង ញ័រញាក់ ដេកច្រើនជាងដើរ រួចបន្ទាប់មកដេកលែងក្រោកតែម្តង ទោះបីជាប្រឹងជួយលើក ក៏វាមិនអាចទ្រទ្រង់ខ្លួនវាបានដែរ ។

- កំដៅខ្លួនធម្មតា

- ស៊ី ផឹក ធម្មតា បើសិនជាយើងដាក់ចំណី ដាក់ទឹកនៅក្បែរវា ។

ជំងឺស្ពឹកកើតមានផងដែរ នៅលើជ្រូកដែលមានជំងឺប៉េស្ត ជំងឺកញ្ជ្រិល ប៉ុន្តែស្ពឹកបណ្តាលមកពីជំងឺឆ្លងទាំងពីរនេះ មានសភាពធ្ងន់ធ្ងរជាងមិនស៊ីចំណី កកឈាម រាគ មានពពឹកភ្នែក ហៀរសំបោរ កំដៅខ្លួនឡើង ។ ល ។

ជំងឺស្ពឹកក៏ឃើញកើតមានផងដែរនៅលើជ្រូកដែលរអិលជើងដួលបាក់ឆ្អឹងភ្លៅ សំប៉ែតភ្លៅក្រោយ ប៉ុន្តែស្ពឹកដោយសារមានរបួស យើងស្រួលដឹងណាស់ ។

- ជ្រូកឈឺគ្រលៀន ឬក៏ហើមគ្រលៀន ឬក៏មកពីប្រើថ្នាំហួសកំរិត ស៊ីចំណីពុល ។ ល ។ ក៏បណ្តាលឱ្យស្ពឹកដែរ ប៉ុន្តែវាមានសភាពយឺតមិនដូចជំងឺស្ពឹក បណ្តាលមកពីខ្វះជាតិវីរ៉ែទេ ។

អាការព្យាបាល :

- ផ្តាច់ដោះកូនជ្រូកជាបន្ទាន់ រួចហើយចិញ្ចឹមវានឹងទឹកដោះគោវិញ

- ក្រាលចំបើងឱ្យក្រាស់ ដើម្បីកុំឱ្យរលាត់ស្បែក

- បញ្ចុកចំណី បន្លែ និង ទឹកផឹក ឱ្យវារាល់ពេល

- ជួយលើកប្រែត្រឡប់ខ្លួនជ្រូក កុំឱ្យវាដេកតែមួយចំហៀងខ្លួន

- ចាក់ Gluconate de calcium 10% ចាក់សរសៃ ថ្ងៃដំបូង 50 cc ថ្ងៃបន្ទាប់ 20 cc ។

- ចាក់ Vitadone forte ចាក់សាច់ ២ថ្ងៃ ក្នុងកំរិត ២ cc

- ចាក់វីតាមីន B1 ( 100mg ) + B12 ( 100µg ) ចាក់សាច់ ១ថ្ងៃម្តង ឬក៏ប្រើ Strychnal B1 forte ចាក់សាច់ ១ថ្ងៃ 2 cc ។

ថែទាំព្យាបាលវា ក្នុងរយៈពេលប្រហែលមួយអាទិត្យ នឹងបានជា ។

# ជំងឺធ្លាក់ផ្លូវយោនី
## Vaginal Prolapse

មេជ្រូកធ្លាក់ផ្លូវយោនី ដោយសារស៊ីចំណីដុះផ្សិត មានជាតិពុល ដោយសារទល់លាមក ឬក៏ដោយសារមានជំងឺពិបាកកើតកូន ខំប្រឹងខ្លាំងពេក ក៏បណ្តាលឱ្យធ្លាក់ផ្លូវយោនីបន្តិចម្តងៗ ។

រោគសញ្ញា :

ផ្លូវយោនីលៀនចេញមកក្រៅ ហើមពណ៌ក្រហម ដោយសារសរសៃឈាមស្ទះនៅនឹងមាត់ផ្លូវយោនី ឈាមមិនអាចចរាចរកើត ភ្នាសផ្លូវយោនីរលាត់ ហើយមេរោគក៏រាតត្បាត ។

ការព្យាបាល :

យក Permanganate de potasium 1‰ លាងសំអាតផ្លូវយោនីដែលលៀនចេញក្រៅ ប៉ុន្តែបើវាហើមធំ យកកន្សែងស្អាតជ្រលក់ទឹកក្តៅរុំជុំវិញ រួចហើយរឹតផ្នែកដែលលៀនចេញពីក្រោមមកលើ ដើម្បីឱ្យឈាមវិលត្រឡប់ទៅក្នុងស្បូនវិញ ។ ពេលដែលផ្លូវយោនីរួមតូចមកវិញហើយ ត្រូវរុញបញ្ចូលបន្តិចម្តងៗ ។ ដើម្បីការពារកុំឱ្យមេជ្រូកប្រឹង ធ្វើឱ្យធ្លាក់ផ្លូវយោនីមកវិញ ត្រូវចាក់ Largactil ១ថ្ងៃ 2 cc ចាក់ ២-៣ថ្ងៃ ។

- Pénicilline ចាក់សាច់ ១ថ្ងៃ 1 000 000 UI ចាក់ ៤-៥ថ្ងៃ។ រួចហើយផ្លាស់ប្តូរចំណី ឬក៏ព្យាបាលជំងឺទល់លាមក ប្រសិនបើវាបណ្តាលមកពីចំណី ឬក៏មកពីមានជំងឺទល់លាមក ។

# បញ្ហាកើតមាននៅលើមេ និង បាជ្រូក

## មេស៊ីកូន

មេជ្រូកស៊ីកូនឯង ជាសញ្ញាដែលច្រើនជួបនៅលើមេចាស់ មូលហេតុមក ពីរបបចំណីរបស់មេជ្រូកនោះមិនមានសមភាព ( ខ្វះជាតិសាច់ឬខ្វះកាល់ស្យូម ... ) ឬក៏មកពីមេជ្រូកឃ្លានពេក ស្រេកពេក ពេលបង្កើតកូន ។ ជួនកាលក៏បណ្តាលមកពីមូលហេតុផ្សេងៗទៀត ដូចជាមេជ្រូកពិបាកកើតកូន ឬក៏មកពីកូនចោខាំដោះមេ បណ្តាលឱ្យមេឈឺចាប់ពិបាកទ្រាំក៏ស៊ីកូនឯង ឬក៏មកពីមេស៊ីសុកហើយស៊ីទាំងកូនទៀត ។

**វិធីការពារ :**

ពេលកើតកូន ត្រូវថែទាំមេជ្រូកឱ្យបានជិតដល់ ផ្គត់ផ្គង់ចំណីមានជីវជាតិគ្រប់គ្រាន់ និង ផ្តល់ទឹកផឹកឱ្យមេជ្រូកឱ្យបានគ្រប់គ្រាន់ និង មានជាប្រចាំ ។

**ការព្យាបាល :**

- កាលណាឃើញមេជ្រូកស៊ីកូន ត្រូវចាប់កូនចេញដាក់មួយកន្លែង។
- ចាក់ Gluconate de calcium ( ចាក់សសៃ ) ឱ្យមេជ្រូក
- ផ្តល់ចំណី និង ទឹក ឱ្យមេជ្រូកឱ្យបានគ្រប់គ្រាន់

- កំណត់ម៉ោង ពេលច្បាស់លាស់ សំរាប់ឱ្យកូនបៅ
- បន្ថែមចំណីដែលសំបូរជាតិសាច់ និង ជាតិរ៉ែ ដល់មេជ្រូក
- ពេលណាមេលែងខាំកូន ទើបលែងកូនឱ្យនៅជាមួយមេវិញ ។

## មេកើតកូនហើយមិនធ្លាក់សុក
**Rétention placentaire**

**មូលហេតុ :**

តាមធម្មតា ពេលកើតកូនអស់ ៣-៤ម៉ោង សុកនឹងធ្លាក់ចុះ ។ ត្រូវទុកឱ្យសុកធ្លាក់ចុះខ្លួនឯងបន្តិចម្តងៗ មិនត្រូវយកដៃជួយទាញទេព្រោះអាចដាច់ បណ្តាលឱ្យហូរឈាម ឬក៏សុកនៅជាប់ស្អិតក្នុងស្បូន ។ ជួនពេលខ្លះ ៥-៦ម៉ោង ក្រោយពេលកើតទើបសុកធ្លាក់ចុះ តែបើហួសពីនេះហើយនៅមិនទាន់ធ្លាក់ចុះ យើងត្រូវជួយធ្វើអន្តរាគមន៍ ។ សុកដែលនៅក្នុងស្បូនរលួយស្អុយ បណ្តាលឱ្យស្បូនមានមេរោគ បើមិនបណ្តាលឱ្យមេជ្រូកងាប់ក៏បណ្តាលឱ្យមេជ្រូកលែងមានកូនដែរ ។ម្យ៉ាងទៀតសុកដែលធ្លាក់មិនអស់អាចបណ្តាលឱ្យមេជ្រូកអត់ទឹកដោះ កូនជ្រូកងាប់ព្រោះស្រេកឃ្លាន ។

មូលហេតុបណ្តាលឱ្យសុកធ្លាក់មិនអស់មានច្រើន :-

- មេជ្រូកចាស់ ខ្សោយ កើតកូនយូរពេក ពិបាកកើតព្រោះ ហេវហត់ សាច់ដុំស្បូនហត់ កន្ត្រាក់តិចមិនគ្រប់កំលាំង ដើម្បីរុញសុកចេញក្រៅ ។

- ពេលមេជ្រូកផើម យើងដឹកជញ្ជូនផ្លូវឆ្ងាយ ត្រូវវាយដំ ជួនក៏ជំពប់ជើងដួល ។ ល ។ បណ្តាលឱ្យមានគ្រោះថ្នាក់ដល់កូនក្នុងពោះ ។

- មេមានជំងឺរលូតកូន ( Brucellose ) ហើយឱ្យស៊ីចំណីមិនគ្រប់គ្រាន់ បណ្តាលឱ្យរាងកាយចុះខ្សោយ សាច់ដុំស្បូនហេវហត់មិនអាចរុញសុកចេញក្រៅបាន ។

- ចំណីសំរាប់មេផើមខ្វះជីវជាតិ ខ្វះកាល់ស្យូម និង ខ្វះអំបិល ។

រោគសញ្ញា :

ក្រោយពេលកើតកូនហើយ ៦ម៉ោង បើសុកធ្លាក់ចុះល្អ មាត់ស្បូននឹងរួមតូចមកវិញដូចសភាពដើម ។

- បើមាត់ស្បូននៅតែបើកធំ នោះជាសញ្ញាបញ្ជាក់ប្រាប់ថានៅសល់សុកក្នុងស្បូន ។

- ពេលស្បូនរួមមកវិញហើយ តែស្រោមរំអិលនៅស្អិតជាប់នោះគឺជាទងសុក យើងអាចទាញចេញ ដោយមិនមានគ្រោះថ្នាក់អ្វីទេ ។

ដូច្នេះបើសិនជាយើងមិនមានលទ្ធភាពនឹងរាប់ចំនួនសុក ថាតើធ្លាក់អស់ហើយឬនៅទេនោះយើងត្រូវពិនិត្យស្បូន ។ ជួនកាលសុកធ្លាក់ចុះជាមួយកូន តែជាទូទៅសុកធ្លាក់ចុះ ក្រោយពេលកើតកូនអស់ ។

ការព្យាបាល :

ក- ធ្វើឱ្យស្បូនគាំរឹត :

ក្នុងករណីសុកមិនទាន់ស្អុយរលួយ យើងអាចប្រើថ្នាំដូចតទៅនេះ ដើម្បីជំរុញឱ្យសាច់ដុំស្បូនកន្ត្រាក់រុញសុកចេញក្រៅ :-

- Gluconate de calcium ចាក់សសៃ 20-50 cc

- Post-hypophyse ឬ Pituilobine ចាក់សាច់ 10-20 UI

- Ergotine ចាក់សាច់ 0,3-0,5mg

ខ- ព្យាបាលស្បូនមានមេរោគ :

( ករណីសុករលួយស្អុយក្នុងស្បូន)

ព្យាបាលដូចជំងឺរលាកស្បូន ។

គ- ជួយធ្វើអន្តរាគមន៍ :

ចំពោះគោ ក្របី ដែលធ្លាក់សុកមិនអស់ យើងស្រួលជួយធ្វើ អន្តរាគមន៍ទេ តែចំពោះជ្រូកគឺពិបាក លុះត្រាតែអ្នកដែលជួយនោះមានបាត ដៃតូច ហើយធ្វើដោយប្រុងប្រយ័ត្ន មិនឱ្យរហែកមាត់ស្បូន ។

មធ្យោបាយដែលប្រសើរបំផុត គឺលាងសំអាតស្បូនដោយទឹកសំលាប់មេរោគ ( Permanganate de potassium 0,5% ) ដើម្បីឱ្យសុកធ្លាក់ចុះអស់ពីស្បូន ។

# មេកើតកូនតិច

មូលហេតុ :

បណ្ដាលមកពី :-

- ដាក់ឈ្មោលមិនត្រូវម៉ោងពេល

- បាបាក់កំលាំង ដោយសារពាក់ញីច្រើនពេក

- បាសំរាក ខានពាក់មេយូរថ្ងៃ

- មេជ្រូកស្គមពេក ព្រោះចំណីខ្វះជីវជាតិ ឬក៏មកពីមេមានជំងឺប៉ារ៉ាស៊ីត បណ្ដាលឱ្យមេរូបញីជ្រុះចុះតិច ។

- មេធាត់ពេក

- មេមានជំងឺស្បូនរ៉ាំរ៉ៃ បណ្ដាលឱ្យមេរូបញី និង ឈ្មោលងាប់ច្រើន ។

- មេមានកូនក្នុងពោះហើយ តែចេះតែធាត់ទៅៗ

មេមានកូនក្នុងពោះហើយ តែមេនោះមិនសូវធ្វើចលនា

- មេមានកូនហើយតែចំណីខ្វះជីវជាតិ ខ្វះជាតិរ៉ែ ជាតិសាច់ និង វីតាមីន A,E ។

- មេមានកូនតិច មកពីពូជវាមានកូនតិច

**វិធីការពារ**

មិនត្រូវដាក់ឈ្មោល ពេលមេស្គម ហេវហត់ មានគ្រុន ឬក៏ពេលទើបផ្ដាច់ដោះកូន ។

- លែងជ្រូកក្រៅទ្វា ដើម្បីឱ្យវាបានធ្វើចលនា

- ឱ្យស៊ីចំណីមានជីវជាតិគ្រប់សព្វ

- មិនត្រូវដាក់បាជ្រូកមានជំងឺ ឬ កំពុងហេវហត់

- ជ្រើសរើសមេជ្រូកសាយកូន កុំចិញ្ចឹមមេជ្រូកពូជកូនតិច

- ត្រូវរង់ចាំដល់ពេលមេជ្រូកពេញរូបរាង ពេញកំលាំង សឹមដាក់ឈ្មោល

- ដាក់ឈ្មោលឱ្យត្រូវម៉ោងពេល ( សូមអានសៀវភៅបច្ចេកទេសចិញ្ចឹមជ្រូក ដែលបានបោះផ្សាយរួចហើយ ) ។

## មេជ្រូកកើតកូន តូច ធំ មិនស្មើគ្នា

មូលហេតុ :

នេះមិនមែនជាជំងឺទេ ប៉ុន្តែគឺជាលទ្ធផលបណ្តាលមកពីបច្ចេកទេសចិញ្ចឹម កាលណាមេជ្រូកកើតកូនធំស្មើគ្នា នោះយើងស្រួលចិញ្ចឹម ប៉ុន្តែបើផ្ទុយទៅវិញនោះ គឺជាបរាជ័យនៃកិច្ចការចិញ្ចឹមរបស់យើងហើយ ។

ទៅតាមពូជជ្រូកដែលផ្តល់កំណើតកូនធំ ឬ តូច តែជាទូទៅកាលណាកូនកើតមកមានទំងន់ ១,២-១,៥គក្រ នោះទើបល្អ កាលណាមួយសំបុកមានធំ មានតូចនោះ មិនល្អទេ ចំពោះកូនដែលកើតមកមានទំងន់ ៦០០-៧០០ក្រ គឺពិបាកចិញ្ចឹមឱ្យរស់ មានសុខភាពល្អណាស់ ។

មូលហេតុជាសំខាន់គឺបណ្ដាលមកពីរបបចំណី និង សុខភាពរបស់មេជ្រូកពេលដើម ។

**មេកើតកូនតូចដោយសារ :**

- ចំណីខ្វះជាតិសាច់ ( Protein ) ខ្វះជាតិរ៉ែ ( Mineral ) និង ខ្វះវីតាមីន ( Vitamin ) ដែលជាកត្តាចាំបាច់ក្នុងការបង្កើតរូបរាងទារក ឱ្យមានសភាពធម្មតា ។

- មកពីមេជ្រូកមានជំងឺក្នុងពេលមានគភ៌ មានឥទ្ធិពលដល់កូនក្នុងពោះ បានជារីកធំធាត់មិនធម្មតា ។

- មកពីមេក្មេងពេក ខ្វះសមត្ថភាពក្នុងការបង្កើតកូនឱ្យបានធំ

- មកពីមេធាត់ពេក បណ្ដាលឱ្យកូនតូច ។

**មេកើតកូនមកមានធំមានតូច ដោយសារ :**

- មកពីធ្វើចលនាតិច ( ដើរតិច ) មកពីចិញ្ចឹមក្នុងទ្រុងតូចចង្អៀត

- មកពីស្បូនមិនធម្មតា មួយកំណាត់ធំ មួយកំណាត់តូច

- មកពីចំណីរឹង ខ្វះបន្លែ ខ្វះទឹកផឹក បណ្ដាលឱ្យមេជ្រូកទល់លាមក ស្បូនត្រូវពោះវៀនសង្កត់ជាកំណាត់ៗ បណ្ដាលឱ្យកូនក្នុងពោះធំធាត់មិនស្មើគ្នា ។

**កំណត់សំគាល់ :**

បើសិនជាពេលកើតមកមានកូនធំស្មើគ្នា តែចិញ្ចឹមក្រធំ ហើយធំមិនស្មើ ត្រូវពិនិត្យមើលតើមេមានទឹកដោះគ្រប់គ្រាន់ដែរឬទេ ? ដោះរីកធំស្មើគ្នាដែរឬទេ ? កូនខ្លាំង ( ធំ ) ដណ្ដើមដោះមិនឱ្យកូនខ្សោយបៅ ។

ចំណីរបស់មេខ្វះជាតិសាច់ ជាតិរ៉ែ ខ្វះវីតាមីន សុទ្ធតែជាមូលហេតុបណ្តាលឱ្យខ្វះទឹកដោះ កូនធំមិនស្មើ ។ ជួនកាលធំមិនស្មើ បណ្តាលមកពីកូនជ្រូកមានជំងឺ ។

វិធីការពារ :

ត្រូវស្វែងរកមូលហេតុ ដើម្បីបញ្ជៀសនូវការខ្វះខាតខាងលើ សំដៅធ្វើយ៉ាងណាឱ្យកូនជ្រូកកើតមកធំស្មើគ្នា ។

## មេខ្វះទឹកដោះឱ្យកូនបៅ

មូលហេតុបណ្តាលមកពី :

- ចំណីដែលផ្តល់ឱ្យមេជ្រូកខ្វះជាតិសាច់ និង ជាតិរ៉ែ ដើម្បីបង្កើតទឹកដោះ ។ ពេលមានគភ៌ស៊ីចំណីគ្រាប់រឹង បណ្តាលឱ្យក្រពេញទឹកដោះមិនរីក មិនបញ្ចេញទឹកដោះ ។
- មេជ្រូកមានជំងឺទល់លាមក អត់ទឹកដោះ
- ដាក់មេជ្រូកក្នុងទ្រុងចង្អៀម ស្អុះស្អាប់
- មេមានជំងឺហើមដោះ រលាកស្បូន សុកធ្លាក់មិនអស់
- មេភ័យខ្លាចខ្លាំង

**រោគសញ្ញា** :

- មេឱ្យកូនបៅតែមួយភ្លែត ក៏លាក់ដោះ

- កូនជ្រូកឃ្លាន ចុះស្គមបន្តិចម្តងៗ ស្បែកជ្រីវជ្រួញ ជួនកាលកន្ត្រាក់ខ្លួន ព្រោះខ្វះជាតិស្ករ

- បើមេអត់ទឹកដោះដោយសារទល់លាមក ឬហើមដោះ រលាកស្បូន សុកធ្លាក់មិនអស់ យើងអាចឃើញរោគសញ្ញានៃជំងឺនេះ ។

**វិធីការពារ** :

- ធ្វើយ៉ាងណាកុំឱ្យមេជ្រូកទល់លាមក

- ការពារ និង ព្យាបាលជំងឺ ហើមដោះ រលាកស្បូន សុកធ្លាក់មិនអស់ ។

- កែលំអទ្រុងចិញ្ចឹម ឱ្យមានខ្យល់អាកាសចេញចូលល្អ និង ស្ងប់ស្ងាត់ ។

- ចំណីសំរាប់មេជ្រូក ត្រូវឱ្យមានជាតិសាច់ និង ជាតិរ៉ែគ្រប់គ្រាន់ ។

**ការព្យាបាល** :

ស្វែងរកមូលហេតុឱ្យឃើញសិន រួចសឹមព្យាបាល ។

ចាក់ Post-hypophyse 20 UI ចែកជា ៤ដង ម្តង 5UI ក្នុងមួយថ្ងៃ ។

ចាក់ហើយមួយម៉ោងទឹកដោះចេញ ត្រូវលែងកូនឱ្យបៅភ្លាម ។

# មេមិនឱ្យកូនបៅ

---

មូលហេតុដែលបណ្តាលឱ្យមេជ្រូកមិនព្រមឱ្យកូនបៅ គឺដោយសារ :

- មេជ្រូកហើមដោះ ពេលកូនបៅឈឺ បានជាលាក់ដោះមិនឱ្យកូនបៅ ។
- មេមានទឹកដោះតិច កូនបៅមិនឈប់
- កូនជ្រូកមានធ្មេញស្រួច ពេលបៅខាំដោះមេ
- មេស្រឡាញ់កូន កាលណាឮកូនស្រែក ស្ទុះងើបឈរ ភ្លេចឱ្យកូនបៅ ។
- ទ្រុងអ៊ូអរ មនុស្សចេញចូលឡូឡា បណ្តាលឱ្យមេមិនព្រមឱ្យកូនបៅ ។

វិធីការពារ និង ព្យាបាល :

- ស្វែងយល់ រកមូលហេតុឱ្យបានច្បាស់លាស់ ដើម្បីព្យាបាល
- កាត់ធ្មេញកូនជ្រូក ក្រោយពេលកើត
- ព្យាបាលជំងឺហើមដោះ ប្រសិនបើមាន
- បើមេមានទឹកដោះតិច :
  + ចាក់ Thyrosine 2 cc ចាក់ ២-៣ថ្ងៃ
  + ផឹកGalactogène ១ថ្ងៃ ៣ដង ម្តង ១៥តំណក់ ដាក់ក្នុងបបរឱ្យវាស៊ី ។

+ ឬ Galactogil ១ថ្ងៃ ៣ដង ម្តងមួយស្លាបព្រាបាយ

+ ឱ្យចំណីសំបូរជាតិសាច់ ជាតិកាល់ស្យូម ឬឱ្យផឹកទឹកដោះគោ ១ថ្ងៃ ៣ដង ម្តងកន្លះលីត្រ ។

## មេកើតកូនមិនរស់

ក៏មានករណីខ្លះ មេជ្រូកកើតកូនមិនរស់ សល់កូនក្នុងពោះ ដោយសារមេកើតកូនយូរ ១-២ម៉ោង ទើបកើតបានកូនមួយ ដូច្នេះទម្រាំកើតកូនអស់ ត្រូវចំណាយពេលជាង ១២ម៉ោង ។ ក្រោយពេលកើតយើងឃើញសុកធ្លាក់គ្រប់ចំនួនកូន មេស៊ីចុកធម្មតា ហើយឱ្យកូនបៅធម្មតា តែកន្លះថ្ងៃ ឬមួយថ្ងៃក្រោយមក ក៏កើតថែមកូន ១ ឬ ២ ទៀត កូនដែលកើតក្រោយនេះ អាចងាប់ ឬ ក៏នៅរស់ ។

### មូលហេតុ :

មូលហេតុជាសំខាន់ដែលបណ្តាលឱ្យមេកើតកូនយូរ មកពីមេធ្វើចលនា ( ដើរ ) តិច ឬក៏មកពីមេខំប្រឹងបង្កើតកូនខ្លាំងពេក ហេវហត់ក៏ឈប់ប្រឹង បណ្តាលឱ្យនៅសល់កូនក្នុងពោះ ។

### រោគសញ្ញា :

ពេលមេដេក យើងពិនិត្យមើលពោះ តើមាននៅសល់កូនទេ បើមាននៅសល់ គឺវាកំរើក តែមានកូនខ្លះមិនកំរើក ដេកស្ងៀម ទាល់តែយើង

យកដៃសង្កត់ឱ្យខ្លាំងទើបដឹង ។

បើពោះនៅធំ យើងសង្កត់ផ្នែកខាងក្រោមឃើញរឹង ហើយមេដេកមិនស្ងៀម ងើបរកផឹកទឹក ដើរចុះឡើងក្នុងសភាពមិនធម្មតា នោះបង្ហាញថានៅសល់កូនក្នុងពោះ ។ យើងអាចលូកដៃចូលក្នុងស្បូន ទាញកូនចេញ ឬក៏ចាក់ Post-hypophyse ដើម្បីឱ្យមេប្រឹងបង្កើតកូន ។

ជំងឺការពារ :

មេជ្រូកដែលធ្វើចលនា ( ដើរ ) ច្រើន មិនសូវកើតមានករណីកើតកូនសល់ក្នុងពោះទេ ។ កន្លែងកើតកូនត្រូវស្ងៀមស្ងាត់ ហើយអ្នកមើលថែទាំមេជ្រូកកើតកូន គឺជាអ្នកឱ្យវាស៊ីចុកពេលវាធើម ។

## បាជ្រូកបាត់បង់សមត្ថភាព

**Impuissance**

មូលហេតុ :

បាជ្រូកដែលមានសុខភាពល្អ គឺខ្លាំងក្លាណាស់ ម៉ោងណា ពេលណា ក៏ពាក់មេបានដែរ តែបើបានោះមិនត្រូវការញីទេ បានន័យថាវាខូចប្រដាប់បន្តពូជ ឬ ប្រដាប់បន្តពូជរបស់វាខ្វះសមត្ថភាព ។

មូលហេតុដែលបណ្ដាលឱ្យបា បាត់បង់សមត្ថភាពបន្តពូជ មកពី :

- ចាជ្រូកនោះធាត់ពេក ដោយសារយើងចញ្ចឹមវាក្នុងទ្រុងចង្អៀត មិនអាចឱ្យវាធ្វើចលនាដើរចុះឡើងបាន ឬក៏មកពីចំណីសំបូរតែជាតិម្សៅ បណ្តាលឱ្យធាត់កកខ្លាញ់ ។

- ចិញ្ចឹមវាក្នុងទ្រុងមួយតែឯងតាំងពីតូច ដូច្នេះកាលណាវាឃើញជ្រូកច្រើន ធ្វើឱ្យវាភ័យខ្លាច ។

- ចំណីអាហារមិនល្អ ខ្វះជីវជាតិ ក្រពេញខាងភេទមិនរីក មិនបញ្ចេញអ័រម៉ូន ( Hormone ) ។

- ចាក្មេងពេក កំសាក ខ្លាចមេ ព្រោះពេលពាក់ញីលើកមុន ត្រូវមេខាំឱ្យមានរបួស ។

- ចាស្គម ខ្សោយ ព្រោះកើតព្រូន ឈឺឆ្អឹង ឈឺជើង មិនហ៊ានកំរើក ។

- ចាបាក់កំលាំង ព្រោះពាក់ញីច្រើនពេក

- ដឹកចាក្នុងដំណើរផ្លូវឆ្ងាយ បណ្តាលឱ្យវាហេវហត់

- ដឹកចាទៅកន្លែងឆ្ងាយដាច់ស្រយាល ចំឡែកកន្លែង ចំឡែកមនុស្ស ធ្វើឱ្យវាមានអារម្មណ៍ចាញ់ស្រាប ( ញ៉ក ) ។

- ចាជ្រូកដែលកើតមកពីការជាន់ឈាម ក៏មិនសូវមានតម្រេកដែរ ។

រោគសញ្ញា :

កាលណាចាជ្រូកឃើញញី ឱ្យសម្លេង ឱ្យក្លិន ដើរតាមហើយ នៅតែធ្វើមិនដឹង ដើរចេញវាហើ នោះបញ្ជាក់ថា ចានោះបាត់បង់សមត្ថភាព

ហើយ ។

ការព្យាបាល :

ត្រូវស្វែងរកមូលហេតុឱ្យបានច្បាស់លាស់ មុននឹងព្យាបាល ។

- ព្យាបាលជំងឺព្រូន ជំងឺឈឺឆ្អឹង ឈឺជើង ... ។ ល ។ បើមាន

- ត្រូវមានផ្កា សំរាប់ឱ្យជ្រូកបាធ្វើចលនា

- ដឹកជ្រូកបាជុំវិញទ្រុងមេជ្រូក ដើម្បីឱ្យវាធ្លាប់នឹងការដឹកដើរផង ជំរុញវាឱ្យមានម្រេកផង ។ ការដឹកដើររបៀបនេះ អាចជួយឱ្យយើងដឹងថា តើមេណារកឈ្មោល មេណាមិនរកឈ្មោល ?

- ត្រូវជ្រើសរើសជ្រូកចិញ្ចឹមទុកធ្វើបាឱ្យបានល្អិតល្អន់ : ពូជល្អ ពងធំស្មើ មិនជាន់ឈាម ... ។ ល ។

- ចំណីសំរាប់ជ្រូកបាត្រូវឱ្យសមស្រប កុំឱ្យវាធាត់ពេក ហើយក៏ កុំឱ្យវាស្គមពេក ។

- ត្រូវឱ្យបាពាក់ញីឱ្យបានសមស្រប ( សូមអានសៀវភៅ បច្ចេកទេសចិញ្ចឹមជ្រូក ) កុំរហ័សឱ្យវាពាក់ញីពេក ហើយក៏កុំប្រើបាចាស់ ពេក ( អាយុ ៦-៧ ឆ្នាំ ) ។

- គប្បីដឹកញីមកទ្រុងជ្រូកឈ្មោល ដើម្បីកុំឱ្យវាប្លែកកន្លែង

- កន្លែងពាក់ញី ត្រូវមានខ្យល់អាកាសត្រជាក់រហើយ និង ស្ងៀម ស្ងាត់ ចំណង់ក្នុងការពាក់ញី វាអាស្រ័យទៅនឹងការយកចិត្តទុកដាក់របស់ មេជ្រូក ។

- មិនត្រូវដឹកជ្រូកបាទៅកាន់ទីឆ្ងាយ ត្រូវរក្សាភាពខ្លាំងក្លារបស់វា

ដោយការផ្គត់ផ្គង់ចំណី កាលណាឃើញសុខភាពរបស់វាចុះខ្សោយ ។ ក្រោយពេលពាក់មេ បំប៉នឱ្យវា ពងមាន់ឆៅ ២គ្រាប់ ឬក៏បបរសណ្តែកខៀវឱ្យវាស៊ី ឱ្យមានកំលាំងឡើងវិញ ។

. ចាក់ Sterandryl 50mg ចាក់សាច់មួយថ្ងៃរំលងមួយថ្ងៃ ចាក់ ៥-៦ម្ជុល ។

. ចាក់ Cacodylate de soude ( ចាក់សើរស្បែក ) ៨ម្ជុល ក្នុងរយៈពេល ១៥ថ្ងៃ ( ២ថ្ងៃ ចាក់ ១ម្ជុល ) សូមអានរបៀបប្រើនៅតារាងខាងក្រោយ ។

## បាជ្រូកឱ្យកូនតិច

មូលហេតុ :

បាជ្រូកឱ្យកូនតិច បណ្តាលមកពីមេរូបឈ្មោលតិច និង ខ្សោយនោះគឺជាលទ្ធផលនៃការ :-

. ពាក់ញីច្រើនហួសកំលាំង

. ខានពាក់មេយូរខែ ថ្ងៃ

- បាធាត់ពេក ខ្ជិលពាក់មេ តឹងពោះ ភាប់បាត់ បញ្ចេញទឹកកាម តិច ហើយមេរូបឈ្មោលក៏តិច ។
- បាមានជំងឺ Brucellose រ៉ាំរ៉ៃ
- ដឹកបាផ្លូវឆ្ងាយ ទៅដល់កន្លែងភ្លាម ក៏ឱ្យពាក់មេភ្លាម
- ពូជជ្រូកបានោះ ជាពូជកូនតិច
- បាជ្រូកនោះជាន់ឈាម ( បងប្អូន ម៉ែ កូន ) ជាមួយជ្រូកមេ ។ល។

សូមអញ្ជើញរកជាវអាន

- រឿង មហារាជនីក្រហម
- បច្ចេកទេសចិញ្ចឹមជ្រូក
- បច្ចេកទេសចិញ្ចឹមមាន់

ដោយ បណ្ឌិត ជា សោខ

# ជំងឺរបស់កូនជ្រូក

## ជំងឺរាគរបស់កូនជ្រូកទើបកើត

មូលហេតុ :

កូនជ្រូកកើតបាន ២-៣ថ្ងៃ ច្រើនមានជំងឺរាគធ្ងន់ធ្ងរ រួចហើយងាប់ ដែលជាទូទៅគឺបណ្ដាលមកពី :-

ក- មេជ្រូកពេលមានគភ៌ខ្វះវីតាមីន A :

កាលណាមេមានគភ៌ខ្វះវីតាមីន A កូនដែលកើតមកក៏ខ្វះវីតាមីននេះដែរ ។ កង្វះវីតាមីន A ពោះវៀនគ្មានអ្វីការពារ បានជាមេរោគ Colibacille និង Salmonella រាតត្បាត បណ្ដាលឱ្យមានជំងឺរាគ ។

ខ- មេជ្រូកធ្លាប់មានជំងឺ Salmonellose :

កាលណាមេមានជំងឺនេះ កូនក្នុងពោះក៏អាចរាតត្បាតដោយជំងឺនេះដែរ ។ ជួនកាលមេរោគនេះឆ្លងតាមរយៈការបៅទឹកដោះមេ កូនជ្រូកមានជំងឺ Salmo-nellose ក៏បណ្ដាលឱ្យរាគ ។

គ- បកពិមេជ្រូកមានជំងឺហើមសួនមានខ្ទុះ :

ដូច្នេះ ក្នុងទឹកដោះក៏មានជាតិពុល កាលណាកូនជ្រូកបៅ បណ្ដាលឱ្យរាគ ។

ឃ- មកពីមេមាន់ទឹកដោះច្រើនពេក :

កូនបៅទឹកដោះច្រើនពេក ជាតិសាច់មិនរំលាយ ក៏បណ្តាលឱ្យរាគ ។

ង- មកពីមេស៊ីចំណីមិនល្អ ដូះផ្សិត ជូរផ្អូម

ច- មកពីកូនជ្រូកខ្វះជាតិដែក

ឆ- មកពីកូនជ្រូកមានជំងឺរលាកផ្ចិត :

ហើម មានខ្ទុះ មេរោគនៅផ្ចិត រាតត្បាតដល់ពោះវៀន បណ្តាលឱ្យរាគ។

ជ- មកពីត្រជាក់ :

ត្រជាក់ កូនរងារ ចុះខ្សោយ បៅហើយមិនរំលាយអាហារ

រោគសញ្ញា :

ពេលទើបចាប់ផ្តើមឈឺជាដំបូង កូនជ្រូកនៅបៅតិចៗ កំដៅខ្លួនឡើងបន្តិច ៣៩.៥-៤០°C កូនជ្រូករាគ លាមកពណ៌លឿង បន្ទាប់មកក៏ងាប់យ៉ាងរហ័សតែក្នុងរយៈពេលមួយថ្ងៃ ដោយសារមេរោគចូលទៅក្នុងឈាម។ មានករណីខ្លះកូនជ្រូកឈឺ អត់បៅ ៣-៤ថ្ងៃ ទើបងាប់ ។

ក្នុងកំរិតស្រាល កូនជ្រូកឈឺ ដេកកន្ទ្រាក់ខ្លួន ញ័រញាក់ ចុះស្គមខ្សោយទៅៗ រហូតដល់ងាប់ ។ បើព្យាបាលមិនទាន់ពេលវេលា អាចងាប់កូនអស់ទាំងសំបុក ។

ការព្យាបាល :

ត្រូវរកឱ្យឃើញពីមូលហេតុដែលបណ្តាលឱ្យរាគ រួចហើយសឹម

ព្យាបាល

- ផ្លាស់ប្តូរចំណី ឱ្យមេជ្រូកស៊ីបន្លែស្រស់ឱ្យបានច្រើន ដើម្បីជួយផ្គត់ផ្គង់វីតាមីន A និង បន្ថយទឹកដោះរបស់មេ ។

- ឱ្យកូនជ្រូកបៅតាមពេលម៉ោងកំណត់ បន្ថយការបៅរបស់វា

ដាក់កូនជ្រូកក្នុងទ្រុងកំដៅ ស្ងួត ស្អាត

- ព្យាបាលជំងឺរលាកស្បូនដល់មេជ្រូក បើសិនជាមេជ្រូកមានជំងឺនេះ ( មើលរបៀបព្យាបាលជំងឺរលាកស្បូន ) ។

- ព្យាបាលជំងឺរលាកផ្ចិតឱ្យកូនជ្រូក បើសិនជាកូនជ្រូកមានជំងឺនេះ ( មើលរបៀបព្យាបាលជំងឺរលាកផ្ចិត ) ។

ប៉ុន្តែទោះបីជាកូនជ្រូកមានជំងឺរាគ ដោយមូលហេតុអ្វីក៏ដោយ ក៏ត្រូវព្យាបាលឱ្យកូនជ្រូកដូចតទៅនេះ :

១- ចាក់វីតាមីន A 0.5-1 cc ក្នុងកូនជ្រូក ១ក្បាល ១ថ្ងៃចាក់ម្តង រហូតដល់ជា ។

២- ចាក់ជាតិដែក : Pigdex, Iron-dextran, Ferrodex --- ។ ចាក់ 1 cc ចាក់សាច់ រួចហើយ ១០ថ្ងៃក្រោយមក ចាក់ 1 cc ទៀត ។

៣- ចាក់ Terramycine injectable solution ចាក់សាច់ ក្នុងរយៈពេល ៣-៤ថ្ងៃ ។

- កូនជ្រូក 0.5-1 cc

- មេជ្រូក 4 cc ក្នុងមួយថ្ងៃ ដើម្បីឱ្យវាបញ្ចេញជាតិ Terramycine នេះទៅក្នុងទឹកដោះ ។

ឃ- ចាក់សេរ៉ូមផ្អែម ( Serum glucose ) : ចាក់ក្រោមស្បែក ពោះ ចាក់ម្តង 20-30 cc មួយថ្ងៃចាក់ ២-៣ដង រហូតដល់ជា ។

ង- ក្នុងករណីជំងឺធ្ងន់ធ្ងរ ត្រូវឱ្យផឹក Terramycine A-D Scours tablet pfizer តាមកំរិតដូចខាងក្រោមនេះ :-

កូនជ្រូកក្រោម ១០គក្រ : ១-៣គ្រាប់ ក្នុង ១ថ្ងៃ ចែកជាបីពេល ។

* ការណែនាំចំណាំ

ពេលឃើញកូនជ្រូកចាប់ផ្តើមរាគ អត់ស៊ី អត់ផឹក ត្រូវឱ្យផឹក Terramycine A-D ភ្លាម តាមកំរិតដូចតទៅ :-

- ក្រោម ១០គក្រ : ១/២-១គ្រាប់ ក្នុង ១ថ្ងៃ
- ១០-២៥គក្រ : ២គ្រាប់ ក្នុង ១ថ្ងៃ
- ៤០គក្រឡើង : ៤គ្រាប់ ក្នុង ១ថ្ងៃ

## ជំងឺហើមផ្ចិត

**Infection umbilicale ( Omphalite )**

មូលហេតុ :

បណ្តាលមកពីមិនបានសំអាតទងផ្ចិត មិនបានចង និង លាបថ្នាំសំលាប់មេរោគ ឬក៏មកពីចងមិនជាប់ កាត់មិនល្អ បណ្តាលឱ្យមេរោគ

រាគត្បាត ទងផ្ចិតហើម ។ មុនពេលកើត ទងផ្ចិត គឺជាទងសុក ដែលភ្ជាប់សរសៃឈាមរបស់កូនជ្រូកនឹងសន្ទឹកសុក ។ ក្រោយពេលកើត សរសៃឈាមនៅទងផ្ចិតស្វិតបន្តិចម្តងៗ រហូតដល់អស់តែម្តង ។

រោគសញ្ញា :

ក្នុងលក្ខណៈធម្មតាដែលផ្ចិតគ្មានមេរោគ តែ ៤-៥ថ្ងៃ នោះ ទងផ្ចិតនឹងបានជាល្អ ប៉ុន្តែបើមានមេរោគរាគត្បាត បណ្តាលឱ្យហើម ជ្រួក ឡើងកំដៅ មិនស្ងួតបោះដោះ ហើយបណ្តាលឱ្យមានរោគសញ្ញាបីបែបដូចតទៅនេះ :-

- មេរោគចូលទៅក្នុងឈាម ធ្វើដំណើរពាសពេញសារពាង្គកាយរួចហើយមកប្រមូលផ្តុំនៅសន្លាក់ឆ្អឹងជើង ។

- កូនជ្រូកមានជំងឺរាគ

- កូនជ្រូកមានជំងឺស្ពន់ជាន់ ( តេតាណូស )

**វិធីការពារ និង ព្យាបាល :**

ក្រោយពេលកើត ត្រូវដាក់កូនជ្រូកក្នុងទ្រុងកំដៅ រាល់ពេលឱ្យកូនបៅ ត្រូវពិនិត្យទងផ្ចិត លាបថ្នាំក្រហម ( Mercurochrome ) មួយថ្ងៃម្តង ។ កាលណាយើងពិនិត្យឃើញទងផ្ចិតក្រៀមស្វិតបន្តិចម្តងៗ ពីក្រៅទៅក្នុងស្បែកពោះ នោះគឺជាការល្អ ប៉ុន្តែផ្ទុយទៅវិញ បើឃើញទងផ្ចិតហើមស្អាបទៅទន់ៗ នោះគឺជារោគសញ្ញានៃការហើមទងផ្ចិតហើយ ត្រូវព្យាបាលជាបន្ទាន់ :-

- ស្រាយខ្សែចងទងផ្ចិត ឱ្យទឹកពណ៌លឿងហូរចេញ

- លាងសំអាតផ្ចិតម្តងទៀត

- ចងទងផ្ចិតឡើងវិញដោយសរសៃចេស ដែលបានសំលាប់មេរោគរួចហើយ ។

- ចាក់ Pénicilline 1000 000UI ចែកជាពីរភាគ ពាក់កណ្តាលចាក់សើស្បែកជុំវិញផ្ចិត ពាក់កណ្តាលទៀតចាក់សាច់កក្រោយត្រចៀក ចាក់ ៣-៥ថ្ងៃ។

បើកូនជ្រូករាគផង ស្អន់ជាន់ផង ( តេតាណូស ) ត្រូវព្យាបាលជំងឺទាំងពីរនេះ ( មើលរបៀបព្យាបាលជំងឺតេតាណូស) ។

## ជំងឺខ្វះជាតិស្ករក្នុងឈាម

**Hypoglycémia**

**មូលហេតុ :**

កូនជ្រូកដែលទើបកើត ជួនកាលមានការរំលាយជាតិស្ករយឺត ហើយការបំលែងជាតិ Glucogène ឱ្យទៅជាជាតិស្ករមិនបានសំរួល បណ្តាលឱ្យកូនជ្រូកខ្វះជាតិស្ករក្នុងឈាម ។

មេជ្រូកខ្វះទឹកដោះ ដោយសារមានជំងឺហើមស្បូន ហើមដោះ ឬក៏មកពីជំងឺដទៃទៀតដូចជា ជំងឺប៉េស្ដ ជំងឺរាគ ។ ល ។ ក៏ជាមូលហេតុបណ្ដាលឱ្យកូនជ្រូកមានជំងឺខ្វះជាតិស្ករក្នុងឈាមដែរ ។

កូនជ្រូកដែលមានជំងឺ បណ្ដាលមកពីមេរោគ Streptocoque, Colibacille, Salmonella, Erysipelotrix --- កូនជ្រូកមានជំងឺរាគក៏អាចបណ្ដាលឱ្យមានជំងឺខ្វះជាតិស្ករក្នុងឈាម ។

ដូចនេះយើងឃើញថា ជំងឺខ្វះជាតិស្ករក្នុងឈាម ជួនកាលអាចបណ្ដាលមកពីមានជំងឺផ្សេងៗទៀតបង្កើតឡើង ។

ជំងឺខ្វះជាតិស្ករក្នុងឈាម កើតឡើងតែនៅលើកូនជ្រូកអាយុប្រហែល ១០ថ្ងៃ ចំណែកឯជ្រូកអាយុលើស ១០ថ្ងៃ ចេះលិទ្ធចំណី ដូចនេះការបំលែងជាតិស្ករត្រូវបានសំរួល ។

រោគសញ្ញា :

តាមធម្មតាកំរិតជាតិស្ករក្នុងឈាមកូនជ្រូកគឺ 100-140mg/100cc ឈាម នៅពេលដែលតួលេខនេះចុះនៅត្រឹម 20mg/100cc ឈាម នោះរោគសញ្ញានៃការខ្វះជាតិស្ករកើតមានឡើង ។

ដំបូងកូនជ្រូកក្ដៅ ស្បែកឡើងកន្ទួលក្រហម ជើងទាំងបួនដើរគន្ទឹងគន្ទាំង ឬ ជួនកាលតែជើងពីរខាងក្រោយទេ ដេកសន្ទឹម កន្ទ្រាក់ជើងទាំងបួនដូចស្ពន់ចូល ... រឹងខ្លួន រឹងក ។ ក្រោយស្ពន់ជាន់ប៉ុន្មានម៉ោងស្បែកក្រឡប់មកជាស្លេក កូនជ្រូកសន្ទប់ រួចហើយងាប់ ។

វិធីការពារ និង ព្យាបាល :

- ចាក់ Serum glucosé 5% ចាក់ច្រើនសារ ចាក់ម្ដង 15cc នៅកន្លែងស្បែកពោះ ( Intra peritonial ) និង ចាក់សើស្បែក ។

- ព្យាបាលជំងឺឱ្យមេជ្រូក ដើម្បីឱ្យសំបូរទឹកដោះឡើងវិញ

- ទុកដាក់កូនជ្រូកនៅកន្លែងកក់ក្ដៅ

- ប្រើថ្នាំអង់ទីប៊ីយ៉ូទិក ទៅលើកូនជ្រូកដែលមានជំងឺ ។

## ជំងឺមិនរំលាយអាហារ ចំពោះកូនជ្រូកបៅដោះ

**Dyspepsia**

ជំងឺនេះកើតមានតែនៅលើកូនជ្រូកអាយុក្រោម ១ខែប៉ុណ្ណោះ ដោយសារការប្រែប្រួលអាកាសធាតុ កូនជ្រូករងា បៅច្រើន កំភាលរុំទ្រុងសើម ដោយសារត្រជាក់ពោះ បានជាបៅហើយមិនរំលាយអាហារ ។

រោគសញ្ញា :

កូនជ្រូកឈឺ ស្រងូតស្រងាត់ បៅតិច ក្អួតចេញទឹកដោះទាំងដុំៗ ជួនរាគ ក្នុងករណីត្រជាក់ខ្លាំងបណ្ដាលឱ្យប្រកាច់ កន្ត្រាក់ជើង រួចហើយងាប់ ។

ជំងឺនេះងាយព្យាបាល ហើយក៏មិនអាចឱ្យយើងច្រឡំនឹងជំងឺដទៃទៀត ដូចជាជំងឺប៉េស្ដ ឬ ជំងឺព្រូនទេ ។

ការព្យាបាល :

បន្ថយកុំឱ្យវាចោរច្រើនពេក រៀបចំទ្រុងឱ្យកក់ក្តៅ ហើយឱ្យផឹកថ្នាំ :

| | |
|---|---|
| - Citrate de soude | ២ក្រ |
| - Sirop simple | ៥០ក្រ |
| ទឹក | ១០០ក្រ |

ឱ្យផឹកបីម៉ោងម្តង ។ ម្តងមួយស្លាបព្រាកាហ្វេ ឬក៏យកក្រូចឆ្មារត្រាំទឹកអំបិល ( ណាំង៉ូវ ) ១គ្រាប់ច្របាច់ឱ្យហួត់ ក្នុងទឹក 100cc រួចឱ្យកូនជ្រូកផឹក ។

# ជំងឺពុល

## ជំងឺពុលថ្នាំ និង ពុលចំណី

**មូលហេតុ** :

- បណ្តាលមកពីជ្រូកឃ្លានពេក ស៊ីតែពីសតែពាស ដូចជាដើម និង សំបកដំឡូងមី ស្រស់ គ្រាប់កៅស៊ូស្រស់ ស្លឹក ឬ ផ្លែគ្រប់ពុល ។ ល ។

- ជ្រូកស៊ីដោយថ្នាំពុល ដូចជាថ្នាំសំលាប់កណ្តុរ ស៊ីបន្លែ ស្មៅ ដែលទើបតែបាញថ្នាំសំលាប់សត្វល្អិតហើយ ... ។ ល ។

- ស្នូកទឹក ស្នូកចំណី លាបថ្នាំ ( Oxyde de plomb ) ឬក៏ធ្វើពីសំណារ បក៏លាបម្រ័ក្ស ។

**រោគសញ្ញា** :

ពេលទើបចាប់ផ្តើមពុលដំបូង យើងពិបាកដឹងណាស់ ប៉ុន្តែមាន រោគសញ្ញាជាប្រមាណដូចតទៅនេះ :-

- ឈឺពោះ ចំកោងខ្នង ផតពោះ ក្អួត ... ។ ល ។
- ឈឺក្នាសស្បែកក្នុងមាត់ ហៀរទឹកមាត់ ទឹកច្រមុះ សង្កៀតធ្មេញ លលាមក
- ញាក់សាច់ដុំ ភ្នែកស្រវាំង

- ដេកសន្លប់សន្និន ១-២ថ្ងៃ ទើបងាប់

- ចំពោះជ្រូកពុលយូរថ្ងៃ មានដំបៅជើងច្រើន រាគមានលាយឈាម ។

វះពិនិត្យមើលឃើញក្រពះ ពោះវៀន ថ្លើម គ្រលៀន ជាពិសេសគឺរលួយថ្លើម ខ្លាញ់ពណ៌លឿង ។

ការព្យាបាល :

ក- ដំបូងគឺធ្វើយ៉ាងណាឱ្យជ្រូកក្អួត បញ្ចេញចំណីពុលមកវិញ :

កាលណាយើងដឹងច្បាស់ថាជ្រូកពុលចំណីហើយ ត្រូវធ្វើយ៉ាងណាឱ្យវាក្អួតបញ្ចេញចំណីនោះឱ្យអស់មកវិញ ដោយប្រើថ្នាំ Ipeca 1-3g ទៅតាមជ្រូកតូច ឬ ធំ ។

ខ- បន្ទាប់មកបន្សាបជាតិពុល :

ពិនិត្យមើលតើជ្រូកពុលចំណីអ្វី រួចហើយឱ្យវាផឹកថ្នាំបន្សាបទៅតាមប្រភេទជាតិពុលនោះ ។ ជាទូទៅគេច្រើនប្រើម្សៅធ្យូង ឬក៏ Sulfate de fer ទៅតាមជ្រូកតូច ឬ ធំ យើងឱ្យផឹកពី 0,5-1g Sulfate de fer លាយក្នុងទឹកល្មមឱ្យវាផឹកអស់ ឬ 5-10g ម្សៅធ្យូងឧសដាំបាយ ។

គ- ជំរុញឱ្យវាបញ្ចេញជាតិពុលឱ្យអស់ :

- ធ្វើយ៉ាងណាឱ្យថ្លើម និង គ្រលៀន ( Rein ) បញ្ចេញជាតិពុលមកក្រៅ ប្រើ Sulfate de soude ឬ Sulfate de magnésie 30-50g ទៅតាមមាឌជ្រូកតូច ឬ ធំ ។

- ឱ្យជ្រូកផឹកទឹកឱ្យច្រើន ដើម្បីលាងឈាម

. ចាក់ Gluconate de calcium ចាក់សរសៃ ដើម្បីឱ្យឈាមរត់ស្មើ និង បញ្ចេញជាតិពុល 20 cc ក្នុងទំងន់ជ្រូក ១០គក្រ ។

. ចាក់ Serum glucosé ចាក់សរសៃ ដើម្បីប៉ូវកំលាំង និងលាងជាតិពុលក្នុងឈាម 100cc ក្នុងទំងន់ជ្រូក ១០០គក្រ ។

ឃ- ចាក់ថ្នាំជំនួយបេះដូង :

. ចាក់ Huile camphrée 3-5cc ក្នុងទំងន់ជ្រូក ១០គក្រ ឬ Sparteine ឬ Cafeine ចាក់សាច់ ៣ម៉ោងចាក់ម្តង ។

ក្រោយពេលជាពីជំងឺ ឱ្យជ្រូកស៊ីចំណីតិចបានហើយ លុះដល់ជាមែនទែនសឹមឱ្យស៊ីធម្មតាឡើងវិញ ។

## ជំងឺពុលអំបិល

**Salt poisoning**

ជំងឺពុលអំបិល ( NaCl ) ជាជំងឺដែលច្រើនជួបប្រទះនៅលើជ្រូក ដោយសារក្នុងចំណីមានកំរិតជាតិអំបិលលើស ។ ជាតិអំបិលដែលលើសផ្ទុកនៅក្នុងខ្លួន និង ក្នុងស្រោមខួរ បណ្តាលឱ្យហើមខួរ និង ស្រោមខួរ ។

រោគសញ្ញា :

ទៅតាមកំរិតជាតិអំបិល ដែលរោគសញ្ញាស្តែងចេញយឺត ឬ រហ័ស ។ កាលណាពុលខ្លាំងរោគសញ្ញាមានដូចតទៅ :- ញ័រញាក់

ដើរវិលវល់ ជួនកាលកន្ត្រាក់ខ្លួន ហើយបើធ្ងន់មែនទែនសន្លប់ ២-៣ថ្ងៃ រួចហើយងាប់ ។

បើពុលតិច មានន័យថាកំរិតជាតិអំបិល លើសតែបន្តិចបន្តួចទេនោះ រោគសញ្ញាមានដូចតទៅ :- ស្រេកទឹក រមាស់ ទល់លាមក ២-៣ថ្ងៃក្រោយ ជ្រូកហេវហត់ ថ្លង់ និង ងងឹតភ្នែក មិនស៊ីចំណី ដេកកន្ត្រាក់ជើង កាច់ក្បាលមកក្រោយ រឹងថ្គាម កន្ត្រាក់ខ្លួនក្នុង ១០នាទីម្តង ជ្រូកអាចងាប់ក្នុងរយៈពេល ៥-៦ថ្ងៃក្រោយ ។

**រោគវិនិច្ឆ័យ :**

- ភ្នាសក្រពះ និង ពោះវៀនកកឈាម
- ហើមគ្រលៀន
- ស្រោមខួរហើម មានទឹក

កំរិតជាតិអំបិលដែលអាចឱ្យជ្រូកងាប់គឺ ១២៥-២៥០ក្រាម មធ្យមគឺ ៣-៧ក្រាម ក្នុងទំងន់ជ្រូក ១គក្រ ។

**វិធីការពារ :**

ប្រយ័ត្នក្នុងចំណីមានជាតិអំបិលច្រើន ។

តម្រូវការជាតិអំបិលចំពោះជ្រូកគឺ 0.៥0% ក្នុងចំណី ។

**ការព្យាបាល :**

- ចាក់ Gluconate de calcium ចាក់សរសៃ 20cc សំរាប់ជ្រូក ១00គក្រ ។

- ចាក់ Serum glucosé ចាក់សសៃ 100cc ក្នុងទំងន់ជ្រូក ១០០គក្រ

- ចាក់ Huile camphrée ឬ Caféine ចាក់សាច់ 3-5cc ក្នុងទំងន់ជ្រូក ១០០គក្រ ។

- ឱ្យជ្រូកផឹកទឹកឱ្យច្រើន ។

## ពុលជ័រកៅស៊ូត្រាលថ្នល់
**Coal Tar poisoning**

ជ័រកៅស៊ូដែលយើងយកមកលាបស្នូកចំណី ស្នូកទឹក អាចបណ្តាលឱ្យជ្រូកពុល ។

**រោគសញ្ញា :**

បើពុលខ្លាំងជ្រូកងាប់ដោយគ្មានរោគសញ្ញា បើពុលតិចអាចបណ្តាលឱ្យជ្រូកចុះខ្សោយ មិនស៊ីចំណី ឈឺពោះ ដង្ហើមញាប់ តែមិនបណ្តាលឱ្យឡើងកំដៅខ្លួនទេ ភ្នាសស្បែកភ្នែក ច្រមុះ មាត់ ពណ៌ស្លេកដោយសារខ្វះឈាម ។

**រោគវិនិច្ឆ័យ :**

ថ្លើមហើមធំ ផ្លាស់ប្តូររូបរាង កកឈាម ហើយផុយរលួយ ។

ការព្យាបាល :

គ្មានថ្នាំព្យាបាលជ្រូលពុលជ័រកៅស៊ូក្រាលថ្នល់ទេ ។ សំខាន់បំផុតគឺមិនត្រូវឱ្យជ្រូកប៉ះពាល់ផ្ទាល់ជាមួយវត្ថុដែលមានជាប់ជ័រកៅស៊ូ គឺថាមិនត្រូវយកជ័រកៅស៊ូមកលាប ឬ បិទស្នូកចំណី ស្នូកទឹកទេ ។

# ពុលចំណីដុះផ្សិត

កាលណាយើងឱ្យជ្រូកស៊ីចំណីមិនល្អដូចជា កន្ទក់ ពោត ចុងអង្ករ កាកសណ្តែកដី កាកប្រេងដូង និង ម្សៅត្រីដុះផ្សិត នោះវាមិនគ្រាន់តែមិនផ្តល់ជីវជាតិដល់ជ្រូកទេ តែនៅហុចលទ្ធផលមិនល្អដោយសារជាតិពុលដែលផ្សិតទាំងនោះបង្កើតឡើងទៀតផង ។

រោគសញ្ញា :

– ក្នុងករណីធ្ងន់ :

ជ្រូកអាចងាប់ក្នុងរយៈពេល ១-២ថ្ងៃ ។ មិនស៊ីចំណី ខ្សោយជើងក្រោយទាំងពីរ ចេញឈាមតាមគូទ កន្ត្រាក់ខ្លួន បោកក្បាលនឹងជញ្ជាំងរហូតដល់ងាប់ កំដៅខ្លួនធម្មតា ។

- ក្នុងករណីស្រាល :

ជ្រូកអាចបន្ថយពេលងាប់រហូតដល់ ៦-៧ថ្ងៃ ។ ដំណើរមិនរឹងមាំ ផត ពោះ ចំកោងខ្នង ភ្នែកលឿង កំដៅខ្លួនធម្មតា ។

រោគវិនិច្ឆ័យ :

វះពិនិត្យជ្រូកងាប់ឃើញ :- ឈាមកកក្នុងពោះ ក្នុងស្រោមសួត ក្នុងក្រពះ ក្នុងពោះវៀន ថ្លើមលឿង មានឈាមកកដុំៗ សាច់ដុំកកឈាមដុំតូចៗ ។

- ចំពោះជ្រូកធំ : ស្រោមប្រដាប់បន្តពូជហើម
- ចំពោះមេជ្រូក : ទ្វារហើមរីក ដូចពេលរកឈ្មោល

ការព្យាបាល :

គ្មានថ្នាំពិសេសណា សំរាប់ព្យាបាលជំងឺនេះទេ ត្រូវបញ្ឈប់កុំឱ្យជ្រូកស៊ីចំណីផុះផ្សិតទាំងនោះទៀត រួចហើយឱ្យផឹកទឹកលាយ Bicarbonate de soude 2% ។

. ចាក់ Gluconate de calcium និងចាក់ Sérum glucosé ដូចព្យាបាលជំងឺពុលដទៃទៀតដែរ ។

. ចាក់ Hiule camphrée ឬ Caféine ជំនួយបេះដូង ។

## ពុលចំណីជូរផ្អូម

**Botulisme**

---

ជំងឺនេះបង្កឡើងដោយមេរោគ Clostridium botulinum ក្នុងចំណីជូរផ្អូម ដែលគេក្រវាត់ចោល ដូចជានៅលើកណ្ដុរងាប់ ត្រី ឆ្អឹង លាមក គ្រឿងកំប៉ុង ខូច ជូរផ្អូម ... ។ ល ។

**រោគសញ្ញា :**

ជ្រូកអាចងាប់ក្នុងរយៈពេល ៨-៩ម៉ោង រហូតដល់ ២-៣ថ្ងៃ ។

**- ខូចសរសៃប្រសាទ :**

ភ្នែកស្លាប់ ។ - ស្ពឹកជើងក្រោយទាំងពីរ លេបចំណីមិនកើត ត្រចៀកធ្លាក់

- បេះដូងលោតខ្សោយ កកឈាមជាំពេញខ្លួន

- ជ្រូកងាប់ដោយសារឈាមហូរយឺត មិនអាចបញ្ចេញជាតិពុលអស់ពីក្នុងឈាម ។

**ការព្យាបាល :**

- ឱ្យផឹកថ្នាំបញ្ចុះ ( ប្រេងល្ហុងខ្វែរ ) ( Huile de ricin ) ជ្រូក ៥០គក្រ ឱ្យផឹក 30 cc ។

- ចាក់ Terramycine injectable solution ដើម្បីសំលាប់ Clostridium botulinum ក្នុងពោះវៀន : 2- 4 cc ក្នុងទំងន់ជ្រូកពី ១០-

៤៥គក្រ ។ 5-10cc ចំពោះជ្រូកទំងន់លើសពី ៥០គក្រ ។ ប៉ុន្តែទោះបីជ្រូកទំងន់ណាក៏ដោយ ក៏មិនត្រូវចាក់ឱ្យលើសពី 10cc ដែរ ។

. ចាក់ Sérum glucosé និង Huile camphrée ដូចព្យាបាលជំងឺពុលដទៃទៀតដែរ ។

# ជំងឺទូទៅ

## ជំងឺហើមសួត

**Pneumonia**

មូលហេតុ :

ជំងឺហើមសួត បង្កឡើងដោយមេរោគ Pneumocoque ។ មេរោគនេះរស់នៅក្នុងទងសួត និង ក្នុងសួត កាលណាជ្រូកចុះខ្សោយវាក៏ធ្វើសកម្មភាព បណ្ដាលឱ្យជ្រូកហើមសួត ជ្រូកមានជំងឺហើមសួត គឺបណ្ដាលមកពី :-

- ទ្រុងចិញ្ចឹមក្ដៅស្អុះពេក ឬក៏សើម ត្រជាក់ពេក
- ជ្រូកមានជំងឺប៉ារ៉ាស៊ីត ព្រូនចង្អឹះធ្វើដំណើរឆ្លងកាត់សួត
- ជ្រូកដេកលើកំរាលស៊ីម៉ងត៍ត្រជាក់ ព្រោះមិនមានក្រាលចំបើង ឬ សំបកបាវ ។

រោគសញ្ញា :

ជ្រូកដែលមានជំងឺហើមសួត ក្ដៅ មិនស៊ីចំណី ច្រើនដេកពិបាកដកដង្ហើម ហេវហត់ ដំណើរមិនរឹងមាំ ច្រើនលុតជង្គង់ជើងមុខទាំងពីរ ។ ប្រសិនបើហើមទាំងទងសួតផង នោះនឹងបណ្ដាលឱ្យជ្រូកហៀរ

សំបោរ បើបំពង់ខ្យល់រលាកស្រាលនោះ សំបោររាវ តែបើរលាកខ្លាំង សំបោរខាប់ កកជាក្រមរ បណ្តាលឱ្យថប់ដង្ហើម ។

បើជំងឺធ្ងន់ អាចបណ្តាលឱ្យជ្រូកងាប់ក្នុងរយៈពេល ២-៣ថ្ងៃ ដោយសារថប់ដង្ហើម ។

បើជំងឺស្រាល ជ្រូកមានជំងឺហើមសួតរ៉ាំរ៉ៃ ដង្ហើមហត់ ស្រោមសួតមានខ្ទុះ ចិញ្ចឹមក្រធំជាងកូនជ្រូកដទៃទៀតក្នុងសំបុក ។

**រោគវិនិច្ឆ័យ :**

វះពិនិត្យជ្រូកងាប់ដោយជំងឺហើមសួតឃើញ :-

- សួតហើមជាំ មានទឹកច្រើន ។ ដាក់ក្នុងទឹក សួតនោះលិចចុះ កាលណាយើងច្របាច់សួតនោះ ឃើញមានចេញទឹក និង ពពុះ ។
- ស្រោមសួតមានទឹកពណ៌លឿង
- បើឈឺយូរ៥-៦អាទិត្យ នោះសួតស្វិតហើយមានខ្ទុះក្នុងស្រោម។

**ការព្យាបាល :**

- Huile camphrée 10% : 2cc ចាក់សើរស្បែក
- Eucalyptol : 3-5 cc ចាក់សើរស្បែក
- Streptomycine ចាក់សាច់ ១០មក្រ ក្នុងទំងន់ជ្រូក ១គក្រ
- Terramycine injectable solution កូនជ្រូក 1-2cc
  ជ្រូកធំ 10-20cc

# ជំងឺទល់លាមក

**Constipation**

---

មូលហេតុ :

មកពីពោះវៀនមិនធ្វើចលនាច្របាច់រុញដុំលាមកចេញមកក្រៅ និង មិនបញ្ចេញរសរំលាយអាហារ បានជាជ្រូកក្តៀន ។

មូលហេតុដែលបណ្តាលឱ្យជ្រូកក្តៀនមានច្រើន :-

- មកពីជ្រូកមិនបានធ្វើចលនា ( ដើរចុះឡើង )
- ខ្វះទឹកផឹក
- ខ្វះបន្លែ ខ្វះជីវជាតិក្នុងចំណីប្រចាំថ្ងៃ
- មកពីជ្រូកឈឺ បណ្តាលឱ្យកំដៅខ្លួនឡើង ជ្រូកមិនសូវស៊ីចំណី ក៏អាចបណ្តាលឱ្យទល់លាមកដែរ ។

រោគសញ្ញា :

លាមករាងមូលតូច រឹងដូចអាចម៍ពពែ ។ ជ្រូកទល់លាមក ច្រើនដេក ខ្ជិលស៊ីចំណី ។ ប្រសិនបើមិនក្តៅខ្លួន ហើយជ្រូកស្រស់ស្រាយជាធម្មតា នោះបញ្ជាក់ថាជ្រូកនោះមានជំងឺទល់លាមកតែម្យ៉ាងគត់ ។ តែបើជ្រូកទល់លាមក ក្តៅខ្លួន ត្រូវរកមូលហេតុដែលបណ្តាលឱ្យមានជំងឺនេះ ។

បើទល់លាមកយូរថ្ងៃ អាចបណ្តាលឱ្យហើមពោះវៀន ក្អួត ទឹកនោមពណ៌លឿង ហើយជួនកាលឡើងកំដៅ ។

ការព្យាបាល ៖

បាញ់បញ្ចូលប្រេង Parafine 30-60g ឬក៏ប្រេងល្ហុងខ្មែរ (Huile de ricin ) 50-100g ទៅក្នុងគូទជ្រូកដែលទល់លាមក ឬ ចាក់ Lantine ½ - 4cc រួចហើយផ្លាស់ប្តូរចំណី ឱ្យស៊ីបន្លែឱ្យច្រើន ។ លែងជ្រូកឱ្យធ្វើចលនា និង ដាក់ទឹកក្នុងស្នូកឱ្យមានជាប្រចាំ ។

## ជំងឺលៀនក្រសាល់គូទ
## Rectal Prolapse

ជ្រូកដែលមានជំងឺនេះ គឺក្រសាល់គូទធ្លាក់ចេញក្រៅ មូលហេតុដែលបណ្តាលឱ្យមានជំងឺនេះ ជាទូទៅគឺបណ្តាលមកពីទល់លាមក មកពីមានជំងឺរាគរូស មកពីមានជំងឺប៉ារ៉ាស៊ីត ធ្វើឱ្យជ្រូកប្រឹងជុះ បណ្តាលឱ្យធ្លាក់ក្រសាល់គូទមកក្រៅ ។ មេជ្រូកដែលមានជំងឺពិបាកកើតកូន ពេលខំប្រឹងខ្លាំង ជួនកាលក៏បណ្តាលឱ្យធ្លាក់ក្រសាល់គូទដែរ ។

រោគសញ្ញា ៖

ពោះវៀនលៀនចេញក្រៅគូទប្រហែល ៥-១០សម កកឈាមហើម ដំបូងពណ៌ក្រហម បន្ទាប់មកពណ៌ខៀវក្រមៅ ទុកកាន់តែយូរពោះវៀនលៀនចេញក្រៅកាន់តែវែងដោយមាន ដក់ទឹក និង ឈាម ។

ការព្យាបាល :

ពេលទើបចាប់ឈឺដំបូង ពោះវៀនលៀនចេញតែបន្តិចទេ យើងត្រូវលាងសំអាតពោះវៀនដែលលៀនចេញនេះដោយទឹក Permanganate រួចហើយលាប Vaseline ឬ Pommade pénicilline ឬ Pommade terramycine ។ លាងសំអាតដៃឱ្យស្អាត រុញពោះវៀនដែលចេញលៀនក្រៅនោះបន្តិចម្តងៗទៅកន្លែងដើមវិញ រួចហើយដេររន្ធគូទ ប៉ុន្តែមិនត្រូវដេរឱ្យជិតពេកទេ ទុកប្រហោងឱ្យជ្រូកអាចជុះអាចម៍កើត ។

ប្រសិនបើពោះវៀនដែលធ្លាក់នោះ ហើមធំពេក យើងត្រូវយកក្រណាត់ស្អាតមករុំជុំវិញ ហើយច្របាច់ឱ្យទឹកចេញ ដើម្បីជួយឱ្យវារួមតូចមកវិញ បន្ទាប់មកយើងលាប Vaseline ឬក៏ប្រភេទ Pommade ខាងលើរួចហើយរុញបញ្ចូលវាទៅក្នុងវិញ ដេររន្ធគូទ ទុកប្រហោងល្មមតែឱ្យជ្រូកអាចជុះកើត ។

- ឱ្យជ្រូកឈឺស៊ីបន្លែស្រស់
- ចាក់ Pénicilline បង្ការក្រែងមានជំងឺឆ្លង ។

# ជ្រូកក្តៅ ហប់ ស្ទុះស្ទាប់

មូលហេតុ :

គ្រប់ប្រភេទសត្វ តែកាលណាហត់ ក្តៅស្ទុះ តែងតែដកដង្ហើមខ្លាំង និង បេញញើស ដើម្បីបន្ថយការហត់ និង ជួយសំរួលកំដៅក្នុងខ្លួន ។ ជ្រូកមានស្រទាប់ ខ្លាញ់ក្រាស់នៅក្រោមស្បែក តែគ្មានក្រពេញបញ្ចេញញើស ( លើកលែងតែចុងច្រមុះ ) ហេតុនេះបានជាវាមិនពូកែទ្រាំទ្រនឹងអាកាសធាតុក្តៅស្ទុះ ។ យ៉ាងនេះបានជាកាលណាជ្រូកធ្វើចលនាហួសកំលាំង ត្រូវគេដេញ ឬក៏ដឹកជញ្ជូនផ្លូវឆ្ងាយ ក្នុងពេលក្តៅខ្លាំង ដាក់ក្នុងកន្លែងស្ទុះស្ទាប់ខ្វះខ្យល់ ជ្រូកងាយនឹងថប់ដង្ហើមងាប់ណាស់ ។

រោគសញ្ញា :

ហារមាត់ ធ្លាក់អណ្តាត ពង្រីករន្ធច្រមុះដើម្បីដកដង្ហើម ភ្នែកក្រហម ស្បែកក្រហម ហើយប្រែជាជាំក្រមៅបន្តិចម្តងៗ ក្តៅ ៤១-៤២°C ដេករួចងើបឡើង រសាប់រសល់ ដូរកន្លែងដេកជាញឹកញាប់ ដើម្បីរកកន្លែងត្រជាក់ ។ បើមិនសង្គ្រោះវាទេ ជ្រូកអាចដាច់ដង្ហើមងាប់ក្នុងរយៈពេល ៣-៤ម៉ោងក្រោយ ។

វិធីការពារ :

- ចៀសវាងកុំដេញជ្រូកផ្លូវឆ្ងាយ ក្រោមកំដៅថ្ងៃ
- ចៀសវាងកុំដេញជ្រូកឱ្យរត់លឿន

- ចៀសវាងការដឹកជញ្ជូនជ្រូកដាក់ក្នុងទ្រុងចង្អៀត ហប់គ្មានខ្យល់អាកាសចេញចូល ។

- ចៀសវាងកុំឱ្យជ្រូកផឹកទឹកមុនពេលដឹកជញ្ជូនផ្លូវឆ្ងាយ

- ត្រូវចិញ្ចឹមជ្រូកក្នុងទ្រុងត្រជាក់ មានខ្យល់អាកាសចេញចូល ខែក្តៅ ត្រូវឧស្សាហ៍មុជទឹកឱ្យជ្រូក បើមានលទ្ធភាពត្រូវធ្វើអាងទឹកឱ្យជ្រូកដេកត្រាំពេលក្តៅខ្លាំង ។

**ការព្យាបាល :**

កាលណាឃើញជ្រូកមានរោគសញ្ញាដូចបានរៀបរាប់ខាងលើ ត្រូវធ្វើអន្តរាគមន៍ជាបន្ទាន់ ។

- ទុកដាក់ជ្រូកនៅកន្លែងល្ហើយ ត្រជាក់

- ដាក់ទឹកត្រជាក់ឱ្យជ្រូកផឹក

- ស្លំទឹកកកដាក់លើក្បាល កុំឱ្យឈាមកកនៅខួរក្បាល ( បើគ្មានទឹកកក យកកន្សែងជ្រលក់ទឹកត្រជាក់ )

- យកទឹកខ្ទេះរីតសព្វខ្លួនជ្រូក ដើម្បីឱ្យរលាយឈាម និង បន្ថយកំដៅក្នុងខ្លួន ។

- មិនត្រូវយកទឹកត្រជាក់ចាក់លើខ្លួនជ្រូកទេ ធ្វើយ៉ាងនេះអាចឱ្យឈាមរត់ចូលទៅក្នុងថ្លើម សួត ពោះវៀន បង្កើតជាជំងឺកកឈាម ធ្វើឱ្យជ្រូករឹតតែឆាប់ងាប់ ។

# ជំងឺដំបៅមានដង្កូវចោះ

ជំងឺដំបៅមានដង្កូវចោះ ច្រើនកើតមាននៅតំបន់ណាដែលសំបូររុយក្បាលខៀវ ។ រុយក្បាលខៀវតែងស្វែងរកមុខរបួសនៅលើខ្លួនសត្វ ដើម្បីជញ្ជក់ឈាម និង ពងដាក់ ។ របួសដោយសារការគ្រៀវ ក៏ដូចជារលាត់ដោយសារមុតបន្លា ឱ្យតែមានចេញឈាមបន្តិច ក៏រុយក្បាលខៀវធុំក្លិនដែរ វាជញ្ជក់ឈាម រួចហើយពងដាក់កន្លែងរបួសនោះ ។ ពងញាស់ក្លាយជាកូនដង្កូវ ប៉ុន្មានថ្ងៃក្រោយមកវារុលស្បុលចូលទៅក្នុងសាច់បណ្ដាលឱ្យហើមសាច់ មានខ្ទុះ ចេញឈាម ។

ជ្រូកដែលត្រូវដង្កូវចោះ ឈឺចុកចាប់ ស៊ីមិនឆ្ងាញ់ ដេកមិនស្រណុក បើមិនព្យាបាលទេ ដង្កូវកាន់តែធំ មុខរបួសក៏កាន់តែក្លាយ មានខ្ទុះបណ្ដាលឱ្យជ្រូកពុល លែងស៊ីចំណី ធាក់កំលាំងបន្តិចម្ដងៗរហូតដល់ងាប់ ។

ត្រូវការពារមុខរបួសកុំឱ្យដង្កូវចោះ ដោយការថែទាំវារាល់ថ្ងៃ :-

- លាងមុខរបួសរាល់ថ្ងៃ ប្រើ Alcool iodée រួចហើយសំលាប់មេរោគ ដោយលាប Mercurochrome ( ថ្នាំក្រហម )

- យកខ្លាញ់ថ្លើមត្រី ( huile de foie de morue ) ឬក៏ទឹក Crésyl ឬជ័រដើមកៅស៊ូ មកលាបលើមុខរបួស ដើម្បីកុំឱ្យរុយក្បាលខៀវមកជិត ។

កាលណាដំបៅមានដង្កូវចោះហើយត្រូវ :-

- លាងសំអាត និង កោសរោមជុំវិញដំបៅ

- យកសំឡីជ្រលក់ថ្នាំ US Formula EQ 335 ញុកទៅក្នុងសំបុកដង្កូវនោះ បើគ្មានថ្នាំនេះទេ អាចប្រើទឹកក្រេស៊ីល ( Crésyl ) ក៏បាន ។ ១ថ្ងៃ ក្រោយមកត្រូវលាងសំអាតមុខរបួសនឹង Permanganate de potassium រួចហើយចាប់ដង្កូវងាប់ និង សាច់ស្អុយចេញ ។

- យកសំឡីស្អាតផ្ចិតមុខរបួសឱ្យស្ងួត លាបថ្នាំក្រហម និង រោយម្សៅ Sulfamide ។

## រលាកស្បែកដោយកំដៅថ្ងៃ

**Sun burn**

មូលហេតុ :

បណ្ដាលមកពីជ្រូកដើរក្រោមកំដៅថ្ងៃក្ដៅខ្លាំង ជ្រូកពណ៌សទទួលឥទ្ធិពលពីពន្លឺថ្ងៃខ្លាំងជាងជ្រូកពណ៌ខ្មៅឬពណ៌ក្រមៅ ដូចជាជ្រូក Duroc ជាដើម។

រោគសញ្ញា :

ធ្ងន់ ឬ ស្រាលវាអាស្រ័យទៅតាមម៉ោងពេលដែលយើងលែងជ្រូកឱ្យដើរក្រោមកំដៅថ្ងៃ ។ ដើរក្រោមកំដៅថ្ងៃ ៣-៤ម៉ោង ជ្រូក Yorkshire ឬ Landrace ប្រែសម្បុរជាក្រហម ក្ដៅខ្លួន បើយើងយកដៃ

សង្កត់វាស្រែក ។ ជ្រូកដើរយឺតៗ មួយៗដោយប្រុងប្រយ័ត្ន ក្រោយមួយរយៈ ស្បែកក៏របក ហើយជាបណ្តើរៗ ជ្រូកក៏មានទំលាប់ឈប់ក្រហមទៀត ។ ចំពោះជ្រូកសម្បុរស អាចខ្មៅចស្លឹកត្រចៀក និង កន្ទុយ ។

ការព្យាបាល :

ជ្រូកដែលរលាកស្បែកដោយកំដៅថ្ងៃក្នុងកំរិតស្រាល ក្រោយពេលបានសំរាកក្នុងម្លប់ត្រជាក់តែ ២-៣ថ្ងៃ ក៏មានសភាពដូចធម្មតាវិញ ។ តែបើរលាកខ្លាំង ត្រូវដាក់វានៅកន្លែងត្រជាក់ រួចហើយលាប Pommade oxyde de zinc ។

មិនត្រូវលែងជ្រូកពេលក្តៅខ្លាំងទេ តែគប្បីលែងវាឱ្យចេញក្រៅទ្វា នៅវេលាព្រឹកត្រជាក់ និង ពេលរសៀលជាការល្អ ។

## ជំងឺប្រតិកម្ម
**Allergie**

ជំងឺប្រតិកម្ម ឬ ជំងឺឡើងកន្ទួល ច្រើនកើតនៅលើកូនជ្រូក ឬ ជ្រូកជំទង់ ក្រោយពេលចាក់វ៉ាក់សាំងការពារជំងឺ ឬក៏បណ្តាលមកពីចំណីអាហារ ជួនកាលចំបើងក្រាលទ្រុងក៏អាចបណ្តាលឱ្យជ្រូកឡើងកន្ទួលដែរ ។ នេះគឺជាប្រតិកម្មដោយឡែករបស់សត្វជ្រូក ព្រោះថាស៊ីចំណីជាមួយគ្នា ឬក៏ចាក់វ៉ាក់សាំងការពារជំងឺដូច គ្នាតែសត្វជ្រូកខ្លះមានប្រតិកម្ម សត្វខ្លះក៏គ្មាន ។

រោគសញ្ញា :

មានចំណុចមូលប៉ុនចុងម្រាមដៃនៅលើស្បែកពោះ ភ្នែក ត្រចៀក ជួនកាលចំណុចមូលនេះជាប់គ្នាជាផ្ទាំងធំតែម្តង ។ កន្លែងស្បែកកន្ទួលពណ៌ស្លេក ហើយកណ្តាប់ជុំវិញពណ៌ក្រហម ដូចគ្នានឹងស្នាកស្នាមដោយឃ្មុំទិច ។ ជ្រូកដែលមានជំងឺនេះមិនក្តៅខ្លួនទេ មិនបោះបង់ចំណីទេ តែរមាស់ ហើយត្រដុសខ្លួនទៅនឹងវត្ថុដែលនៅជុំវិញ ។

ជំងឺនេះកើតឡើងយ៉ាងរហ័ស ហើយបាត់ទៅវិញដោយមិនដឹងខ្លួន ប៉ុន្តែ ជួនកាលជ្រូកត្រដុសខ្លួនទាល់តែរលាត់ស្បែក ។

ការព្យាបាល :

ដំបូងត្រូវរកមូលហេតុដែលបណ្តាលឱ្យមានជំងឺនេះ ។

- ផ្លាស់ប្តូររូបមន្តចំណី ពិនិត្យមេរ្យាត្រីឡើងវិញ
- ផ្លាស់ចំបើងទ្រាប់បាតទ្រុង
- ចាក់ Adrénaline ចាក់សរសៃ 2-3cc ក្នុងជ្រូក ១ក្បាល
- ចាក់ Gluconate de calcium ចាក់សរសៃ 10-20cc ក្នុងជ្រូក ១ក្បាល ចាក់ ២-៣ថ្ងៃ ។

## ជំងឺសំប៉ែតភ្លៅ

**Luxation coxo femorale**

---

មូលហេតុ :

ចិញ្ចឹមជ្រូកក្នុងទ្រុងចង្អៀត មិនអាចធ្វើចលនាបាន បណ្តាលឱ្យវាធាត់ ហើយសន្លាក់ឆ្អឹងភ្លៅភ្ជាប់ទៅនឹងឆ្អឹងគូទខ្សោយ ។ ជួនកាលបណ្តាលមកពីរអិលជើងដួលលើកំរាលទ្រុងធ្វើពីស៊ីម៉ង់ត៍ ។ មេជ្រូកមាឌតូច ហើយឱ្យបាធំពាក់ មិនអាចទ្រាំទ្រនឹងទំងន់បាបាន ក៏អាចបណ្តាលឱ្យសំប៉ែតភ្លៅដែរ ។

រោគសញ្ញា :

ដេកផ្កាប់ ភ្លៅក្រោយទាំងពីរសំប៉ែតចូលគ្នា ជ្រូកឈឺគ្មានក្តៅខ្លួនទេ ស៊ីចុកធម្មតា បើកាលណាយើងយកចំណី យកទឹកទៅដាក់ក្បែរមាត់វា ។ ទោះបីជាយើងប្រឹងជួយឱ្យជ្រូកងើបឈរ ក៏វាឈរមិនកើតដែរ ហើយពេលដេកទៅវិញ ភ្លៅនៅតែសំប៉ែតដដែល ។

ការព្យាបាល :

ជំងឺសំប៉ែតភ្លៅ ត្រូវព្យាបាលយូរថ្ងៃទើបជា ។ ក្នុងករណីជ្រូកឈឺជាជ្រូកសាច់ ត្រូវរហ័សលក់ភ្លាម ដើម្បីកុំឱ្យវាចុះទំងន់ ខាតថ្លៃថ្នាំ និង ខាតពេលវេលាថែទាំ ។ តែបើជាប្រភេទជ្រូកពូជល្អ ត្រូវព្យាបាលឱ្យវា ។

- ឱ្យជ្រូកដេកផ្អៀងមួយចំហៀង ទាញជើងក្រោយទាំងពីរឱ្យសណ្តូកស្មើគ្នា បើវាសំប៉ែតភ្លៅតែមួយចំហៀងទេ ត្រូវដាក់ចំហៀងដែល

ឈិទៅខាងលើ ។

- រឹត Salicylate de méthyle
- ចាក់ Gluconate de calcium
- ចាក់វីតាមីន C
- បញ្ចុកចំណី និង ដាក់ទឹកឱ្យជ្រូកឈឺផឹក
- ដាក់ជ្រូកឈឺលើកំរាលចំបើងក្រាស់ ដើម្បីការពារកុំឱ្យវារលាត់ស្បែក ។

ព្យាបាលរបៀបនេះពី ៥-១០ថ្ងៃ ជ្រូកអាចដើបឈរឡើងវិញបាន។

## ជំងឺប្រេះស្បែក

**Greasy pig disease**

មូលហេតុ :

ជំងឺនេះកើតមានដោយឡែកតែនៅលើសត្វជ្រូកហើយមូលហេតុបណ្ដាលមកពីអ្វីនោះ គេមិនទាន់កំណត់បានច្បាស់លាស់ទេ ។ នៅលើស្បែកជ្រូកឈឺ គេតែងឃើញមាន : Streptocoque ឬ Sphéropholus Nécrophorus ប៉ុន្តែមូលហេតុជាសំខាន់ គឺប្រហែលជាបណ្ដាលមកពីកង្វះវីតាមីន A ឬ ក៏បណ្ដាលមកពីផ្សិតក្នុងចំបើង ហើយជួនកាលគេគិតថាប្រហែលជាបណ្ដាលមកពីជំងឺប្រតិកម្ម (Allergie ) ។

រោគសញ្ញា :

ជំងឺនេះច្រើនកើតនៅលើកូនជ្រូកអាយុ ២-៤ខែ ប៉ុន្តែជួនកាលអាយុតិចជាងនេះ ជួនកាលច្រើនជាងនេះក៏មានដែរ ។ បើមានជំងឺតិចមិនរមាស់ទេ តែមិនសូវស៊ីចំណី ទុក្ខព្រួយ នៅលើស្បែកមានស្រការស្ងួត ហើយ ២-៣ថ្ងៃក្រោយ ជំងឺក៏ក្លាយជាផ្ទក់ផ្ទរ ស្បែករឹង ហើយប្រេះក្រហែង ។ ជ្រូកឈឺចុះស្គមបន្តិចម្តងៗ ហើយ ៥-១០ថ្ងៃក្រោយ ជួនកាល ២-៣អាទិត្យក្រោយ ជ្រូកងាប់ ។ អត្រាងាប់ដោយជំងឺនេះ អាចមានពី ១០-២០% ។

ការព្យាបាល :

- Penicilline ចាក់សាច់ 20 000UI ក្នុងទំងន់ជ្រូក ១គក្រ
- រោយម្សៅ Sulfamide លើស្បែកប្រេះ
- ផ្តល់វីតាមីន A ឱ្យជ្រូកឈឺឱ្យបានច្រើន ។

# ប្រតិទិនចាក់ថ្នាំការពារឱ្យកូនជ្រូក និង ជ្រូកសាច់




* **កំណត់សំគាល់ :**

បើយើងចិញ្ចឹមជ្រូកយកសាច់ ( យូរជាងមួយឆ្នាំ ) ត្រូវបន្តចាក់ថ្នាំការពារដូចតទៅនេះ :-

- វ៉ាក់សាំងសាល់ម៉ូណេឡូស ចាក់លើកទី ៤ ក្រោយលើកទី ៣ : ៣-៤ខែ
- វ៉ាក់សាំងសារទឹក ចាក់លើកទី ៣ ក្រោយលើកទី ២ : ៣-៤ខែ
- វ៉ាក់សាំងប៉េស្ត ចាក់លើកទី ៣ ក្រោយលើកទី ២ : ៤.៥-៥ខែ

## ប្រតិទិនចាក់ថ្នាំការពារឱ្យមេជ្រូក

**១- ចាក់ថ្នាំការពារមុនពេលដាក់ឈ្មោល :**

- ១៥ថ្ងៃមុនពេលដាក់ឈ្មោល ចាក់ប៉េស្ត និង សាល់ម៉ូណេឡូស
- ១០ថ្ងៃមុនពេលដាក់ឈ្មោល ចាក់សារទឹក
- មុនពេលកើត ១ខែ ចាក់សាល់ម៉ូណេឡូស ជាលើកទី ២
- ៤០ថ្ងៃក្រោយពេលកើត ចាក់សាល់ម៉ូណេឡូស ជាលើកទី ៣
- ៤៥ថ្ងៃក្រោយពេលកើត ចាក់សារទឹក និង ប៉េស្ត ជាលើកទី ២

**២- ចាក់ថ្នាំការពារពេលដើម :**

( អនុវត្តក្នុងករណីដែលមុនពេលដាក់ឈ្មោល មិនបានចាក់ថ្នាំការពារ )

- ដើមបាន ៤០ថ្ងៃ ចាក់សាល់ម៉ូណេឡូស លើកទី ១
- ដើមបាន ៤៥ថ្ងៃ ចាក់ប៉េស្ត លើកទី ១

- ជើមបាន ៥០ថ្ងៃ ចាក់សារទឹក លើកទី ១
- កើតកូនបាន ៣០ថ្ងៃ ចាក់សាល់ម៉ូណេឡូស លើកទី ២
- កើតកូនបាន ៤០ថ្ងៃ ចាក់សារទឹក លើកទី ២
- កើតកូនបាន ៤៥ថ្ងៃ ចាក់ប៉េស្ត លើកទី ២

## កម្មវិធីចាក់ថ្នាំការពារជំងឺឱ្យកូនជ្រូក និង មេជ្រូក

ដើម្បីឱ្យការចិញ្ចឹមជ្រូករបស់យើងទទួលបានលទ្ធផលសេដ្ឋកិច្ចខ្ពស់ និង ដើម្បីរួមចំណែកឱ្យការងារកសាងតំបន់សន្តិសុខពីបញ្ហាជំងឺនៅតាមមូលដ្ឋាននីមួយៗ នោះគ្រប់គ្រួសារអ្នកចិញ្ចឹមជ្រូកទាំងអស់ ត្រូវចាក់ថ្នាំការពារឱ្យមេជ្រូកមុនពេលដាក់ឈ្មោល ឬ ក្រោយពេលដាក់ឈ្មោល ១.២ខែ ។ ការចាក់វ៉ាក់សាំងការពារដល់មេជ្រូកមានសារសំខាន់ ព្រោះអាចផ្តល់អង់ទីក័រឱ្យកូនជ្រូក ។ រួចហើយមុនពេលផ្តាច់ដោះ ត្រូវចាក់វ៉ាក់សាំងបីមុខដល់កូនជ្រូក ។

### ១- វ៉ាក់សាំងប៉េស្តជ្រូក ( Peste ) :

ជាប្រភេទវីរុសរស់ ដែលគេបានបន្ថយឥទ្ធិពលរបស់វា ។ ជាប្រភេទថ្នាំម្សៅដាក់ក្នុងដប ក្នុងមួយដបលាយទឹក NaCl 9‰ 50ml រួចហើយជ្រូក ១ ចាក់ 1cc ។

ថ្នាំនេះបើរក្សាទុកក្នុងកំដៅ 0.៤°C អាចទុកបាន ៩ខែ ចាប់ពីពេលផលិត ។ កាលណាលាយជាមួយទឹក Physiologique ទុកបាន ១២ម៉ោង ។

- របៀបលាយ :

យកសីរ៉ាំង និង ម្សុល ដែលបានស្ងោរសំលាប់មេរោគ ឬ ទឹក Physiologique 10cc ចាក់បញ្ចូលទៅក្នុងដបថ្នាំ ក្រឡុកឱ្យសព្វ រួចហើយ ឬមបញ្ចូលទៅក្នុងដបទឹក Physiologique 50ml ។

- របៀបចាក់ :

កូនជ្រូកអាយុចាប់ពី ៤៥ថ្ងៃ ចាក់ 1cc សើរស្បែក ក្បែរគ្រលៀន ឬ គុម្ពត្រចៀក ។ មេជ្រូកមុនពេលដាក់ឈ្មោល ១៥ថ្ងៃ ចាក់ 1cc ចាក់សើរស្បែកក្បែរគុម្ពត្រចៀក ។ ៥ថ្ងៃក្រោយមានភាពស៊ាំ រហូតដល់កូនផ្តាច់ដោះ ទើបចាក់ជាលើកទី ២ ។ ១ខែក្រោយ ( អាយុ ៧៥ថ្ងៃ ) ចាក់ជាលើកទី ២ ។

* ប្រយ័ត្ន !

កាលណាឃើញដបវ៉ាក់សាំងប្រេះស្រាំ ឬ វ៉ាក់សាំងនោះមិនរលាយក្នុងទឹក Physiologique មិនត្រូវប្រើទេ ។ មិនត្រូវឱ្យពន្លឺថ្ងៃជះចំដបវ៉ាក់សាំងទេ វ៉ាក់សាំងដែលលាយរួចហើយ ត្រូវទុកក្នុងធុងទឹកកក ហើយត្រូវប្រើឱ្យអស់ក្នុងថ្ងៃនោះ ។

ជ្រូកឈើ និង មេជ្រូកជើម ខែទី១និងខែទី៤ និង កូនជ្រូកអាយុក្រោម ៤៥ថ្ងៃ មិនត្រូវចាក់ទេ ។ ក្នុងករណីដែលតំបន់នោះមានការរាតត្បាតនៃជំងឺ អាចចាក់ឱ្យកូនជ្រូកអាយុពី ១៥ថ្ងៃ ទៅមួយខែ ។ វ៉ាក់សាំងនេះលាយបានតែជាមួយទឹកអំបិល NaCl 9‰ មិនអាចលាយជាមួយទឹកបិន (ចំហុយ) ទេ ។

## ២- វ៉ាក់សាំងសាល់ម៉ូណេឡូស ( Salmonellose ) :

១ដប = ២០មល ។ វ៉ាក់សាំងនេះអាចរក្សាទុកក្នុងកំដៅ ៤-៨°C ក្នុងរយៈពេលបីខែចាប់ពីថ្ងៃផលិត បើរក្សាទុកក្នុងបន្ទប់ដែលមានកំដៅធម្មតាអាចទុកបាន ១ខែ ។

មុនពេលប្រើមចាក់ ត្រូវក្រឡុកឱ្យសព្វ ។ ចាក់ឱ្យកូនជ្រូកអាយុ ២១ថ្ងៃ ចាក់សើរស្បែកក្បែរត្រចៀក ឬ គុម្ពត្រចៀក ចាក់ ២មល មួយអាទិត្យក្រោយមកចាក់ម្តងទៀត ២មល ។ ចំពោះជ្រូកធំ និង មេជ្រូក មុនពេលដាក់ឈ្មោល ១៥ថ្ងៃ ចាក់ ៣មល ។ ចាក់ហើយ ១៤ថ្ងៃ ទើបមានឥទ្ធិពល ហើយភាពស៊ាំអាចបន្លាយពេលពី ៤-៦ខែ ( ៤ខែក្រោយចាក់ឡើងវិញជាការល្អ ) ។

### * ប្រយ័ត្ន !

ជ្រូកកំពុងឈឺមិនត្រូវចាក់ទេ ។ ដបដែលប្រេះ ឬ វ៉ាក់សាំងមិនរលាយក៏មិនត្រូវប្រើដែរ ដបដែលយើងបូមប្រើហើយ ត្រូវប្រើឱ្យអស់ក្នុងមួយថ្ងៃ ។ ត្រូវរក្សាវ៉ាក់សាំងនៅកន្លែងត្រជាក់ ស្ងួត និង ការពារកុំឱ្យត្រូវពន្លឺថ្ងៃ ។

## ៣- វ៉ាក់សាំងសារទឹក ( Pasteurellose ) :

ជាប្រភេទដប ( 10ml, 20ml, 50ml, 100ml )

- រក្សាក្នុងកំដៅ ៤-៨°C អាចទុកបាន ៣ខែ
- ដាក់ក្នុងបន្ទប់រក្សាទុកបាន ១ខែ

របៀបប្រើ ៖

មុនប្រើត្រូវក្រឡុកឱ្យសព្វ ។ កូនជ្រូកអាយុពី ៤០ថ្ងៃឡើង ចាក់គុម្ពត្រចៀក ឬ ក្បែរគ្រលៀន ក្នុងកំរិត ៣មល ។ មេជ្រូកមុនពេលដាក់ឈ្មោល ១៥ថ្ងៃ ចាក់គុម្ពត្រចៀក ៥មល ។ ចាក់ហើយ ១៤ថ្ងៃទើបមានប្រសិទ្ធិភាព ហើយប្រសិទ្ធិភាពនេះអាចមានរយៈពេលពី ៤-៦ខែ ។

* ប្រយ័ត្ន !

ដបប្រេះស្រាំ វ៉ាក់សាំងកកមិនរលាយ មិនត្រូវប្រើទេ ។ ជ្រូកកំពុងឈឺ និង កូនជ្រូកអាយុក្រោម ៤០ថ្ងៃ មិនត្រូវចាក់ទេ ។ ដបដែលប្រើហើយ ត្រូវប្រើឱ្យអស់ក្នុង ១ថ្ងៃ មិនត្រូវទុកប្រើរហូតដល់ថ្ងៃស្អែកទេ ។ ត្រូវរក្សាវ៉ាក់សាំងនៅកន្លែងត្រជាក់ ស្ងួត កុំឱ្យត្រូវពន្លឺថ្ងៃ ។



# ប្រភេទថ្នាំដែលគិលានុបដ្ឋាយិកាត្រូវមាន

## A- ថ្នាំសំលាប់មេរោគ :

១- **Acide borique :** ( ១ដប = ១០០ cc )

ជាថ្នាំសំលាប់មេរោគ រលាយក្នុងទឹកក្តៅឧណ្ហៗ មិនបណ្តាលឱ្យហើម ឬ រលាត់ស្បែកទេ ។ ប្រើសំរាប់លាងភ្នែក ត្រចៀក មាត់ ( លាយជាសូលុយស្យុង ២% ) ។

២- **Teinture d'iode :**( ១ដប = ១០០ cc )

សំរាប់លាងមុខរបួស កន្លែងចាក់ថ្នាំ កន្លែងវះកាត់ កន្លែងគ្រៀវ ។

៣- **Alcool iodé :** ( ១ដប = ២០០ cc )

- Teinture d'iode ១ភាគ
- Alcool ៤ភាគ

ប្រើសំលាប់មេរោគកន្លែងចាក់ថ្នាំ កន្លែងវះកាត់ កន្លែងគ្រៀវ ។

៤- **Mercurochrome** ( ១ដប = ២០០ cc )

ថ្នាំក្រហមសំរាប់សំលាប់មេរោគ មិនបណ្តាលឱ្យរលាកស្បែក សំរាប់លាបកមរមាស់ និង មុខរបួស ។ អាចលាយថ្នាំនេះជាមួយទឹកផ្ចិន សំរាប់លាងស្បូនដែលមានខ្ទុះ លាយជាសូលុយស្យុង ១‰ ( 1 cc ក្នុងទឹកផ្ចិន ១លីត្រ ) ។

៥ - **Permanganate de potassium : ( ១ដប = ៥០ក្រ )**

ដាក់ក្នុងដបពណ៌គ្របជិត ។ ថ្នាំសំរាប់លាងបន្លែមុនពេលដាក់ឱ្យជ្រូកស៊ី ( ថ្នាំ ១ក្រ លាយទឹក ១០លីត្រ ) ។ បើលាយ ០,៥ក្រ ក្នុងទឹក ២លីត្រ គឺសំរាប់លាងមុខរបួស និង លាងសំអាតស្បែន ។

៦ - **Bleu de méthylène :**

សំរាប់ឃាត់ឈាមមុខរបួស លាបកមរមាស់ លាបមាត់មានដំបៅរលាក ( លាយជាសូលុយស្យុង ១-២ % )

៧ - **Crésyl :**

ប្រើសំរាប់សំលាប់មេរោគទ្រុងចិញ្ចឹម បំបាត់ក្លិនឆ្អេះឆ្អាប សំលាប់ចៃ ។

- លាយសំរាប់សំអាតទ្រុង :

Crésyl = 50cc ( ១ស្លាបព្រាបាយ ) ទឹក ១០លីត្រ

- លាយសំរាប់ឱ្យជ្រូកដេកត្រាំ ព្យាបាលជំងឺរមាស់ :

Crésyl = 20cc ទឹក ១លីត្រ

៨ - កំបោររស់ :

ថ្ងៃថោក ស្រួលរក ប្រើសំរាប់សំលាប់មេរោគទ្រុងចិញ្ចឹម លាបជញ្ជាំង និង បាតទ្រុង ។ ដាក់នៅមាត់ទ្វាររោងចិញ្ចឹម ដើម្បីឱ្យគេដើរជាន់ពេលចេញចូលក្នុងរោងចិញ្ចឹម ។ សំរាប់រោយលើសាកសពសត្វងាប់ ។

- លាយសំរាប់លាបជញ្ជាំង :

. កំបោររស់ ១គក្រ ទឹក ១០លីត្រ

៩- ម្សៅ DDT :

សំរាប់កំចាត់ចៃ កំចាត់មូស ។

- លាយបាញ់សំអាតទ្រូង :

- DDT = 50-100g

- ទឹក ១០លីត្រ

- លាបលើខ្លួនប្រឆាំងសំលាប់ចៃ និង មេរោគ :

- DDT = 50g

- ម្សៅ Talc = 500g

១០- សំឡី ៥០០ក្រ

១១- បង់ស្អិត ១ដុំ

១២- បង់ក្រណាត់សំរាប់រុំរបួស ៥ដុំ

១៣- Pommades penicilline, Aureomycine ១ប្រអប់

១៤- Pommades sulfamide ១ដប

សំរាប់លាបបូស លាបកន្លែងពងដោរ លាបកមរមាស់

១៥- Vaseline ១ប្រអប់

១៦- Huile de foie de morue ( ខ្លាញ់ថ្លើមត្រី )

សំរាប់ព្យាបាលជ្រូកខ្វះវីតាមីន A, D ដែលបណ្តាលឱ្យជ្រូក ស្គមស្រក ចំបាត់ ( លាបលើមុខរបួស កុំឱ្យរុយទំ )

១៧- Lindane

លាបមុខរបួសកុំឱ្យរុយទំ មានប្រសិទ្ធិភាពដូចខ្លាញ់ត្រី និង

Cresyl ដែរ

B- ថ្នាំប្រើសម្រាប់រំលាយអាហារ :

១- ថ្នាំបញ្ចុះ Sulfate de soude ឬ sulfate de magnésie:

ជ្រូកទំងន់ ៥០-១០០គក្រ  ៣០-៥០ក្រ

ជ្រូកទំងន់ធ្ងន់ជាង ១០០គក្រ ៦០ក្រ

២- Bicarbonate de soude :

ជួយក្នុងការរំលាយអាហារ ព្យាបាលជំងឺក្អួតចង្អោរ លាងសំអាតក្រលៀន ពេលពុលចំណី ឬក៏ឱ្យប្រើប្រភេទថ្នាំ Sulfamide ។

វិធីប្រើ :

៥-១៥ក្រ ទៅតាមជ្រូកតូច ឬ ធំ មិនត្រូវប្រើច្រើន និង យូរថ្ងៃទេ ។ កាលណាឃើញទឹកនោមល្អក់ ត្រូវឈប់ប្រើថ្នាំនេះភ្លាម ។

៣- ថ្នាំបញ្ចុះ ប្រេងល្ហុងខ្មែរ ( Huile de ricin )

ប្រើសំរាប់បញ្ចុះមេជ្រូកដើម កាលណាទល់លាមក ឬក៏ក្រោយពេលប្រើថ្នាំបញ្ចុះព្រូន ។ ពេលប្រើថ្នាំនេះមិនត្រូវឱ្យជ្រូកផឹកទឹកទេ ត្រូវរង់ចាំ ២-៣ម៉ោង សិន ដើម្បីកុំឱ្យថ្នាំរាវពេក នាំឱ្យបាត់បង់ប្រសិទ្ធភាព ។

វិធីប្រើ :

កូនជ្រូកទំងន់ ១០-៥០គក្រ ឱ្យផឹក ៥-៣០ cc

ជ្រូកទំងន់ ១០០គក្រ ឱ្យផឹក ៥០ cc

ជ្រូកទំងន់ ២០០គក្រ ឱ្យផឹក ១០០ cc

៤- **Huile de ricin chénopodée :**

លាយប្រេង Esssence chénopodée មួយតំណក់ក្នុងប្រេងល្ហុងខ្មែរ ១ cc ប្រើសំរាប់បញ្ចុះព្រូន ។

ភរិតប្រើ :

ជ្រូកទំងន់ ១០គក្រ ឱ្យផឹក ៥-១០ cc

ជ្រូកទំងន់ ២០គក្រ ឱ្យផឹក ១០-២០ cc

ជ្រូកទំងន់ ៣០គក្រ ឱ្យផឹក ២០-៣០ cc

ជ្រូកទំងន់ ៥០គក្រឡើង ឱ្យផឹក៣០-៥០ cc

៥- **Piperazine wormer pfizer ( ថ្នាំទឹក ) :**

សំរាប់បញ្ចុះព្រូនចង្កឹះ និង ព្រូនម្ជុល ។ មេជ្រូកជើមក៏អាចប្រើថ្នាំនេះបានដែរ គ្មានគ្រោះថ្នាក់អ្វីទាំងអស់ ។

ឱ្យផឹកនៅពេលព្រឹក ពេលឃ្លានចំណី មួយខែក្រោយឱ្យផឹកម្តងទៀត ។

ភរិតប្រើ :

ជ្រូកទំងន់ ៥០គក្រ ឱ្យផឹក ២ស្លាបព្រាបាយ ( មួយស្លាបព្រាបាយមាន ១៥ cc ) លាយទឹក ១លីត្រ ឬ ដើម្បីឱ្យស្រួលគិតប្រើ ១០០មក្រ Piperazine base ក្នុងទំងន់ជ្រូក ១គក្រ ( ១ សម$^3$ ថ្នាំទឹក Piperazine wormer មាន ១៧០មក្រ Piperazine base ) ចំពោះកូនជ្រូក ។ ចំពោះជ្រូកធ្ងន់ជាង ១០០គក្រ ប្រើ ៥០មក្រ ក្នុងទំងន់ជ្រូក ១គក្រ ។

ឧទាហរណ៍ :

- .កូនជ្រូកទំងន់ ១០គក្រ ត្រូវការ Piperazine base 100mg x10= 1000mg ឬ $\frac{1cc \times 1000mg}{170} = 6cc$ ថ្នាំទឹក Piperazine wormer

- ជ្រូកទំងន់ ៥០គក្រ : 100mg x 50 = 5000mg piperazine base ឬ $\frac{1cc \times 5000mg}{170} = 50cc$ ថ្នាំទឹក Piperazine wormer

- ជ្រូកទំងន់ ១៥០គក្រ : $\frac{1cc \times 50mg \times 150}{170} = 40 - 45cc$

៦- ម្សៅស្លា ( ស្លាចាស់កិនជាម្សៅ ) :

សំរាប់ព្យាបាលជំងឺព្រូនចង្កឹះ និង ព្រូនមូល ឱ្យផឹកនៅពេលព្រឹក ពេលកំពុងឃ្លាន ៣ម៉ោងក្រោយឱ្យផឹកប្រេងល្ហុងខ្មែរ ។

កាលណាយើងបញ្ចុះព្រូនដោយប្រើស្លា អាចដាក់ទឹកឱ្យជ្រូកផឹកដោយសេរី ។ បញ្ចុះព្រូនហើយ ឱ្យស៊ីបបររាវ ស្រួលរំលាយអាហារ ។ រំលងមួយថ្ងៃឱ្យស៊ីធម្មតា ។

គិរិតប្រើ :

ជ្រូកទំងន់ ១០-៥០គក្រ ម្សៅស្លាក្រៀម ៣-៥ក្រ

ជ្រូកទំងន់ ១០០គក្រ ម្សៅស្លាក្រៀម ១០-២០ក្រ

៧- **Guanidan :**

ព្យាបាលជំងឺរាគធម្មតា ឈឺពោះវៀន ជុះចេញឈាម កុកស៊ីឌីយូស ។ ផឹកថ្នាំនេះនៅពេលឃ្លាន ផឹក ៣-៤ ថ្ងៃ ។

គំរិតប្រើ :

ជ្រូកតូច :

. ថ្ងៃទី ១, ទី ២ : ៥ក្រ

. ថ្ងៃទី ៣, ទី ៤ : ៣ក្រ

ជ្រូកធំ

. ថ្ងៃទី ១, ទី ២ : ២០ក្រ

. ថ្ងៃទី ៣, ទី ៤ : ១០ក្រ

៨- **Lentine :** ១អំពូល ១ cc ១០អំពូល

សំរាប់ព្យាបាលជំងឺទល់លាមកធ្ងន់ធ្ងររបស់ជ្រូក ចាក់សើរស្បែក សំដៅធ្វើឱ្យពោះវៀនកំរើក ជំរុញការបញ្ចេញអង្គធាតុរំលាយអាហារ ។

គំរិតប្រើ :

0,5 - 4 cc ក្នុងជ្រូកមួយក្បាល ក្នុងមួយថ្ងៃ ទៅតាមជ្រូកតូចឬធំ។

## C - ប្រភេទ ស៊ុលហ្វាមីដ ( Sulfamides ) :

. ថ្នាំគ្រាប់ ឬ ម្សៅ ៥០០ក្រ

. ថ្នាំចាក់ ៥០០ cc

ប្រភេទគ្រាប់មាន : Triple sulfa boluses, Sulmet ។ ល ។

ប្រភេទថ្នាំចាក់មាន: Triple sulfa solution, Sulmet solution

: ចាក់សរសៃក៏បាន ចាក់សាច់ក៏បាន ។

ការព្យាបាល ៖

មុខរបួសមានខ្ទុះ ហើមស្ងួត ហៀរសំបោរ សាល់ម៉ូណេឡូស កុកស៊ីឌីយ៉ូស សារទឹក ហើមពោះវៀន ហើមដោះ ហើមស្បូនមានខ្ទុះ ។ ល ។

ការិតប្រើ ៖

ក្នុងពីរថ្ងៃដំបូងឱ្យផឹកកំរិតខ្ពស់ បន្ទាប់មកចុះថយបណ្ដើរៗ ។ មិនត្រូវ ប្រើលើសពី ១០ថ្ងៃទេ ។

ក្នុងកំណាក់កាលឱ្យជ្រូកផឹក ឬ ចាក់ Sulfamides គប្បីលាយ Bicarbonate de soude 2‰ ក្នុងទឹក ឱ្យជ្រូកផឹកដោយសេរី ( ២ក្រ ក្នុងទឹក ១លីត្រ ) ។

| | កំរិតថ្នាំ Triple sulfa boluses ក្នុងទំងន់ជ្រូក ១គក្រ ផឹកក្នុងមួយថ្ងៃ | កំរិតថ្នាំ Triple sulfa solution ក្នុងទំងន់ជ្រូក ១គក្រ ចាក់ក្នុង ១ថ្ងៃ |
|---|---|---|
| ១_២ថ្ងៃដំបូង | ៣០០_៥០០មក្រ ចែកជា ២ | 1cc Triple sulfa solution |
| ១_២ថ្ងៃបន្ទាប់ | ២០០_៣៥០មក្រ ចែកជា ២ | 0,5 cc Triple sulfa solution |
| ១_២ថ្ងៃចុងក្រោយ | ៥០_៣៥០មក្រ ចែកជា ២ | 0.3 cc Triple sulfa solution |

ឧទាហរណ៍ ៖ព្យាបាលជ្រូកទំងន់ ១០គក្រ

ឱ្យផឹក Triple sulfa boluses :

- ២ថ្ងៃ ដំបូង : 300mg x 10 = 3000mg ចែកជាពីរ ឱ្យផឹកព្រឹក និង ល្ងាច
- ២ថ្ងៃ បន្ទាប់ : 200mg x 10 = 2000mg ចែកជាពីរ ព្រឹក និង ល្ងាច
- ២ថ្ងៃ ចុងក្រោយ : 50mg x 10 = 500mg ចែកជាពីរ ព្រឹក និង ល្ងាច

ចាក់សាច់ដុំ ឬ សរសៃ :

- ២ថ្ងៃ ដំបូង : 1 cc x 10 = 10 cc ( ព្រឹក ៥ cc ល្ងាច ៥cc)
- ២ថ្ងៃ បន្ទាប់ : 0,5 cc x 10= 5 cc ( ចាក់ម្តង )
- ២ថ្ងៃ ចុងក្រោយ : 0,3 cc x 10 = 3 cc ( ចាក់ម្តង )

## D- ប្រភេទអង់ទីប៊ីយ៉ូទិក ( Antibiotiques )

### ១- Pénicilline G. procaine ( ចាក់សាច់ )

1 cc មាន 300 000UI ១ដបមាន ១០ cc--- 100 cc

ព្យាបាល :

ជំងឺហើមសួត ហើមសន្លាក់ឆ្អឹង ហើមដោះ ហើមផ្ចិត ប្រភេទជំងឺមានខ្ទុះ ស្នាមរបួសមានខ្ទុះ ជំងឺសារទឹក ឈាមខ្មៅ បួសឧ្យល់ រាគសាល់ម៉ូណេឡូស ។

អាំងតេស្រី :

5000 - 30 000UI ក្នុងទំងន់ជ្រូក ១គក្រក្នុង ១ថ្ងៃ ចាក់ ៣-៤ ថ្ងៃ ។

២- **Combistrep solution :**

ចាក់សាច់ ឬ សើរស្បែក ១ដប = ៥០០ cc , 1cm³ មាន ១២៥មក្រ Streptomycine និង ១២៥មក្រ Dihydro streptomycine ។

ព្យាបាល :

ជំងឺសារទឹក ឈាមខ្មៅ ហើមសួត រលូតកូនដោយសារ Brucellose របេង ហើយនិងជំងឺរាគ ។

អាំងតេស្រី : ចាក់ ៣-៤ថ្ងៃ ។

- កូនជ្រូកបៅដោះ 0.5 - 1 cc
- កូនជ្រូកផ្តាច់ដោះ 1 cc - 1.5 cc
- មេ និង បាជ្រូក 4 - 8 cc

៣- **Combiotic aquous suspension :**

ចាក់សាច់ ១ដបមាន 10cc, 100 cc, 500 cc ។ ក្នុង ១ដប មាន

| | |
|---|---|
| - Pénicilline G. procaine | 200 000UI |
| - Dihydrostreptomycine | 250mg |

ព្យាបាល :

ជំងឺឬស ជំងឺដំបៅ សារទឹក ឈាមខ្មៅ ឈឺភ្នែក ផ្លោកនោម មានខ្ទុះ ត្រចៀកមានខ្ទុះ រាគ ហើមស្បូន ហើមសួត ព្យាបាលមុខរបួស

ក្រោយពេលគ្រៀវ។

អំពីការប្រើ : ដូច Combistrep

. កូនជ្រូកបៅដោះ 0.5 - 1 cc

. កូនជ្រូកផ្តាច់ដោះ 1 cc - 1.5 cc

. មេ និង បាជ្រូក 4 - 8 cc

**៤ - Terramycine injectable solution :**

ក្នុង ១ដប មាន ៥0 cc 1cm³ មាន ៥0មក្រ Oxytétracycline ។

ព្យាបាល :

ជំងឺរលូតកូន រលាកដោះ ហើមពោះវៀន រលាកសួត កូនជ្រូករាគ ក្តៅ ហើមស្បូន សារទឹក អុតក្តាម ប៉េស្ត និង សាល់ម៉ូណេឡូស ។

អំពីការប្រើ :

ចាក់ ៣-៤ថ្ងៃ ចាក់សាច់ក៏បាន សរសៃក៏បាន ។

. កូនជ្រូកបៅដោះ 1 cc ក្នុង ១ថ្ងៃ

. កូនជ្រូកផ្តាច់ដោះ 2 cc - 5 cc ទៅតាមជ្រូកតូច ឬ ធំ ចែកជាពីរ ព្រឹក និង ល្ងាច ។

. ជ្រូកសាច់ ២0-១00គក្រ 5 - 10 cc

. ជ្រូកធំជាង ១00គក្រ 10 cc

**៥ - Terramycin Animal Formula Soluble Powder ( TAFSP ) 453g :**

ក្នុង TAFSP 453g មាន 25g Terramycine អាចលាយក្នុងទឹក ឬ ក៏លាយក្នុងចំណីឱ្យជ្រូកស៊ី ឬ ផឹកដោយសេរី ។

ព្យាបាល :

ជំងឺសារទឹក ប៉ូសថ្លើម រៀចក្តោងប្រមុះ

ការិតប្រើ :

១ស្លាបព្រាកាហ្វេ ក្នុងទំងន់ជ្រូក ២៥គក្រ ។

**៦ - Chloramphénicol ( Tyfomycine ) : ២០គ្រាប់**

- គ្រាប់ 0,100g ; 0,250g

ព្យាបាល :

ជំងឺសាល់ម៉ូណេឡូស ក្តៅដោយសារមានមេរោគរាគត្បាត ។

ការិតប្រើ :

50 - 150 mg ក្នុងទំងន់ជ្រូក ១គក្រ ក្នុងមួយថ្ងៃ ។

**៧ - Néo-Terramycin soluble powder concentrate :**

**ក្នុងមួយកញ្ចប់ ១២០ក្រ ថ្នាំមាន :**

- Néomycine 14g
- Terramycine 20g

ព្យាបាល :

ជ្រូកខ្សោយ ហេវហត់ បាក់កំលាំង រាគ សារទឹក ហើមពោះរៀន ហើម សន្លាក់ឆ្អឹង ។

ការិតប្រើ :

១ស្លាបព្រាកាហ្វេ លាយទឹកឱ្យជ្រូកទំងន់ប្រហែល ២០-២៥គក្រ ចំនួន ៥ក្បាលផឹក ។

៨- **Terramycin A-D Scours tablets pfizer :** ១០គ្រាប់

មួយកញ្ចប់ មាន ៤គ្រាប់ ក្នុងមួយគ្រាប់មាន

- Terramycine 250mg
- Vitamine A 62 500UI
- Vitamine D 6250UI
- Vitamine PP ( Niacine ) 100mg

ព្យាបាល :

ជំងឺរាគ ហើមពោះវៀនធំ ពោះវៀនតូច ចេញឈាម ហើមផ្ចិត ហើម សួត ហើមទងសួត ហើមស្រោមសួត ស្បូនមានខ្ទុះ និង សាល់ម៉ូណេឡូស ។

គោរពប្រើ :

កាលណាជ្រូករាគ មិនស៊ីចំណី ទុយមុយ ត្រូវឱ្យផឹកថ្នាំនេះភ្លាម បើឈឺធ្ងន់ ឱ្យផឹកមួយថ្ងៃពីរដង ។

- ជ្រូក < ១០គក្រ ១ថ្ងៃ កន្លះគ្រាប់ ដល់ ១គ្រាប់
- ជ្រូកទំងន់ ១០-៣០គក្រ ១ថ្ងៃ ២គ្រាប់
- ជ្រូកទំងន់ > ៤៥គក្រ ១ថ្ងៃ ៣-៤គ្រាប់

៩- **Néomycin Scours boluses pfizer :**

ជាប្រភេទថ្នាំគ្រាប់ សំរាប់ព្យាបាលជំងឺរាគកូនជ្រូក ១កញ្ចប់មាន ៤ គ្រាប់ ។ ក្នុង ១គ្រាប់ Néomycine មាន

- Néomycine 500mg
- Vitamine A 50 000UI
- Kaolin សំរាប់ការពារភ្នាសពោះវៀន
- Pectin

ឱ្យជ្រូកដែលមានជំងឺរាគផឹក ១ថ្ងៃកន្លះគ្រាប់ ទៅ ១គ្រាប់ ។

**១០- Terramycin for mastitis pfizer :**

ថ្នាំព្យាបាលជំងឺហើមដោះ ។ ក្នុង ១ក្រ ថ្នាំមាន 30mg Terramycin ( ក្នុង ១អំពូល ១៥ក្រ មាន ៤៣៦ មក្រ Terramycin ) ។

របៀបប្រើ :

- ច្របាច់ទឹកដោះឱ្យអស់ពីដោះ
- លាងក្បាលដោះឱ្យស្អាត
- បាញ់បញ្ចូលថ្នាំក្នុងដោះ ២-៣ក្រ
- ច្របាច់អង្អែលដោះ ឱ្យថ្នាំរលាយ

**១១- Utérine boluses pfizer :** ៤គ្រាប់

ជាថ្នាំសំរាប់សុលក្នុងស្បូនដែលមានខ្ទុះ ឬក៏ធ្លាក់សុកមិនអស់ ដើម្បីសំលាប់មេរោគ ។ ក្រោយពេលលាងសំអាតស្បូនរួចហើយ សុលថ្នាំនេះឱ្យជ្រៅ ម្តង ១គ្រាប់ មួយថ្ងៃពីរដង ។

## E - ប្រភេទថ្នាំវីតាមីន ( Vitamin ) :

**១- Vit. A, D, E injectable émulsifiable :**

ចាក់សាច់ ក្នុង $1cm^3$ ថ្នាំមាន :

- Vitamine A 500 000 UI
- Vitamine D2 1 000 000 UI
- Vutamine E 50 UI

ព្យាបាល :

ជំងឺគ្រិនក្រពំ រាគ ស្គម ហើមឆ្អឹង ទន់ឆ្អឹង ចាក់កំលាំង មេកើតកូនតិច ។

វិធីប្រើ :

<u>បើឈឺធ្ងន់</u> : ១ថ្ងៃចាក់ម្តង 0.5 - 1cc ទៅតាមជ្រូកតូចឬធំ

<u>បើជំងឺស្រាល</u> : ១អាទិត្យ ចាក់ពីរដង

<u>ការពារជំងឺ</u> : ១ អាទិត្យម្តង

២ – Vit. B1 ( Benerva, Bevitine, Vitabet ) : ២០អំពូល

ព្យាបាល : ជំងឺស្ពឹក ស្រពន់

របៀបប្រើ :

| | ផឹក | ចាក់ |
|---|---|---|
| កូនជ្រូក | 20mg / ថ្ងៃ | 10mg / ថ្ងៃ |
| ជ្រូកជំទង់ | 50mg / ថ្ងៃ | 25mg / ថ្ងៃ |
| ជ្រូកធំ | 200mg / ថ្ងៃ | 100mg / ថ្ងៃ |

**៣ – Vit.C (Vitascorbol, Vitacémine, Viacet ...) : ២០អំពូល**

- ជាថ្នាំជំនួយកំលាំងដល់ជ្រូកឈឺ ចាក់កំលាំងដោយប្រឹងបង្កើតកូន ។
- ជំនួយកំលាំងដល់មេជ្រូកពិបាកកើតកូន មេមានទឹកដោះតិច ។
- ជាជ្រូកបាក់កំលាំង ពាក់មេអត់មានកូន

- មេជ្រូកកើតកូនតិច

- ជួយដល់ជ្រូកឈឺ ប្រឆាំងនឹងមេរោគ

- ជំរុញឱ្យអង្គប្រាណបង្កើតកោសិកាថ្មី ជួយឱ្យមុខរបួសទាំងខាងក្នុង និង ខាងក្រៅឆាប់ជា។

- ការពារនិងបំបាត់ធាតុភាពប្រតិកម្មដោយសារថ្នាំ Anaphylaxie

- ការពារជំងឺចេញឈាម

វីតាមីន C មិនពុលទេ ចាក់ច្រើនក៏មិនមានគ្រោះថ្នាក់អ្វីដែរ ចាក់សាច់ក៏បាន សរសៃក៏បាន ។

**គំរិតប្រើ :**

- ផឹក 0,200g - 0,500g / ថ្ងៃ ទៅតាមជ្រូកតូច ឬ ធំ

- ចាក់ 2 - 5 cc / ថ្ងៃ ទៅតាមជ្រូកតូច ឬ ធំ។

**៤- Vit. BC ( Vitamines du complexe B ) :**

មាន Bécozyme, Tétravit, Foldine --- ជាប្រភេទគ្រាប់ និង ជាប្រភេទទឹក សំរាប់ចាក់ ។

មានឥទ្ធិពលជួយដល់ការធំធាត់ បង្កើតឈាមក្រហម ព្យាបាលជំងឺបាត់បង់ឈាម មិនសូវស៊ីចំណី ជំនួយកំលាំងក្រោយពេលជាពីជំងឺ ។

**គំរិតប្រើ :**

- ចាក់ 1 - 2 cc / ថ្ងៃ ទៅតាមជ្រូកតូច ឬ ធំ

- ផឹក 0,3g ក្នុងទំងន់ជ្រូក ១គក្រ

**៥- Vit. B12 :**

ចាក់សាច់មានប្រសិទ្ធិភាពដូច Bécomplexe ។

ការគេប្រើ :

1 -3 cc ទៅតាមជ្រូកតូច ឬ ធំ ។

## F- ថ្នាំប៉ូវកំលាំង :

**១- Gluconate de calcium :** ចាក់សរសៃ

ព្យាបាល :

. ជំងឺខ្វះ Calcium : ក្រិន ស្គម ទន់ឆ្អឹង

. ជំងឺគ្រុនទឹកដោះ : ពេលកំពុងកើត និង ក្រោយពេលកើត ២៤ម៉ោង ចាក់ថ្នាំនេះអាចការពារជំងឺគ្រុនទឹកដោះ

. ជំងឺកន្ទ្រាក់ដៃជើង

. ជំងឺស្លឹក មុន និង ក្រោយពេលកើត

. ជំងឺពុលចំណី

. ឃាត់ឈាម

ការគេប្រើ :

ចាក់សរសៃ ចាក់មួយថ្ងៃ សំរាកមួយថ្ងៃ

. ជ្រូកជំទើរ 20 cc

. ជ្រូកធំ 50 cc

**២- Strychnine ( Strychnal B1, Cacostrychnine )**

ជាថ្នាំជំនួយកំលាំងនិយាយរួម ជំនួយសរសៃនិយាយដោយឡែក។

ធ្វើឱ្យជ្រូកស៊ីឆ្ងាញ់ ជួយប៉ូវកំលាំងជ្រូកទើបជាពីជំងឺ ។ ព្យាបាលជំងឺខ្សោយសរសៃ ស្ពឹកខ្លួនមួយកំណាត់ក្រោយ ។ ព្យាបាលជំងឺស្ពឹកមុន និង ក្រោយពេលកើត ។ ព្យាបាលជ្រូលពុលចំណី ។ ចាក់សរសៃក៏បាន សាច់ក៏បាន ។

របៀបប្រើ :

ក្នុង ១អំពូល 1cc មាន 1mg Strychnine

- កូនជ្រូក ½ cc
- ជ្រូកជំទើរ 1 cc
- ជ្រូកធំ 2 cc

៣ – **Serum glucosé និង Serum ទឹកប្រៃ :**

ប្រសិទ្ធិភាព :

- ប៉ូវកំលាំងជ្រូកភាគ បាត់បង់ទឹកក្នុងខ្លួននិងបាត់បង់ឈាមច្រើន។
- លាងសំអាតឈាម ដោយសារស៊ីចំណីពុល
- ប៉ូវកំលាំងដល់មេជ្រូកដែលមានជំងឺគ្រុនទឹកដោះ ។

របៀបប្រើ :

20-50 cc ទៅតាមជ្រូកតូច ឬ ធំ ចាក់សរសៃក៏បាន ស្បែកស្បែកក៏បាន។

៤ – **Cal. D. Mag solution pfizer :**

១ ដបមាន 250 cc - 500 cc

- Calcium 23 %
- Dextrose 1 %
- Magnésium gluconate 2 %

ព្យាបាល :

ជំងឺគ្រុនទឹកដោះ ជំងឺស្លឹក ពុលចំណី ។

អាំងទ្រេ :

8-20 cc ( ចាក់សរសៃ ) ទៅតាមជ្រូកតូច ឬ ធំ

៥- Cacodylate de soude :

ជាប្រភេទថ្នាំថ្លៃថោក ហើយមានប្រសិទ្ធិភាពខ្ពស់ ។

- ជួយឱ្យជ្រូកស៊ីចំណីឆ្ងាញ់

- ប៉ូវកំលាំងជ្រូកស្គម ខ្សោយ ទើបជាពីជំងឺ

- អាចចាក់ព្យាបាលជំងឺសើរស្បែក

អាំងទ្រេ :

ថ្នាំនេះមិនសូវពុលដូច Strychnine ទេ ។ ពីរថ្ងៃចាក់ម្តង ចាក់សើរស្បែក ចាក់ពីកំរិតតិចទៅច្រើន រួចហើយចុះមកកំរិតតិចវិញទាំងអស់ចាក់ ៨ម្ជុល ក្នុង ១៥ថ្ងៃ ។ ចាក់ចប់មួយវគ្គហើយ បើចង់បន្តមួយវគ្គទៀតត្រូវរង់ចាំ ១០-១៥ ថ្ងៃក្រោយ ។

| | | |
|---|---|---|
| - កូនជ្រូក | កំរិតតិច 1/3 cc | កំរិតច្រើន 1 cc |
| - ជ្រូកជំទើរ | កំរិតតិច 1/2 cc | កំរិតច្រើន 2 cc |
| - ជ្រូកធំ | កំរិតតិច 1 cc | កំរិតច្រើន 5 cc |

ឧទាហរណ៍អំពីរបៀបចាក់ Cacodylate de soude ឱ្យជ្រូក :

| ថ្ងៃចាក់ថ្នាំ | កូនជ្រូក | ជ្រូកជំទើរ | ជ្រូកធំ |
|---|---|---|---|
| ថ្ងៃទី ១ | 1/3 cc | 1/2 cc | 1 cc |
| ថ្ងៃទី ៣ | 1/2 cc | 1 cc | 2 cc |
| ថ្ងៃទី ៥ | 1/2 cc | 1 cc | 3 cc |
| ថ្ងៃទី ៧ | 1 cc | 2 cc | 5 cc |
| ថ្ងៃទី ៩ | 1 cc | 2 cc | 5 cc |
| ថ្ងៃទី ១១ | 1/2 cc | 1 cc | 3 cc |
| ថ្ងៃទី ១៣ | 1/2 cc | 1 cc | 2 cc |
| ថ្ងៃទី ១៥ | 1/3 cc | 1/2 cc | 1 cc |

## G- ថ្នាំដាក់ភ្នែក ( Optalmique ) :

- Pommade pénicilline optalmique ១ បំពង់
- Collyre sulfate de zinc ១ ដប

## H- ថ្នាំដាក់ច្រមុះ :

Rhinamide. Rhinasol ១ ដប

## I- ថ្នាំប្រើក្នុងការបន្តពូជ :

១– Post-hypophyse : ចាក់សើរស្បែក 5 UI

ផលពិពល :

ជំរុញឱ្យស្បូនកន្ត្រាក់ បញ្ចេញកូនមកក្រៅ ។

ប្រើចំពោះតែនៅលើមេជ្រូក ដែលកូនគ្រប់ខែ ថ្ងៃ កស្បូនរីកធំ តែមេខ្ជិលប្រឹង ។ បើមិនដូច្នោះទេអាចបណ្តាលឱ្យមានគ្រោះថ្នាក់ ដោយសារតែរហែកស្បូន ។ ក្នុងករណីកូនងាប់ក្នុងពោះ ក៏មិនត្រូវចាក់ថ្នាំនេះដែរ ។

- អាចចាក់ឱ្យមេជ្រូកដែលកើតកូនអស់ហើយ តែសុកមិនព្រមធ្លាក់ ។

- ប្រើចំពោះមេជ្រូកមានទឹកដោះតិច មិនគ្រប់គ្រាន់ ដើម្បីចិញ្ចឹមកូន ។

មួយថ្ងៃចាក់ ៤ដង ម្តង 5 UI ចាក់ហើយត្រូវលែងឱ្យកូនបៅភ្លាម ។

ការិតប្រើ :

ក្នុង ១ថ្ងៃ ចាក់ពី 10- 20 UI

*ប្រយ័ត្ន !

មិនត្រូវចាក់ថ្នាំនេះទៅលើមេជ្រូកធើមទេ ។

២ – **Progesterone ( Hormone luteate : Lutogyl )**

**Luteine :** ១ ប្រអប់

ចាក់ឱ្យមេជ្រូកដាក់ឈ្មោលហើយ តែមិនមានកូន ( ចាក់សើរស្បែក ) ។

វិធីប្រើ :

១ថ្ងៃ ចាក់ 25mg ចាក់ ២-៣ថ្ងៃ

៣- Folliculine ( Hormone Oestrogène ) Oestrone.

Zoo-gynoestryl Benzoate d'oestradiol : ១ ប្រអប់ ប្រើក្នុងករណីមេជ្រូករកឈ្មោលមិនទៀងទាត់ ចាក់ ១ថ្ងៃ 30 000 UI ឬ 3mg ចាក់ ២-៣ថ្ងៃ ចាក់ហើយបើមិនឃើញរកឈ្មោលទេ ១៥ថ្ងៃក្រោយ ចាក់ម្ដងទៀត ចាក់សាច់ សរសៃ សើរស្បែក បានដូចគ្នា ។

៤- Testotérone ( Stérandryl )- Extrait Orchitique :

ព្យាបាលបាជ្រូកខូចប្រដាប់បន្តពូជ ខ្សោយកំលាំង ពាក់ញីមិនមានកូន ហើមថ្លោកនោម មេជ្រូកមានដុំពក ( Tumeur ) នៅដោះ ។

វិធីប្រើ :

ពីរថ្ងៃចាក់ម្ដង ចាក់រហូត ១០-២០មុល ចាក់សើរស្បែក ឬ ចាក់សាច់ ។

៥- ថ្នាំជំរុញឱ្យមេជ្រូកមានទឹកដោះច្រើន :

- Thyrosine : ១ថ្ងៃ ចាក់ 2 cc ចាក់ ២-៣ថ្ងៃ

- Prolactine ឬGalactine : ចាក់ ១ថ្ងៃ 50-100UI ចាក់ ២-៣ថ្ងៃ ។

- Galactogène ឱ្យផឹក ១ថ្ងៃ ៣ដង ម្ដង ១៥តំណក់ ដាក់ក្នុងបបរឱ្យមេជ្រូកស៊ី រហូតដល់មានទឹកដោះគ្រប់គ្រាន់ទើបឈប់ ។

- Galactogil : ឱ្យផឹក ១ថ្ងៃ ៣ដង ម្តងមួយស្លាបព្រាបាយ លាយជាមួយចំណី ឱ្យស៊ីរហូតដល់មានទឹកដោះគ្រប់គ្រាន់ ។

## J- ថ្នាំលាប រឹត បំបាត់ការចុកចាប់ និង សំរួលសរសៃប្រសាទ :

១– **Salicylate de méthyle :**

លាបកន្លែងពកហើម លាបសន្លាក់ឆ្អឹង និង រឹតសរសៃថ្លោះ ។

២– **Huile camphrée, Solucamphre, Cafeine :**

ថ្នាំជំនួយបេះដូង ប្រើពេលហេវហត់ បេះដូងដើរខ្សោយ រាគពុលចំណី ព្យាបាលជំងឺហើមសួត សាលម៉្មូណេឡូស ។ ល ។

៣– **Phénergan, Aniline, Antergan, Néo- antergan :**

ព្យាបាល :

. ជំងឺឡើងកន្ទួលដោយសារប្រតិកម្មថ្នាំ ឬ ប្រតិកម្មចំណី

. ជំងឺហឺត ជំងឺរមាស់ ហើមសួត ក្អក

វិធីប្រើ :

ចាក់សាច់ 2mg ក្នុងទំងន់ជ្រូក ១គក្រ ។ ជ្រូកទំងន់ ១០គក្រ ចាក់ 20mg ឬ ជិត 1 cc Phénergan ចែកជាពីរ ។

ផឹក 4-5mg ក្នុងទំងន់ជ្រូក ១គក្រ ។ ជ្រូកទំងន់ ១០គក្រ ឱ្យផឹក 40-50mg Sirop phénergan ចែកជា ៤-៥ដង ក្នុង ១ថ្ងៃ ។

៤– **Gardénal :**

ថ្នាំធ្វើឱ្យងងុយដេក ។ ប្រើសំរាប់ព្យាបាលជំងឺពុលដោយសារ

Strychnine ។

ព្យាបាលជំងឺកន្ត្រាក់សរសៃ ប្រកាច់ ( តេតាណូស )។

វិធីប្រើ :

ផឹក 10- 100mg ទៅតាមជ្រូកតូច ឬ ធំ

៥- **Largactil :** ១អំពូល 5 cc ៥អំពូល

ថ្នាំធ្វើឱ្យងងុយដេក បំបាត់ការចុកចាប់ ដូច Gardénal ដែរ ។

ចាក់ព្យាបាលសត្វមានជំងឺ កន្ត្រាក់សរសៃ ប្រកាច់ ក្អួត ហើម សរសៃ ឈឺសន្លាក់ឆ្អឹង ។

ប្រើឧបករណ៍ :

គ្រៀវ វះបូស និង វះកាត់ ។ ល ។

ជ្រូកធំ ចាក់ម្តង 5 cc

ជ្រូកតូច ចាក់ម្តង 1-2 cc ចាក់សាច់ ចាក់ ៣-៤ដងក្នុង ១ថ្ងៃ ។



# References

1- A Colour Atlas of Diseases & Disorders of the Pig W.J.Smith. D.J.Taylor, R.H.C. Penny. Wolfe Publishing limited 1990.

2- Animal Health in Australia. Volume 6. Bacterial and fungal Diseases of Pig. J.R. Buddle 1985

3- Diseases of Swine 7 th Edition fourth printing 1996 IOWA state university press / Ames. IOWA. USA.

4- Les maladies du porc. Howard W. Dunne. Vigot frères éditeurs 1962.

5- Manuel pratique des maladies du porc - Dr. méd.Vét. Karl - Otto Eich.
Adaptation : H. Fuchs - Dr. Vét. J.P. Alno
La France agricole 1987

6- Manuel Vétérinaire 2e. édition 1988. Ministère de la Coopération et du Développement. La documentation française.

7- Pig Diseases. D.J. Taylor six edition. 1995

8- Skin diseases of the pig. R.D.A. Cameron, MVSc., PhD., M.R.C.V.S. 1984

9- Benh lon o Viet Nam. Trinh Van Thinh NXB. Khoa hoc va ky thuat Ha Noi 1985.

10- Nuoi heo thuc hanh. Ho Van Giá NXB Tong hop Tien Giang. 1991.

11- Phong tri benh Heo nai, Heo Con. Heo thit. BS Nguyen Xuan binh 1991

12- Vacxin va Thuoc thú y - Cong ty thuoc thú y trung uong2. NXB nong nghiep. TPHCM- 1995.

## មាតិកាអត្ថបទ

I- វិធីបន្តឡើងដោយទីរុស ទំព័រ

១. ផ្កាសាយ ១

២. ប៉េស្ត ៤

៣. អុត ៧

៤. ក្អកក្តែងក្លាយ ១០

៥. អុតក្តាម ១៣

៦. រលាកស្អូត ១៦

៧. រលាកពោះវៀន ១៨

៨. រលាកបំពង់កមានពងដោរ ២១

II- វិធីបន្តឡើងដោយបាក់តេរី

៩. ឈាមខ្មៅ ២៣

១០. បូសខ្យល់ ២៧

១១. កញ្ជ្រិល ២៨

១២. សារទឹក ៣៣

១៣. របេង ៣៧

១៤. រលូតកូន ៣៩

១៥. ឡិបតូ ៤៣

១៦. សាល់ម៉ូណេឡូស ៤៧

១៧. រាគស ៥១

១៨. តេតាណូស ៥៣

III- ជំងឺញ៉ាំស៊ីត

១៩. គ្រុនចង្អឹះ ៥៦

២០. គ្រុនស្វិត ៦០

២១. ចុងអង្ករ ៦២

២២. កមរមាស់ ៦៣

២៣. កុកស៊ីឌីយ៉ូស ៦៦

IV- ជំងឺមេជ្រូក

២៤. ជំងឺពិបាកកើតកូន ៦៩

២៥. រលាកដោះ ៧៦

២៦. រលាកស្បូន ៧៩

២៧. គ្រុនទឹកដោះ ៨៣

២៨. ស្គីក ៨៦

២៩. ធ្លាក់ផ្លូវយោនី ៨៩

V- បញ្ហាកើតមាននៅលើមេ និង បាជ្រូក

៣០. មេស៊ីកូន ៩០

៣១. មេកើតកូនហើយមិនធ្លាក់សុក ៩១

៣២. មេកើតកូនតិច ៩៤

៣៣. មេកូនធំតូចមិនស្មើគ្នា ៩៥

៣៤. មេខ្វះទឹកដោះឱ្យកូនពៅ ៩៧

៣៥. មេមិនឱ្យកូនបៅ ៩៩

៣៦. មេកើតកូនមិនអស់ ១០០

៣៧. បាជ្រូកបាត់បង់សមត្ថភាព ១០១

៣៨. បាជ្រូកឱ្យកូនតិច ១០៤

VI- ជំងឺកូនជ្រូក

៣៩. រាគពេលនៅបៅដោះ ១០៦

៤០. ហើមផ្ទិត ១០៩

៤១. ខ្វះជាតិស្ករក្នុងឈាម ១១១

៤២. កូនជ្រូកបៅដោះមិនរំលាយអាហារ ១១៣

VII- ជំងឺពុល

៤៣. ពុលថ្នាំ និង ពុលចំណី ១១៥

៤៤. ពុលអំបិល ១១៧

៤៥. ពុលផ័រកៅស៊ីក្រាលថ្នល់ ១១៩

៤៦. ពុលចំណីដុះផ្សិត ១២០

៤៧. ពុល[illegible]ជូរ ផ្អូម ១២២

VIII- ជំងឺទូទៅ

៤៨. ហើមសួត ១២៤

៤៩. ទល់លាមក ១២៦

៥០. លៀនក្រសាល់គូទ ១២៧

៥១. ក្ដៅ ហប់ ស្ពុះស្លាប់ ១២៩
៥២. ដំបៅមានដង្កូវចោះ ១៣១
៥៣. របកស្បែកដោយកំដៅថ្ងៃ ១៣២
៥៤. ប្រតិកម្ម ១៣៣
៥៥. សំប៉ែតភ្លៅ ១៣៥
៥៦. ប្រេះស្បែក ១៣៦
IX- ប្រតិទិនចាក់ថ្នាំការពារ ១៣៨
- ប្រតិទិនចាក់ថ្នាំការពារឱ្យមេជ្រូក ១៣៩
- ប្រតិទិនចាក់ថ្នាំការពារជំងឺឱ្យកូនជ្រូក និង មេជ្រូក ១៤០
+ វ៉ាក់សាំងប៉េស្តជ្រូក ១៤០
+ វ៉ាក់សាំងសាល់ម៉ូណែឡូស ១៤២
+ វ៉ាក់សាំងសារទឹក ១៤២
X- ប្រភេទថ្នាំដែលគសិដ្ឋានចិញ្ចឹមជ្រូកត្រូវមាន
- ថ្នាំសំលាប់មេរោគ ១៤៤
- ថ្នាំប្រើលើប្រដាប់រំលាយអាហារ ១៤៧
- ថ្នាំស៊ុលហ្វាមីដ ១៥០
- ថ្នាំអង់ទីប៊ីយ៉ូទីក ១៥២
- ថ្នាំវីតាមីន ១៥៧
- ថ្នាំប៉ូវកំលាំង ១៦០
- ថ្នាំដាក់ភ្នែក ១៦៣

- ថ្នាំដាក់ច្រមុះ ១៦៣
- ថ្នាំប្រើក្នុងការបន្តពូជ ១៦៣
- ថ្នាំលាប វីត បំបាត់ការចុកចាប់ និង សំរួលសរសៃប្រសាទ ១៦៦

XI – សំខាន់ឯកសារយោង ១៦៨

XII- មាតិកាអត្ថបទ ១៦៩

សូមអញ្ជើញរកជាវអាន សៀវភៅបច្ចេកទេសចិញ្ចឹមសត្វ

របស់ បណ្ឌិត ជា ឈេង :

- បច្ចេកទេសចិញ្ចឹមជ្រូក
- បច្ចេកទេសចិញ្ចឹមមាន់
- បច្ចេកទេសចិញ្ចឹមទា

សៀវភៅ ជំងឺជ្រូក

បោះពុម្ពលើកទី ៣ ចំនួន ១.០០០ក្បាល

ឆ្នាំ ១៩៩៩